សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Universite´ Royale de Droit et des Sciences Economiques
Royal University of law and Economics

**សារណាបញ្ចប់ការសិក្សា**

# ប្រាតិភោគដោយអនុប្បទាន

ស្រាវជ្រាវពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០២១

តាក់តែងឡើងដោយ

និស្សិតឈ្មោះ លោក **អឿន វណ្ណា**

លោកស្រី **ហោ ផានី**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ឧុធ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# លិខិតថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ អឿន វណ្ណា និង ហោ ផានី ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ជំនាន់ទី២២ នៃ សាកលវិទ្យាល័យភូមិនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨ – ២០២២ ។

សូមគោរពលំឱនកាយវាចាចិត្ត សម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅ

ជាទីបំផុតចំពោះ ៖

លោកឳពុក ងិន សំអឿន　　　　លោកឳពុក ហោ ហួត

អ្នកម្តាយ ផាន់ នាង　　　　អ្នកម្តាយ សៀ គឹមស្រ៊ាន់

ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅជួយទំនុបបំរុងដល រូបកូនៗទាំងស្មារតី និងសម្ភារៈគ្រប់បែបយ៉ាងជាពិសេសរួមទាំងការផ្តល់ដំបូន្មានដ៏ល្អៗរបស់លោកដល់រូបកូននៅជាកុមារភាព រហូតដល់កូនធំពេញវ័យ និងបានទទួលការបណ្តុះបណ្តាលតាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា ។ លោកទាំងពីរបានព្យាយាមប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់ខ្លួនក្នុងការជួយទំនុបបំរុងទិសឱ្យកូនៗ មាន អនាគតភ្លឺស្វាង រីកចម្រើនទៅមុខ និងអភិវឌ្ឍន៍ខ្លួនឱ្យក្លាយជាសិស្សល្អ និងពលរដ្ឋល្អនៅក្នុងសង្គមជាតិ ។

ឯកឧត្តមសាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសមត្ថភាពខ្ពង់ខ្ពស់ និងបានជួយតម្រង់ទិសយើងខ្ញុំ តាំងពីឆ្នាំសិក្សាមូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រប្រកបដោយក្រមវិជ្ជាជីវៈ ។

លោកសាស្ត្រាចារ្យ **ញឹក ឧត្តម** ដែលលោកបានដឹកនាំបង្ហាត់បង្ហាញនូវគំនិត និងវិធីសាស្ត្រល្អៗ ទាក់ទងនិងប្រធានបទ រួមទាំងចំណាយពេលវេលាដ៏មានតម្លៃរបស់លោក តាំងពីដើមរហូតដល់ការស្រាវជាវ មួយនេះ ។ ស្នាដៃដែលកើតឡើងចេញពីការស្រាវជ្រាវមួយនេះ ពិតជាមិនអានមានអត្ថិភាពឡើយ ប្រសិនបើគ្មាន ការជ្រោមជ្រែងពីលោក ។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីនាក់ សូមធ្វើការអរគុណ និងដឹងគុណម្តងទៀតដល់អ្នកមានគុណទាំងពួង ដែលបានរៀបរាប់ខាងលើ សូមបានប្រកបតែនឹងពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

បន្ទាប់ពីចំណាយអស់រយៈពេល ៤ឆ្នាំ ដែលខ្ញុំទាំងពីរនាក់បានទទួលការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ព្រមទាំងមុខវិជ្ជាជាច្រើនរួមមានទាំងនីតិជាតិ នីតិអន្តរជាតិ ថែមទាំងនីតិឯកជន និងនីតិសាធារណៈ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរួចមក ។ ដោយក្រោមការយកចិត្តទុកដាក់ប្រឹងប្រែងបង្ហាត់បង្រៀនរបស់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ ទើបខ្ញុំទាំងពីរមានឱកាសឈានដល់ការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី២២ និងជាចំណែកមួយក្នុងការអភិវឌ្ឍន៍វិស័យអប់រំនៅកម្ពុជា។ ជាមួយគ្នានេះដែរ ការសរសេរសារណាមិនមែនងាយស្រួលដូចជាកិច្ចការផ្ទះ ឬកិច្ចការស្រាវជ្រាវកន្លងមកនោះទេ តែបែរជាតម្រូវឲ្យយើងទាំងពីរនាក់ត្រូវមានភាពអំនត់ ស៊ូទ្រាំ បូករួមទាំងចំណេះដឹងខ្លះៗ ក្នុងការសរសេរវាឡើងមក ដោយហេតុថាអំឡុងពេលសរសេរ យើងអាចនឹងជួបប្រទះនូវការលំបាកដោយមិនបានគិតទុកជាមុន ដែលវាធ្វើឲ្យយើងទទួលបាននូវភាពរីកចម្រើនទៅមុខក្នុងការដោះស្រាយផងដែរ។

យើងខ្ញុំទាំងពីរបានជ្រើសរើសប្រធានបទ « **ប្រាតិភោគដោយអនុប្បទាន** » ដើម្បីចងក្រងធ្វើជាសារណាបញ្ចប់ការសិក្សា ដោយយើងទាំងពីរសម្លឹងឃើញថាមានសិស្សច្បងភាគច្រើនបាន រៀបចំសំណៅឯកសារ និងសារណាដែលពាក់ព័ន្ធទៅនឹងទ្រឹស្តី សញ្ញាណទូទៅ និងគោលការណ៍របស់ប្រាតិភោគដោយអនុប្បទានប៉ុណ្ណោះ យ៉ាងនេះទើបខ្ញុំទាំងពីរនាក់បន្ថែមពីភាពខុសគ្នារវាងទ្រឹស្តីរបស់ច្បាប់ និង ការអនុវត្តជាក់ស្តែងនៅប្រទេសកម្ពុជា។ ការអនុវត្តប្រាតិភោគដោយអនុប្បទាន គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់អាជីវករពាណិជ្ជករ និងវិនិយោគិនជាដើម ព្រោះថាការរស់នៅក្នុងសង្គមយើងសព្វថ្ងៃ មិនអាចជៀសឆ្ងាយពីបញ្ហាសេដ្ឋកិច្ចបាននោះទេ ហេតុនេះហើយយើងទាំងពីរនាក់ក៏បានសម្រេចចងក្រងសារណានេះឡើងមក ។

ចុងបញ្ចប់ ខ្ញុំទាំងពីរនាក់សង្ឃឹមយ៉ាងមុតមាំថា ស្នាដៃដ៏តូចមួយនេះនឹងក្លាយជាប្រយោជន៍ដល់ការអនុវត្តប្រាតិភោគដោយអនុប្បទាន ជាពិសេសទុកឲ្យប្អូនៗជំនាន់ក្រោយបានសិក្សាស្វែងយល់បន្ថែមពីចំណុចសំខាន់ៗនៅក្នុងសារណាមួយនេះ។ ទន្ទឹមនឹងនេះ ការចងក្រងសារណានេះឡើង វាអាចនឹងមានការខ្វះចន្លោះដោយប្រការណាមួយ ដែលត្រូវការកែតម្រូវនាពេលខាងមុខ ដូចនេះយើងខ្ញុំទាំងពីរនាក់សូមមេត្តាខន្តីអភ័យទោសចំពោះរាល់កំហុសឆ្គងក្នុងការតាក់តែងនេះ ហើយក៏សូមស្វាគមន៍នូវ ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកស្រាវជ្រាវគ្រប់រូបដើម្បីជាបច្ច័យក្នុងការកែលម្អសមិទ្ធផលមួយនេះ ឲ្យកាន់តែប្រសើរឡើងថែមមួយកម្រិតទៀត ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ...... ១
ក. លំនាំបញ្ហានៃការស្រាវជ្រាវ...... ២
ខ. ចំណោទបញ្ហា ...... ២
គ. គោលដំណងនៃការសិក្សាស្រាវជ្រាវ...... ៣
ឃ. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ...... ៣
ង. វិធីសាស្ត្រនៃការស្រាវជ្រាវ...... ៣
ច. សារៈសំខាន់នៃការស្រាវជ្រាវ...... ៣
ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ...... ៤

## ជំពូកទី ១
## សញ្ញាណទូទៅ នៃប្រាតិភោគដោយអនុប្បទាន

**ផ្នែកទី១. សញ្ញាណទូទៅ** ...... ៦
កថាភាគទី១. និយមន័យ...... ៦
កថាភាគទី២. អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ...... ៧
កថាភាគទី៣. ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ...... ៧
កថាភាគទី៤. ការបង្កើតកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ...... ៧
កថាភាគទី៥. លក្ខខណ្ឌគ្រឹះ...... ៧
ក. ការព្រមព្រៀង...... ៧
ខ. កម្មវត្ថុ...... ៨
គ. លក្ខខណ្ឌសមត្ថភាពគូភាគី ...... ៨
កថាភាគទី៦. លក្ខខណ្ឌទម្រង់ ...... ១០
កថាភាគទី៧. អានុភាពតតាំង...... ១០
ក. ការផ្ទេរការកាន់កាប់ដោយជាក់ស្តែង...... ១១
ខ. ការផ្ទេរការកាន់កាប់ដោយប្រយោល...... ១១
គ. ការផ្ទេរការកាន់កាប់ដោយសង្ខេប ...... ១១
ឃ. ការផ្ទេរការកាន់កាប់ដោយបញ្ជា...... ១២
**ផ្នែកទី២. អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន**...... ១២
កថាភាគទី១. ទំហំនៃអានុភាពរបស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ...... ១៣
កថាភាគទី២. អានុភាពចំពោះផល...... ១៤

## ជំពូកទី២
## ការអនុវត្តឧបាទេសកម្ម និងការអនុវត្តសិទ្ធិ

**ផ្នែកទី១. ឧបាទេសកម្ម**.....១៦
កថាភាគទី១. ឧបាទេសកម្មលើចលនវត្ថុដែលមិនមែនជាចលនវត្ថុដុំគ្នា .....១៦
កថាភាគទី២. ឧបាទេសកម្មលើចលនវត្ថុដុំ.....១៧
កថាភាគទី៣. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន.....១៨
កថាភាគទី៤. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន .....១៩
កថាភាគទី៥. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា .....២០
កថាភាគទី៦. បញ្ញត្តិពិសេសក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុ.....២១
ក.សិទ្ធិឃាត់ទុក.....២១
ខ.ករណីកិច្ចរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានក្នុងការរក្សាទុកវត្ថុ.....២២
គ.សិទ្ធិទាមទារឲ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន.....២២
**ផ្នែកទី២. ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន**.....២៣
កថាភាគទី១. ការចាត់ចែងប្តូរជាប្រាក់.....២៤
ក.អនុប្បទានជាស្ថាពរ.....២៤
ខ.ករណីកិច្ចត្រូវបង់ទឹកប្រាក់ដែលលើស.....២៤
គ.សិទ្ធិទទួលយកវិញរបស់អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន.....២៤
កថាភាគទី២. ការអនុវត្តអត្រាការប្រាក់.....២៥
កថាភាគទី៣. ស្ថាប័នមានសមត្ថកិច្ចទាក់ទិននឹងប្រាតិភោគដោយអនុប្បទាន .....២៦
ក. ក្រសួងយុត្តិធម៌ .....២៦
ខ. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ.....២៦
គ. តុលាការ.....២៧

## ជំពូកទី៣
## ការអនុវត្តការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន

**ផ្នែកទី១. ការភាន់ច្រឡំរវាងការបញ្ចាំនិងប្រាតិភោគដោយអនុប្បទានរបស់ប្រជាពលរដ្ឋ**.....២៩
កថាភាគទី១. ការង្កើតកិច្ចសន្យាបង្កើតសិទ្ធិ .....៣០
កថាភាគទី២. អានុភាពនៃសិទ្ធិ.....៣០
កថាភាគទី៣. ការអនុវត្តសិទ្ធិ ក្នុងករណីដែលកាតព្វកិច្ចពុំត្រូវបានអនុវត្ត.....៣០
**ផ្នែកទី២.ការអនុវត្តប្រាតិភោគដោយអនុប្បទាន** .....៣១
កថាភាគទី១. កម្រិតយល់ដឹងរបស់ប្រជាជនកម្ពុជា ទៅលើប្រាតិភោគដោយអនុប្បទាន.....៣១
កថាភាគទី២. បញ្ហាការភាន់ច្រឡំរវាងការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន.....៣២
កថាភាគទី៣. ការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានមានអាជ្ញាបណ្ណ.....៣២

កថាភាគទី៤. ការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយពុំមានអាជ្ញាបណ្ណ..................៣៣
កថាភាគទី៥. បញ្ហាអត្រាការប្រាក់ត្រឹមត្រូវតាមច្បាប់..............................................................៣៤
កថាភាគទី៦. បញ្ហាអត្រាការប្រាក់ខុសច្បាប់...........................................................................៣៥
កថាភាគទី៧. បញ្ហាការកត់ត្រាព័ត៌មានប្រាតិភោគដោយអនុប្បទាន និងការប្រមូលពន្ធ..................៣៦
ក. ភាពមិនអាចត្រួតពិនិត្យបាននូវព័ត៌មានប្រាតិភោគដោយអនុប្បទាន..................................៣៦
ខ. បញ្ហាទាក់ទិននឹងការប្រមូលពន្ធ......................................................................................៣៦
កថាភាគទី៨. ការប្រើប្រាស់បច្ចេកវិទ្យាជំនួយក្នុងការប្រមូលព័ត៌មាន..........................................៣៧
កថាភាគទី៩. ដំណោះស្រាយទាក់ទិននឹងការប្រមូលព័ត៌មាន..................................................៣៧
**សេចក្ដីសន្និដ្ឋាន**..........................................................................................................៣៩
**អនុសាសន៍**..................................................................................................................៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នីតិរដ្ឋប្បវេណី ជាប្រភេទច្បាប់ដែលវិវត្តមកពីច្បាប់រ៉ូម៉ាំងសរសេរមួយ ច្បាប់នេះត្រូវបានប្រទេសបារាំងអនុម័តបន្ទាប់ពីមានបដិវត្តបារាំងនៅឆ្នាំ ១៧៨៩ ។ ច្បាប់នេះត្រូវគេឱ្យឈ្មោះថា ក្រមណា ប៉ូឡេអុង ហើយក្រមនេះ គ្របដណ្តប់តែលើនីតិឯកជនប៉ុណ្ណោះ ។

មុនសម័យអាណានិគមនិយមបារាំង កម្ពុជាត្រូវបានគ្រប់គ្រងដោយរបបរាជានិយម ដែលនៅពេលនោះមានតែច្បាប់ប្រុស ច្បាប់ស្រី ដែលមានលក្ខណៈជាទំនៀមទម្លាប់ប៉ុណ្ណោះ ។ បន្ទាប់មកបារាំងបានដាក់អាណានិគម មកលើប្រទេសកម្ពុជា ក្នុងនោះបារាំងបាននាំមកជាមួយនូវច្បាប់របស់ខ្លួនមកកម្ពុជាផងដែរ ។ នៅក្នុងនោះក្រមរដ្ឋប្បវេណីណាប៉ូឡេអុងជាភាសាបារាំង ត្រូវបានប្រកាសឱ្យប្រើដោយព្រះអង្គម្ចាស់ ស៊ី សុវត្ថិ នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩២០ បន្ទាប់មកក្រមនេះត្រូវបានបកប្រែជាភាសាខ្មែរនឹងកែប្រែនៅឆ្នាំ ១៩៦៧ ដែលដឹកនាំដោយលោក អេង សុត ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រហូតដល់ឆ្នាំ ២០០៧ ក្រមរដ្ឋប្បវេណីថ្មីត្រូវបានប្រកាសឱ្យប្រើ និងអនុវត្តនៅឆ្នាំ ២០១១។

នីតិរដ្ឋប្បវេណី ជានីតិសម្រាប់គ្រប់គ្រងទំនាក់ទំនងទាំងអស់របស់ពលរដ្ឋខាងផ្លូវឯកជន ។ ជានីតិមួយនៃនីតិឯកជន ជានីតិរួម ដែលបទដ្ឋាននានាកំណត់អំពីការរស់នៅរបស់មនុស្ស នឹងបេតិកភណ្ឌរបស់មនុស្សម្នាក់ៗ ពីអត្រាកូលដ្ឋានដែលទាក់ទងនឹងសមត្ថភាពខាងផ្លូវច្បាប់របស់បុគ្គលទំនាក់ទំនង អំពីអាពាហ៍ពិពាហ៍ការកាន់កាប់ទ្រព្យសម្បត្តិ ប្រាតិភោគ នឹងកំណត់អំពីទំនាក់ទំនងនៃសិទ្ធិ នឹងកាតព្វកិច្ចដែលភ្ជាប់ពីមនុស្សម្នាក់ទៅនឹងមនុស្សម្នាក់ទៀត ។

នីតិត្រូវបានបែងចែកចេញជាពីរប្រភេទ គឺ នីតិសាធារណៈ នឹងនីតិឯកជន ។ ចំពោះច្បាប់ដែលស្ថិតក្នុងប្រភេទនីតិសាធារណៈមានដូចជា រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបោះឆ្នោត ច្បាប់ស្តីពីការបង្កើតក្រសួងស្ថាប័ន ។ល។ ដោយឡែកចំពោះច្បាប់ដែលស្ថិតនៅក្នុងប្រភេទនៃនីតិឯកជនវិញមានដូចជា ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ជាដើម ។

ការកំណត់ពីអត្ថន័យនៃនីតិឯកជន នឹងនីតិសាធារណៈ គឺមានការពិបាក ។ ប៉ុន្តែនាពេលបច្ចុប្បន្ន គេអាចកំណត់បានថា បទបញ្ញត្តិទាំងឡាយដែលសម្រាប់កំណត់នូវទំនាក់ទំនងស្មើរគ្នារវាងបុគ្គលឯកជន នឹងបុគ្គលឯកជន រីឯនីតិសាធារណៈវិញ គឺសំដៅទៅលើបញ្ញត្តិដែលកំណត់នូវទំនាក់ទំនងរវាងរដ្ឋជាមួយបុគ្គលឯកជន ឬទំនាក់ទំនងរវាងរដ្ឋបាលមូលដ្ឋានជាមួយនឹង បុគ្គលឯកជនដោយទទួលស្គាល់ឧត្តមភាពរបស់ស្ថាប័នរដ្ឋក្នុងនាមជាប្រធាននៃអំណាចនៅក្នុងទំនាក់ទំនងនោះ ។

នៅក្នុងនីតិឯកជននេះ ត្រូវបានគេបែងចែកចេញជាច្បាប់ទូទៅ នឹងច្បាប់ពិសេសដែលក្នុងនោះ ក្រមរដ្ឋប្បវេណីត្រូវបានគេកំណត់ថាជាច្បាប់ទូទៅនៃនីតិឯកជន ។ ក្នុងករណីដែលច្បាប់ទាំងឡាយណាមានកំណត់នូវ វិសាលភាពច្បាស់លាស់ចំពោះមនុស្សវត្ថុទីកន្លែង នឹងសកម្មភាពដែលជាកម្មវត្ថុនៃការអនុវត្តច្បាប់ ច្បាប់នោះហៅថា ច្បាប់ពិសេស ផ្ទុយទៅវិញប្រសិនបើមិនមានការកំណត់នូវវិសាលភាពនៃការអនុវត្តមិនច្បាស់លាស់ទេពោលគឺត្រូវយកទៅអនុវត្តជាទូទៅច្បាប់ប្រភេទនោះហៅថាច្បាប់ទូទៅ ។ ក្នុងករណីដែលបញ្ហាថាត្រូវអនុវត្ត

បទដ្ឋានច្បាប់មួយណានោះ បញ្ញត្តិច្បាប់ពិសេសត្រូវយកទៅអនុវត្តដោយមានអនុភាពទៅលើបញ្ញត្តិច្បាប់ទូទៅ ដែល នេះគឺជាផលប្រយោជន៍នៃការបែងចែក ឬ ត្រូវបានគេនិយាយថា « ច្បាប់ ពិសេសមានអាទិភាពលើច្បាប់ទូទៅ » ។ ក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកជាច្បាប់ទូទៅនៃនីតិឯកជន រីឯច្បាប់ផ្សេងៗទៀតនៃនីតិឯកជនត្រូវបានចាត់ជាច្បាប់ពិសេស ។

## ក. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ស្ថិតនៅក្នុងបរិបទនៃការអភិវឌ្ឍសង្គមជាតិ នៅគ្រប់បណ្តាលប្រទេសទាំងអស់ មិនថាតែប៉ែកអ៊ឺរ៉ុប ឬប៉ែកអាស៊ីនោះទេ ដែលមាននៅក្នុងសកលលោកនេះ ក៏កំពុងតែព្យាយាមការអភិវឌ្ឍឥតឈប់រផង ដែរ ។ ចាប់តាំងពីឆ្នាំ ១៩៩៣ ព្រះរាជាណាចក្រកម្ពុជា បានប្រែខ្លួនចេញពី « សេដ្ឋកិច្ចជាតិ ដែលស្ថិតក្រោមការដឹកនាំរបស់រដ្ឋ » មកអនុវត្តប្រកាន់យកសេដ្ឋកិច្ចទីផ្សារ ។ អ្វីដែលពិសេសនោះការអភិវឌ្ឍន៍ និងការកើនឡើងនៃកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់មួយដែលត្រូវបានគេចាប់ទុកថា ជាប្រទេសមួយដែលមានការអភិវឌ្ឍន៍លឿនរហ័សមួយនៅក្នុងពិភពលោក ជាមួយនឹងល្បឿនកំណើនសេដ្ឋកិច្ចក្នុងរង្វង់អត្រាប្រមានជា ៧% ក្នុងមួយឆ្នាំ ។ ដូចបានឃើញប្រកាស់របស់ក្រសួងយុត្តិធម៌ និងប្រកាសរបស់ធនាគារជាតិ ដែលបានកំណត់អត្រាការប្រាក់ដែលត្រូវបានកម្រិត មកត្រឹម ១៨% ក្នុងមួយឆ្នាំដែលធ្វើឱ្យប្រជាជនក៏ដូចជាស្ថាប័នឯកជនទទួលបាននូវមូលធនសម្រាប់ការរស់នៅ ក៏ដូចជាប្រកបពាណិជ្ជកិច្ចផងដែរ ។ អនុវត្តនូវកាតព្វកិច្ចទទួលបន្ទុករួមមាន រូបវន្តបុគ្គល ស្ថាប័នគារ ( ធនគារពាណិជ្ជ និង ធនាគារឯកទេស ) ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ។

ដូចនេះក្រុមយើងខ្ញុំ និងធ្វើការស្រាវជ្រាវលើទ្រឹស្តីដែលមានស្រាប់ ទិន្នន័យមួយចំណួនព្រមទាំងស្រាយដំណោះចំពោះបញ្ហាដែលការអនុវត្តដោយអនុប្បទានឱ្យមានប្រសិទ្ធិភាព ។

## ខ. ចំណោទបញ្ហា

ស្ថិតក្នុងបរិបទនៃប្រទេសកម្ពុជាដែលកំពុងមានការអភិវឌ្ឍឥតឈប់ឈរ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៅក្នុងជំពូកទី៦ នៃគន្ថីទី៥ បានចែងអំពីប្រាតិភោគដោយអនុប្បទាន ក៏ដូចជាប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានធ្វើអាជីវកម្មប្រាតិភោគដោយអនុប្បទាន ក៏ការអនុវត្តជាក់ស្តែងនៅតែមិនមានតម្លាភាពកើតឡើងជារឿយៗដែលបញ្ហាមានទាំងនេះកើតឡើងដោយសារតែ ការរំញែកអំពីអត្រាការប្រាក់ហួសហេតុពីអត្រាការប្រាក់ដែលបានកំណត់ ។

ហេតុនេះ នៅក្នុងសារណានេះយើងខ្ញុំលើកយកប្រធានបទអំពី ប្រាតិភោគដោយអនុប្បទាន ចំពោះបញ្ហានៅក្នុងសម្មតិកម្មខាងលើនេះបានបង្កើតជាសំនួរ ដូចជា ៖ តើការអនុវត្តច្បាប់ទាក់ទងទៅនឹងប្រាតិភោគដោយអនុប្បទានមានប្រសិទ្ធិភាពដែរឬទេ ? ហើយប្រជាជនយល់ដឹងអំពីប្រាតិភោគដោយអនុប្បទានដែលឬយ៉ងណា ?

## គ. គោលដំណងនៃការសិក្សាស្រាវជ្រាវ

ចំពោះគោលបំណងនៃការសិក្សាចំពោះកិច្ចការស្រាវជ្រាវមួយនេះ គឺដើម្បីធ្វើការស្រាវជ្រាវឱ្យបានស៊ីជម្រៅទៅលើបញ្ហា ក៏ដូចជាកត្តាប៉ះពាល់ដែលទាក់ទិនជាមួយការអនុវត្តប្រាតិភោគដោយអនុប្បទាន ៖

- យល់ដឹងអំពីទិដ្ឋភាពច្បាប់ដែលពាក់ព័ន្ធនឹងប្រាតិភោគដោយអនុប្បទាន យល់ដឹងអំពីនីតិវិធីនៃការធ្វើប្រាតិភោគដោយអនុប្បទាន
- ប្រមូលទិន្នន័យ និងធ្វើការវិភាគទិន្នន័យដែលទាក់ទិននឹងការអនុវត្តប្រាតិភោគដោយអនុប្បទាន ប្រៀបធៀបការអនុវត្តជាក់ស្តែង និងទ្រឹស្តីច្បាប់ដែលពាក់ព័ន្ធ
- យល់ដឹងអំពីផលប៉ះពាល់ដែលកើតឡើងដោយសារការអនុវត្តមិនស្របតាមនីតិវិធីនៃច្បាប់របស់ភាគីពាក់ព័ន្ធ
- ធ្វើការសន្និដ្ឋាន និងផ្តល់អនុសាសន៍ដើម្បីអាចធ្វើការកែតម្រូវចំពោះបញ្ហា
- ចងក្រងទុកជាឯកសារសម្រាប់ជាស្នាដៃ និង ចំណុចផ្តើមនៃការស្រាវជ្រាវបន្តសម្រាប់និស្សិតជំនាន់ក្រោយៗទៀត។

## ឃ. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទដែលបានលើកឡើងនៅក្នុងចំណោទបញ្ហាខាងលើ ដែលមានដែនកំណត់គ្របដណ្តប់ទៅលើទិដ្ឋភាពច្បាប់ ក៏ដូចជាការអនុវត្តច្បាប់ដែលទាក់ទងទៅនឹងប្រាតិភោគដោយអនុប្បទាននៅកម្ពុជា ។ នៅក្នុងសារណានេះ មានវិសាលភាពក្នុងក្របខណ្ឌនៃច្បាប់កម្ពុជា ដែលរួមមានក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា នឹងរួមមាន អនុក្រឹត្យ ឬប្រកាសផ្សេងៗដែលមានការទាក់ទង ពីឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ន ។

## ង. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រប្រមូលឯកសារ គឺបានប្រមូលនៅបណ្ណាល័យនីតិសាស្ត្ររបស់សាលកវិទ្យាល័យភូមិនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងនៅក្នុងគ្រុបបណ្ណាល័យ Telegram ។ កត្តាបន្ទាប់បន្សំ គឺប្រមូលទៅតាមការផ្សព្វផ្សាយបណ្តាលគេហទំព័រច្បាប់មួយចំនួន នឹងអាចពន្យល់ប្រាប់អំពីមូលហេតុដែលទាក់ទងនឹងបញ្ហាខាងលើ ។

## ច. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ មានសារៈសំខាន់ដល់សង្គមជាតិកម្ពុជា ទាំងផ្នែកសេដ្ឋកិច្ច និងសង្គមផងដែរ។ ចំពោះសារសំខាន់ផ្នែកសេដ្ឋកិច្ច ការអនុវត្តប្រាតិភោគដោយអនុប្បទានមានតម្លាភាព ផ្តល់ភាពងាយស្រួលចំពោះការប្រមូលមូលធនសម្រាប់ការចិញ្ចឹមជីវិត ក៏ដូចជាការប្រកបពាណិជ្ជកិច្ច ដែលជាមូលដ្ឋានគ្រឹះ នៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជា។ ចំណែកឯការស្វែងរកដំណោះស្រាយនៅក្នុងកិច្ចការស្រាវជ្រាវ នេះ អាចធ្វើឱ្យអ្នកសិក្សា អ្នកស្រាវជ្រាវ ជាពិសេសនីតិករទទួលបាននូវគំនិតក្នុងការធ្វើបច្ចុប្បន្នភាពចំពោះការបង្កើត

និងអភិវឌ្ឍន៍ច្បាប់ ក៏ដូចជានីតិវិធីដែលទាក់ទិននឹងប្រាតិភោគដោយអនុប្បទាន ដែលចំណុចនេះគឺជាសារៈសំខាន់ដែលមិនអាចខ្វះបានរបស់សារណានេះចំពោះផ្នែកសង្គម ។ ជាមូលដ្ឋានក្នុងការរួមចំណែកក្នុងការចែករំលែក គំនិតស្មារតី ក៏ដូចជាចំណេះដឹងផ្នែកច្បាប់បន្ថែមទៅដលបន្ថែមអំពីសារៈសំខាន់ផ្នែកសេដ្ឋកិច្ច និងសង្គមខាងលើ សារណាបញ្ចប់ការសិក្សានេះក៏អាចក្លាយជាចំណេះដឹងមួយសម្រាប់ប្រជាពលរដ្ឋកម្ពុជាក៏ដូចជាមិត្តអ្នកអានទាំងអស់គ្នាផងដែរ។

## ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងសារណានេះ ត្រូវបានបែងចែកជា ៣ជំពូក ដែលមាន ជំពូកទី១ និយាយអំពី"សញ្ញាណទូទៅប្រាតិភោគដោយអនុប្បទាន" លើកឡើងនូវ ទ្រឹស្តីច្បាប់មួយចំនួន និងទស្សនៈដែលពាក់ព័ន្ធទៅនឹងប្រាតិភោគដោយអនុប្បទាន ដែលរួមមានសញ្ញាណទូទៅ ប្រាតិភោគដោយអនុប្បទាន នីតិវិធីទាក់ទិននឹងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ក៏ដូចជាធ្វើការ រៀបរាប់អំពីស្ថាប័នមានសមត្ថកិច្ចទាក់ទិននឹងប្រាតិភោគដោយអនុប្បទានផងដែរ។ នៅក្នុងជំពូកទី២ និយាយពី" ការអនុវត្តឧបាទេសកម្ម និងការអនុវត្តសិទ្ធិ " បង្ហាញអំពីការភាន់ច្រឡំរវាងប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុរបស់ប្រជាជនកម្ពុជា ព្រមទាំងលើកឡើងដោយសង្ខេបនូវភាពដូចគ្នា និងខុសគ្នានៃទ្រឹស្តីច្បាប់ និងទស្សនៈពាក់ព័ន្ធរវាងប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ ។ ចំណុចចុងក្រោយ ជំពូកទី៣ " ការបញ្ចាំចលនវត្ថុ និង ការអនុវត្តប្រាតិភោគដោយអនុប្បទាន " បង្ហាញអំពីទិន្នន័យនៃការស្រង់មតិ ក៏ដូចជាការបកស្រាយអំពីបញ្ហាប្រឈមនៃប្រាតិភោគដោយអនុប្បទាន ព្រមទាំងធ្វើការពិភាក្សារកដំណោះស្រាយនៃបញ្ហាទៀតផង។

# ជំពូកទី ១

# សញ្ញាណទូទៅ នៃប្រាតិភោគដោយអនុប្បទាន

# ជំពូកទី ១

# សញ្ញាណទូទៅនៃប្រាតិភោគដោយអនុប្បទាន

## ផ្នែកទី១. សញ្ញាណទូទៅ

### កថាភាគទី១. និយមន័យ

ប្រាតិភោគដោយអនុប្បទាន ជាប្រភេទមួយនៃសិទ្ធិប្រាតិភោគប្រត្យក្ស ដែលមានលក្ខណៈជាប្រាតិភោគតាមការព្រមព្រៀង ហើយរបបគតិយុត្តនេះបង្កើតឡើងដើម្បីបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះចលនវត្ថុ មានន័យថាបង្កើតសិទ្ធិប្រាតិភោគដោយឱ្យអ្នកបង្កើតសិទ្ធិប្រាតិភោគនោះបន្តកាន់កាប់ចលនវត្ថុ តាមទម្រង់នៃការផ្ទេរកម្មសិទ្ធិដែលសម្រាប់សិទ្ធិលើការបញ្ចាំចលនវត្ថុអ្នកបង្កើតសិទ្ធិលើការបញ្ចាំមិនត្រូវបាអនុញ្ញាតឱ្យបន្តកាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំនោះឡើយ ប៉ុន្តែប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលស្ថានភាពគិតយុត្តនេះ ។ មួយវិញទៀត ជាលក្ខណៈទ្រឹស្តីស្តីពីប្រាតិភោគដោយអនុប្បទានរបបគតិយុត្តនេះអាចបង្កើតបានលើទ្រព្យក្រៅពីចលនវត្ថុ ដូចជាអចលនវត្ថុជាអាទិ៍ ប៉ុន្តែសម្រាប់ក្រមរដ្ឋប្បវេណីកម្ពុជា បទប្បញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទានមានចំពោះតែចលនវត្ថុ ប៉ុណ្ណោះ ហើយសម្រាប់អចលនវត្ថុវិញ គឺគេបង្កើតរបបគតិយុត្តស្តីពីហ៊ីប៉ូតែកដែលជាសិទ្ធិប្រាតភោគប្រត្យក្សមិនចាំបាច់ផ្ទេរការកាន់កាប់ ។

តើប្រាតិភោគដោយអនុប្បទាន គឺជាអ្វី? ដើម្បីឈានដល់ការបកស្រាយនូវចម្ងល់ខាងលើ ការស្វែងយល់នូវពាក្យថា « ប្រាតិភោគ និងពាក្យថា អនុប្បទាន » គឺជាប្រការសំខាន់ខ្លាំងណាស់នៅក្នុងអត្ថបទនេះ ។

ដោយយោងតាមសទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ព្រមទាំងផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី បានចែង ថា « ប្រាតិភោគ » គឺជាការធានាដល់ម្ចាស់បំណុលក្នុងការប្រមូលតណទាយ្យរបស់ខ្លួនមកវិញ ឬ ជាមធ្យោបាយមួយដើម្បីធានាការសងកាតព្វកិច្ច»[១]។ សរុបមក ប្រាតិភោគ គឺជាមធ្យោបាយដែលកូនបំណុលប្រើប្រាស់វត្ថុសម្រាប់ធ្វើការធានាលើសិទ្ធិលើបំណុលទៅកាន់ម្ចាស់បំណុល ។ ដោយតាមអត្ថន័យនៃ ក្រមរដ្ឋប្បវេណី ប្រាតិភោគត្រូវបែងចែកជាពីរគឺ ប្រាតិភោគប្រត្យក្ស និងប្រាតិភោគបុគ្គល ( បាតិបុគ្គល ឬការធានាដោយបុគ្គល ) ។ ផ្នែកនេះដោយសារតែ ដែនកំណត់នៃប្រធានបទនៃសារណាមានតែ ប្រាតិភោគប្រត្យក្សតែមួយប៉ុណ្ណោះដែលនឹងត្រូវលើកយកមកសិក្សា ។ ចំពោះសិទ្ធិប្រាតិភោគប្រត្យក្សដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីត្រូវបែងចែកជា ៥ គឺ សិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក និង សិទ្ធិប្រាតិភោគដោយអនុប្បទាន[២] ។

អត្ថន័យពាក្យថា អនុប្បទាន វិញគឺជា « ការផ្ទេរសិទ្ធិ ឬ ទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលជាអនុប្បទាយីទៅឲ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក »[៣] ។

---

១. សទ្ទានុក្រមផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ ២០០៧

២. មាត្រា ៧៦៧ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

៣. សទ្ទានុក្រមផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ ២០០៧

ដោយសរុបជារួមមក ពាក្យថាប្រាតិភោគដោយអនុប្បទាន គឺជាកិច្ចធានាមួយសម្រាប់ម្ចាស់បំណុល ដោយផ្អែកលើការផ្ទេរសិទ្ធិ ឬ ទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលអាចជាកូនបំណុល ឬ តតិយជន ទៅឲ្យម្ចាស់បំណុលក្នុងការធានាប្រមូលបំណុលរបស់ខ្លួនត្រឡប់មកវិញ ។ ក្នុងក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ក៏បានចែងនូវនិយមន័យ ប្រាតិភោគដោយអនុប្បទានផងដែរ ដែលសំដៅទៅលើ « ការណ៍ដែលកូនបំណុល ឬ តតិយជន ធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណាត់ ទៅឲ្យម្ចាស់បំណុល ដើម្បីធានាកាតព្វកិច្ច »[៤] ។ ដូចនេះ សិទ្ធិ ឬ ទ្រព្យសម្បត្តិដែលបានសន្មតនៅក្នុងពាក្យ ប្រាតិភោគដោយអនុប្បទានខាងលើ តាមអត្ថន័យក្រមរដ្ឋប្បវេណីសំដៅទៅលើ សិទ្ធិមួយចំនួននៃសិទ្ធិប្រត្យក្សលើចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ។

## កថាភាគទី២. អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន តាមអត្ថន័យដែលមានចែងក្នុងក្រមរដ្ឋប្បវេណី គឺសំដៅទៅលើកូនបំណុល ឬ តតិយជនដែលបានធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួន ទៅកាន់ម្ចាស់បំណុល ហើយដើម្បីធានានូវកាតព្វកិច្ចសងបំណុលរបស់ខ្លួន[៥] ។

## កថាភាគទី៣. ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

ចំណែកឯម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយយោងតាមក្រមរដ្ឋប្បវេណីសំដៅទៅលើម្ចាស់បំណុលដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន បានធ្វើអនុប្បទាននូវចលនវត្ថុទៅឲ្យ ដើម្បីទទួលបាននូវការធានារបស់បំណុល[៦] ។

## កថាភាគទី៤. ការបង្កើតកិច្ចសន្យាសិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ឬតតិយជន ដែលផ្តល់ចលនវត្ថុសម្រាប់ធ្វើប្រាតិភោគដោយអនុប្បទាន[៧] ។ មិនខុសគ្នាអំពីកិច្ចសន្យាពិសេសនោះទេ ប្រាតិភោគដោយអនុប្បទាន ជាទំនាក់ទំនងរវាងសិទ្ធិ និង កាតព្វកិច្ច។ ចំណែកការបង្កើតកិច្ចសន្យាសិទ្ធិប្រាតិភោគដោយអនុប្បទាន ក៏មិនមានភាពខុសគ្នាជាមួយនឹងការបង្កើតកិច្ចសន្យាដែលមានចែងក្នុងគន្ថី ទី៤ ស្តីអំពីកាតព្វកិច្ចនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នោះផងដែរដែលជាគោលការណ៍ និងការបង្កើតកិច្ចសន្យានីមួយៗ ដោយត្រូវគោរពទៅតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

## កថាភាគទី៥. លក្ខខណ្ឌគ្រឹះ

### ក. ការព្រមព្រៀង

សិទ្ធិប្រាតិភោគដោយអនុប្បទានដូចដែលបានអធិប្បាយខាងលើ កិច្ចសន្យាប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងភាគីពីររួមមាន អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន និង

៤. មាត្រា ៨៨៨ .១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៥. មាត្រា ៨៨៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៦.មាត្រា ៨៩០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៧. មាត្រា ៨៨៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន។ ការព្រមព្រៀងនោះទៀតសោត ត្រូវតែកើតអំពីការបង្ហាញឆន្ទៈដែលពុំមានវិការៈដែលរួមមានការភាន់ច្រឡំ ការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត និង អំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ[៨] ។ បន្ថែមពីលើនេះផងដែរការព្រមព្រៀងនេះត្រូវមានអត្ថន័យមិនផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អរបស់សង្គម[៩] ។

ករណីដែលកច្ចិសន្យាប្រាតិភោគដោយអនុប្បទានមានវិការៈក្នុងការបង្ហាញឆន្ទៈ ឬ មានអត្ថន័យផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយឬសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អរបស់សង្គម ឬ សិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានលុបចោលនោះសិទ្ធិបំណុលដែល ត្រូវបានធានាដោយប្រាតិភោគប្រត្យក្សត្រូវបានចាប់ទុកជាមោឃៈដែលជាហេតុធ្វើឲ្យសិទ្ធិភោគដោយអនុប្បទានក៏មិនត្រូវមានអានុភាពដែរ[១០] ។

## ខ. កម្មវត្ថុ

ដើម្បីសិក្សាទៅលើនិយមន័យនៃ ចលនវត្ថុ គឺជា វត្ថុ ឬ ទ្រព្យរបស់ដែលបម្រើបាន ដែលលើកដាក់ ឬ ដឹកនាំពីកន្លែមួយទៅកន្លែងមួយទៀតបាន ។ វត្ថុ គឺសំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង ដែលអាចផ្លាសទីបាន[១១] ។ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានអធិប្បាយអំពីនិយមន័យនៃពាក្យ វត្ថុរួចមក ក្រមនេះក៏កំណត់នូវនិយមន័យថា « ចលនវត្ថុ ជាវត្ថុក្រៅពីអចលនវត្ថុ »[១២] ។ បន្ថែមពីនេះក្រមនេះ ក៏បានកំណត់បន្ថែមថា « បញ្ញត្តិស្តីពីចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន លើកលែងតែមានបញ្ញាត្តិស្តីពីចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន លើកលែងតែមានបញ្ញាត្តិក្នុងច្បាប់ពិសេស »[១៣]។ ដូចនេះអត្ថន័យនៃឃ្លាទាំង ខាងលើអាចបញ្ជាក់បានថា ចលនវត្ថុ សំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ រួមទាំងទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបានផងដែរ ដែលជាទូទៅ « ទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន គឺជាវត្ថុអរូបិយដែលមាន ដូចជា សិទ្ធិ អគ្គិសនី កំដៅ ពន្លឺជាដើម»[១៤] ។

## គ. លក្ខខណ្ឌសមត្ថភាពគូភាគី

លក្ខខណ្ឌសមត្ថភាពគូភាគី មានបីគឺ ៖

៨. មាត្រា ៣៤៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៩. មាត្រា ៣៥៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

១០. មាត្រា ៧៦៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

១១. មាត្រា ១១៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

១២. មាត្រា ១២០ .៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

១៣. មាត្រា ១២០ .៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

១៤. មាត្រា ១២០ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

### ក. សមត្ថភាពអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

សមត្ថភាពក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន របស់អ្នកបង្កើតសិទ្ធិប្រាតិភោគដោយទាន សំដៅទៅលើសមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព[១៥] ។ ជាទូទៅ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានអាចជានីតិបុគ្គល ឬរូបវន្តបុគ្គល។ ដោយសារនីតិបុគ្គល ជាបុគ្គលដែលបង្កើតឡើងដោយច្បាប់ ដូចនេះលក្ខខណ្ឌសមត្ថភាព ពុំចោទជាបញ្ហានេះ កំណត់ឲ្យរូបវន្តបុគ្គលត្រូវតែជា នីតិជន អនីតិជនដែលទទួលបានអត្តាធីនភាព[១៦] អនីតិជនដែលអនុញ្ញាតឲ្យចាត់ចែងទ្រព្យសម្បត្តិដោយអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាល[១៧] អនីតិជនដែលត្រូវបានអនុញ្ញាតឲ្យប្រកបអាជីវកម្ម[១៨] ជនដែលមិនមែនជាជននៅក្រោមអាណាព្យាបាលទូទៅ[១៩] ឬ ជនដែលមិនមែនជាជននៅក្រោមហិតូបត្ថម្ភ[២០] ។

### ខ. សមត្ថភាពម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

បើតាមក្រមរដ្ឋប្បវេណី ចំពោះលក្ខខណ្ឌសមត្ថភាពរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនមានភាពខុសគ្នាទៅនឹងអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានប៉ុន្មាននោះទេ គឺអាចជានីតិបុគ្គល ឬ បុគ្គលដែលមានសមត្ថភាពដូចជា នីតិជន អនីតិជនដែលទទួលបានអត្តាធីនភាព អនីតិជនដែលត្រូវបានអនុញ្ញាតឲ្យប្រកបអាជីវកម្ម ។ ប៉ុន្តែប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានបញ្ជាក់ថា ដើម្បីទទួលបានសមត្ថភាពពេញលេញក្នុងការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវតែជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា[២១] ។ បន្ទាប់មកនីតិបុគ្គល ខាងលើត្រូវធ្វើការចុះបញ្ជីប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានបន្ថែមទៀត ដោយការការចុះបញ្ជី ត្រូវធ្វើឡើងនៅឯនាយដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលប្រកបអាជីវកម្មខ្នាតមធ្យម និងធំ ឬ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីខេត្តចំពោះអាជីវកម្មខ្នាតតូច។ បន្ថែមពីនេះ អាជីវកម្មទទួលប្រាតិ ភោគដោយអនុប្បទានមានដើមទុនចាប់ពី ២០ លានរៀលឡើងទៅ និងត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម ចំនួន ១០% នៃដើមទុនផងដែរ[២២] ។

---

១៥. មាត្រា ១៤ និង មាត្រា ១៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

១៦. មាត្រា ២១ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

១៧. មាត្រា ១៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

១៨. មាត្រា ២០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

១៩.មាត្រា ២៤ - មាត្រា ២៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

២០. មាត្រា ២៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

២១. ប្រការ៦ និងប្រការ៧ សេចក្តីប្រកាសអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន , ឆ្នាំ ២០១៧

២២. ប្រការ៦ ដល់ ប្រការ៩ សេចក្តីប្រកាសអាជីវកម្មបញ្ចាំ និង ប្រតិភោគដោយអនុប្បទាន, ឆ្នាំ ២០១៧

ក៏ប៉ុន្តែសេចក្តីប្រកាសនេះពុំបានចែងអំពីការ មិនគោរពលក្ខខណ្ឌសមត្ថភាព ដែលអាចធ្វើឲ្យលុបចោល ឬ មោឃភាពនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទាននោះទេ។ ប៉ុន្តែករណីដែលម្ចាស់សិទ្ធិ ប្រាតិភោគដោយអនុប្បទាន មិនគោរពលក្ខខណ្ឌសមត្ថភាពនេះ នឹងត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៥,០០០,០០០ រៀល ចំពោះអាជីវកម្មខ្នាតតូច និង ១០,០០០,០០០ រៀល ចំពោះអាជីវកម្មខ្នាតមធ្យម និងធំ ដែលកំណត់នៅក្នុងប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន (ទំហំដើមទុនអាជីវកម្មមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២)[២៣]។

**គ. កម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន**

ដូចដែលបានរៀបរាប់ខាងលើរួចមកហើយ កម្មវត្ថុនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទានគឺ ការធ្វើអនុប្បទាននូវចលនវត្ថុ។ ការធ្វើអនុប្បទាននូវអចលវត្ថុ ក្នុងន័យនេះសំដៅដល់ការផ្ទេរជាបណ្តោះអាសន្ននូវកម្មសិទ្ធិនៃចលនវត្ថុ ទៅកាន់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ដើម្បីបង្កើតជាសិទ្ធិប្រាតិភោគដោយអនុប្បទាន ហើយកម្មសិទ្ធិនោះនឹងត្រូវផ្ទេរត្រឡប់ទៅកាន់កូនបំណុលវិញដោយការសង ឬអនុវត្តកាតព្វកិច្ចរួចចំពោះចលនវត្ថុនេះផងដែរសំដៅទៅលើចលនវត្ថុទូទៅ និងទ្រព្យអរូបិយផងដែរ។

## កថាភាគទី៦. លក្ខខណ្ឌទម្រង់

ចំពោះលក្ខខណ្ឌទម្រង់វិញក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ពុំបញ្ជាក់ថាតើកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវធ្វើឡើងដោយផ្ទាល់ ជាលាយលក្ខណ៍អក្សរ ជាលិខិតឯកជន ឬ លិខិតយថាភូតនោះទេ។ ប៉ុន្តែប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន ឆ្នាំ២០១៧ បានចែងអំពីទម្រង់នៃកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយតម្រូវឲ្យធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានការចុះហត្ថលេខា ឬ ស្នាមមេដៃទទួលស្គាល់ត្រឹមត្រូវរវាងគូភាគីនៃកិច្ចសន្យា តាមទម្រង់នៃកិច្ចសន្យាត្រូវផ្តល់ជូនដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវបញ្ជាក់ឲ្យច្បាស់អំពីព័ត៌មានអប្បរមា លក្ខខណ្ឌរយៈពេលនៃកិច្ចសន្យាមិនលើសពី ៤ខែប៉ុន្តែអាចបន្តសុពលភាពសារជាថ្មីបាន និងកាតព្វកិច្ចដែលគូភាគីបានព្រមព្រៀង។

## កថាភាគទី៧. អានុភាពតតាំង

ចំពោះការតតាំងជាមួយតតិយជន "ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធប្រាតិភោគដោយអនុប្បទាននោះ ចំពោះតិតយជនក្រៅពីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបានទេប្រសិន បើមិនបានទទួលការផ្ទេរកាន់កាប់វត្ថុដែលជាកម្មវត្ថុនោះទេ[២៤] ។

---

២៣. ប្រការ៦ ដល់ ប្រការ៩ សេចក្តីប្រកាសអាជីវកម្មបញ្ចាំ និង ប្រតិភោគដោយអនុប្បទាន, ឆ្នាំ២០១៧

២៤. មាត្រា ៨៩០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ការផ្ទេរការកាន់កាប់នេះអាចត្រូវធ្វើឡើងតាម ៤ ប្រភេទ ដែលរួមមាន៖

- ការផ្ទេរការកាន់កាប់ដោយការប្រគល់ជាក់ស្ដែង
- ការផ្ទេរការកាន់កាប់ដោយការព្រមព្រៀង ឬ ការប្ដូរលក្ខណៈនៃការកាន់កាប់
- ការផ្ទេរការកាន់កាប់ដោយការ ប្រគល់ដោយសង្ខេប
- ការផ្ទេរការកាន់កាប់ដោយបញ្ជា[២៥] ។

## ក. ការផ្ទេរការកាន់កាប់ដោយជាក់ស្ដែង

ការប្រគល់ដោយជាក់ស្ដែង គឺជាការផ្ទេរកម្មសិទ្ធិនៃវត្ថុដែលបានកាន់កាប់ ដោយការប្រគល់វត្ថុពីអនុប្បទានយីទៅកាន់អនុប្បទាននិកដោយផ្ទាល់[២៦] ឬ ជាការប្រគល់ដោយផ្ទាល់ដៃពីកូនបំណុល ទៅឲ្យម្ចាស់បំណុលកាន់កាប់តាមការជាក់ស្ដែង។

ឧទាហរណ៍ នៅក្នុងកិច្ចសន្យាមួយបង្កើតប្រាតិភោគដោយអនុប្បទាន ដែលមានកម្មវត្ថុជាម៉ូតូ។ ម៉ូតូត្រូវបានផ្ទេរពីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានទៅឲ្យម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ។ តាមរយៈការផ្ទេរនេះ ដោយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន នឹងត្រូវបាត់បង់នូវការកាន់កាប់របស់ខ្លួន ហើយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានទទួលបាននូវការកាន់កាប់របស់នោះ ។

## ខ. ការផ្ទេរការកាន់កាប់ដោយប្រយោល

« ការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីតែប៉ុណ្ណោះ ប៉ុន្តែគ្មានការប្រគល់ដោយជាក់ស្ដែងនោះទេ។ ក្នុងករណីនេះ អនុប្បទានិកនៃការកាន់កាប់ត្រូវទទួលបានការកាន់កាប់ដោយប្រយោល តាមរយៈអនុប្បទាយី។ ការកាន់កាប់បែបនេះហៅថា ការកាន់កាប់ដោយការព្រមព្រៀង ឬ ការប្ដូរលក្ខណៈនៃការកាន់កាប់ »[២៧]។ នៅក្នុងការផ្ទេរនេះមានការព្រមព្រៀង ប៉ុន្តែគ្មានការផ្ទេរវត្ថុជាក់ស្ដែងនោះទេ។

## គ. ការផ្ទេរការកាន់កាប់ដោយសង្ខេប

ដោយសារហេតុនេះអនុទាយី នៃការកាន់កាប់ត្រូវបាត់បង់ការកាន់កាប់ដោយប្រយោលដែលខ្លួនធ្លាប់មាន តាមរយៈអ្នកក្ដាប់ទុកវត្ថុកាន់កាប់។ ការផ្ទេរការកាន់កាប់បែបនេះហៅថា ការប្រគល់ដោយសង្ខេប »[២៨]។ ក្នុងទម្រង់នៃការផ្ទេរការកាន់កាប់នេះ ការប្រគល់វត្ថុ គឺមិនត្រូវបានគេធ្វើឡើងតាមការជាក់ស្ដែងនោះទេ ដោយសារអនុប្បទានិក គឺជាអ្នកកាន់កាប់ដោយចំពោះរួចទៅហើយ ។

---

២៥. មាត្រា ២២៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

២៦. មាត្រា ២២៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

២៧. មាត្រា ២២៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

២៨. មាត្រា២២៩ .៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ឃ. ការផ្ទេរការកាន់កាប់ដោយបញ្ជា

«អ្នកកាន់កាប់ដោយប្រយោលដែលជាអនុប្បទាយី តាមរយៈអ្នកដទៃអាចផ្ទេរការកាន់កាប់ ឲ្យតតិយជនដែលជាអនុប្បទានិកបាន ដោយការព្រមព្រៀងជាមួយនឹងតតិយជនដែលជាអនុប្បទានិក និងដោយការជូនដំណឹងអំពីហេតុនោះទៅឲ្យអ្នកកាន់កាប់ដោយចំពោះ។ ការផ្ទេរការកាន់កាប់បែបនេះ ហៅថាការកាន់កាប់ដោយបញ្ជា»[២៩] ។ នៅក្នុងទម្រង់នៃការផ្ទេរការកាន់កាប់នេះ ការប្រគល់មិនត្រូវបានគេធ្វើឡើងតាមការជាក់ស្តែងទេ។ បន្ទាប់ពីមានការព្រមព្រៀងរវាងអនុប្បទាយី និងអនុប្បទានិក និងការជូនដំណឹងអំពីការផ្ទេរទៅអ្នកកាន់កាប់ដោយចំពោះ ដើម្បីឲ្យអ្នកកាន់កាប់ដោយចំពោះនោះធ្វើការប្រគល់វត្ថុទៅឲ្យអនុប្បទានិក។

ឧទាហរណ៍ ៖ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន បានផ្ញើរឡានទៅនឹងលោក ក ។ ក្រោយមកអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន និងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានព្រមព្រៀងបង្កើតកិច្ចសន្យាសិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលមានកម្មវត្ថុជាឡានខាងលើ និងបានជូនដំណឹងទៅកាន់លោក ក ។ ដូចនេះតាមរយៈការផ្ទេរការកាន់កាប់ដោយបញ្ជា អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំចាំបាច់ធ្វើការប្រគល់ឡានទៅកាន់ម្ចាស់សិទ្ធិប្រាតិភោគដោយទានដោយផ្ទាល់នោះទេគ្រាន់តែបញ្ជាឲ្យបុគ្គល ក ប្រគល់ឡានទៅឲ្យម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានតែប៉ុណ្ណោះ។

## ផ្នែកទី២. អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ពេលដែលប្រាតិភោគដោយអនុប្បទានបានបង្កើតនាំឱ្យសិទ្ធិប្រតិភោគដោយអនុប្បទានមានអានុភាពលើវត្ថុ វត្ថុភ្ជាប់ និងផ្នែកនៃវត្ថុដែលជា កម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដែលមានកំណត់នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន និងប្រសិនបើម្ចាស់

សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានទទួលបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុនោះដោយ ចំពោះ ឬបានទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុ ផលដែលកើតពីវត្ថុនោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមានសិទ្ធិទទួលផលនោះដោយមិនចាំបាច់យកផលនោះមកកានត់សិទ្ធិលើបំណុលឡើយ ដោយនៅក្នុងករណីនេះម្ចាស់បំណុលមិនអាចទាមទារការប្រាក់បាននោះទេ លើកលែងតែមានកំណត់ផ្សេងនៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន និង ប្រសិនបើអ្នកបង្កើតសិទ្ធិនេះ ( កូនបំណុល ) ឬតតិយជនដែលបានទទួលបញ្ជាពីអញ្ញនកបង្កើតសិទ្ធិនេះ កាន់កាប់វត្ថុដែលជាកម្មវត្ថុនោះដោយចំពោះស្ថានភាពខាងលើនេះមិនអាចអនុវត្តបានឡើយ ។

មួយវិញទៀត ជាគោលការណ៍សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវ បានបង្កើតឡើងដើម្បីធានានូវប្រាក់ដើមការប្រាក់ ប្រាក់ធានាសងក្នុងករណី មិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្សដោយអនុ ប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុ និងសំណង់នៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ លើកលែងតែមានកំណត់ផ្សេងនៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិនោះ

២៩. មាត្រា ២២៤ .៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ហើយក្នុងករណី ដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុ នាំឱ្យម្ចាស់បំណុលមានសិទ្ធិឃាត់ទុកវត្ថុ និងទទួលសំណងដោយអាទិភាព ប៉ុន្តែមានករណីត្រូវគ្រប់គ្រងដោយសុចរិតដោយអាចប្រើប្រាស់បានក្នុងកម្រិតគ្រប់គ្រងនិងថែរក្សាបើមិនដូច្នេះនោះទេ កម្មសិទ្ធិករមានសិទ្ធិទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុមកវិញ ។

លើសពីនេះទៅទៀត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាច អះអាងអំពីសិទ្ធិរបស់ខ្លួនបាន ឬមិនបានក្នុងករណីដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបានចាត់ចែងវត្ថុដែលជាកម្មវត្ថុ មានន័យថា ជាគោលការណ៍តតិយជនដែលបានធ្វើលទ្ធកម្មនូវការកាន់កាប់វត្ថុដែលសុចរិត និង គ្មានកំហុសអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនតតាំងជាមួយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន និងនៅក្នុងករណីដែលចលនវត្ថុមួយត្រូវបានផ្តល់ជា ប្រាតិភោគដោយអនុប្បទានលើសពីមួយ។ បុគ្គលដែលបានធ្វើលទ្ធកម្មនូវប្រតិភោគដោយអនុប្បទាននៅពេលក្រោយមិនអាចតតាំងសិទ្ធិរបស់ខ្លួន ។

ចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ប្រសិនបើមិនបានបំពេញលក្ខខណ្ឌនៃលទ្ធកម្មដោយសុចរិតចំពោះចលនវត្ថុនោះទេ និងប្រសិនបើបានបំពេញលក្ខខណ្ឌនាំឱ្យអ្នកធ្វើលទ្ធកម្មទីមួយមានឋានៈទាបជាងអ្នកធ្វើលទ្ធកម្មទីពីរប៉ុន្តែ ប្រសិនបើតតិយជនបានរឹបអូសវត្ថុម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចបណ្តឹងតវ៉ាបាន ។ ផ្ទុយទៅវិញ សម្រាប់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលបានកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ បានធ្វើអនុប្បទាននូវវត្ថុនោះទៅតតិយជន ឬបានបង្កើតសិទ្ធិប្រាតិភោគលើវត្ថុនោះសម្រាប់តតិយជន ហើយតតិយជនបានបំពេញគ្រប់លក្ខខណ្ឌនាំឱ្យតតិយជនអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនតាំងចំពោះអ្នកបង្កើតដោយរាប់បញ្ចូលទាំងអ្នកដទៃ ដែលទទួលបញ្ញោពីម្ចាស់សិទ្ធិប្រាតិភោគដែលបានកាន់កាប់ចំពោះនូវវត្ថុដែលជាកម្មវត្ថុ ។

## កថាភាគទី១. ទំហំនៃអានុភាពរបស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

«សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុជាកម្មវត្ថុ និងជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។ អានុភាពនេះ ក៏មានលើវត្ថុដែលត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ »[៣០]។

ចំពោះវត្ថុដែលភ្ជាប់នឹងវត្ថុ និងវត្ថុដែលជាផ្នែកមួយនៃវត្ថុ សំដៅទៅលើមាសភាគនៃវត្ថុ[៣១] ឬ វត្ថុចំណុះរបស់វត្ថុចម្បង[៣២] ។ ដូចនេះ តាមបញ្ញត្តិនៃមាត្រាខាងលើ មានអត្ថន័យជារួមថា សិទ្ធិប្រតិភោគ ដោយអនុប្បទាន មានអានុភាពទាំងទៅលើវត្ថុដែលរួមទាំងសមាសភាគនៃវត្ថុ និងវត្ថុចំណុះនៃវត្ថុចម្បង ដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ទោះបីជាមុន ឬក្រោយបង្កើតសិទ្ធិប្រាតិភោគដោយ អនុប្បទាន។

៣០. មាត្រា ៨៩១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៣១. មាត្រា ១២១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៣២. មាត្រា ១២៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ថ្វីបើកថាខណ្ឌទី១ វាក្យខណ្ឌទី១ មាត្រា ៨៩១ កំណត់អំពីអានុភាពខាលើក៏ពិតមែន ប៉ុន្តែ ម្ចាស់សិទ្ធិប្រាតិភោគដោយអប្បទាន និងអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានអាចធ្វើការកំណត់ សន្យាពិសេសផ្សេងទៀតបានដោយចែងការកំណត់នោះនៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយ អនុប្បទានបាន[៣៣] ។

**កថាភាគទី២. អានុភាពចំពោះផល**

ក្នុងករណីដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានបញ្ញាពី អ្នកបង្កើតនោះឲ្យកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ អានុភាពនៃសិទ្ធិប្រតិភោគដោយអនុប្បទាន នឹងពុំមានចំពោះផលនោះឡើយ ។ ប៉ុន្តែអានុភាពចំពោះផលនេះ នឹងត្រូវកើតឡើងនៅក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានទាមទារឲ្យប្រគល់វត្ថុដែលជាកម្មវត្ថុ ដើម្បីធ្វើការចាត់ចែងប្តូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ។

ផ្ទុយមកវិញ ករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលទទួលបានការបញ្ញាពីម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាននោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះអានុភាពចំពោះផលនឹងត្រូវអនុវត្តដូចគ្នា ទៅនឹងសិទ្ធិទទួលការសងពីផលដោយមានអាទិភាពចំពោះ សិទ្ធិលើការបញ្ចាំ[៣៤] ដែលមានន័យថា ផលដែលបានមកពីកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាននេះ ត្រូវយកមកកាត់សិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយមានអាទិភាពជាង ម្ចាស់បំណុលដទៃទៀតបាន។ ចំពោះវិធីនៃការកាត់សិទ្ធិលើបំណុលនោះ គឺត្រូវកាត់ការប្រាក់ជាមុនសិន ហើយប្រសិនបើមានសល់ទើបយកទៅកាត់នឹងប្រាក់ដើម។

៣៣. មាត្រា ៨៩១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៣៤. មាត្រា ៨២២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី២

# ការអនុវត្តឧបាទេសកម្ម និងការអនុវត្តសិទ្ធិ

# ជំពូកទី២

# ការអនុវត្តឧបាទេសកម្ម និងការអនុវត្តសិទ្ធិ

## ផ្នែកទី១. ឧបាទេសកម្ម

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចធ្វើឧបាទេសកម្មចំពោះប្រាក់ ឬ វត្ថុផ្សេងទៀតដែលត្រូវទទួលដោយការលក់ ការបាត់បង់ ឬ ការខូតខាតនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ។

មានករណីលើកលែងចំនួន ពីរ ចំពោះបញ្ញត្តិនេះ :

ទី ១ គឺម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចធ្វើឧបាទេសកម្មបានទេ ក្រោយពេលដែលប្រាក់ ឬ វត្ថុផ្សេងទៀតនោះត្រូវបានសង ឬ ប្រគល់ទៅឱ្យអ្នកបង្កើតរួចហើយ ។

ទី ២ ក្នុងករណីចលនវត្ថុផ្គុំគ្នា ហើយចលនវត្ថុនោះត្រូវមានគម្រោង លក់តាំងពីដំបូងនូវចលនវត្ថុនេះទៅឱ្យអ្នកផ្សេងទៀត ម្ចាស់សិទ្ធិប្រាតិភោគ ដោយអនុប្បទានមិនអាចធ្វើឧបាទេសបានទេ ។

ឧទាហរណ៍ទី ១ ៖ ក បានយកទំនិញរបស់ខ្លួន ទៅបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានជាមួយ ខ ។ ក្រោយមក ក បានលក់សាងទំនិញទាំង អស់នោះទៅឱ្យ គ ។

ក្នុងករណីនោះ អាចធ្វើឧបាទេសកម្មលើប្រាក់ដែលជាថ្លៃសាង ទំនិញនោះពី គ បាន ។ ប៉ុន្តែក្នុងករណីដែលប្រាក់នោះត្រូវប្រគល់ទៅឱ្យ ក ហើយនោះ គឺ ខ មិនអាចធ្វើឧបាទេសកម្មបានទេ ។

ឧទាហរណ៍ទី ២ បានយកទំនិញរបស់ខ្លួននៅក្នុងឃ្លាំងជា ចលនវត្ថុផ្គុំគ្នាដែលគ្រោងនឹងលក់ ទៅបង្កើតប្រាតិភោគដោយអនុប្បទានជាមួយ ខ ។ នៅក្នុងករណីនេះ មិនថាទំនិញដែលទើបនឹងនាំចូល ឬ ទំនិញដែលបានលក់ចេញនោះទេ គឺទំនិញដែលមាននៅក្នុងឃ្លាំងនាពេលនេះត្រូវបានចាត់ទុកថាជាចលនវត្ថុផ្គុំគ្នា ។ ហេតុដូច្នេះ អានុភាពនៃប្រាតិភោគដោយមិនមានចំពោះវត្ថុដែលត្រូវបានយកចេញនោះទេ ។ ក្នុងករណីនេះ ខ មិនអាចធ្វើឧបាទេសកម្មលើទឹកប្រាក់ដែលបានពីការលក់ទំនិញនោះទេ ។

### កថាភាគទី១. ឧបាទេសកម្មលើចលនវត្ថុដែលមិនមែនជាចលនវត្ថុផ្គុំគ្នា

តាមសទន្ទានុក្រមពាក្យច្បាប់ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីកំណត់ឲ្យនិយមន័យ "ឧបាទេសកម្ម ជាឋានៈមួយដែលបុគ្គលម្នាក់ទទួលជំនួសបុគ្គលណាម្នាក់តាមផ្លូវច្បាប់ (ឧបាទេសកម្ម អាចសំដៅទៅលើវត្ថុផងដែរ)។

ចំពោះឧបាទេសកម្មក្នុងន័យប្រាតិភោគដោយអនុប្បទាន សំដៅលើការណ៍ដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានសិទ្ធិត្រូវទទួលដោយសារតែការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុ[៣៥] ។ប៉ុន្តែ

៣៥. មាត្រា ៨៩៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ម្ចាស់សិទ្ធប្រាតិភោគដោយអនុប្បាទានពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ទៅឲ្យអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។

ឧទាហរណ៍ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន និង ម្ចាស់សិទ្ធិប្រាតិភោគដោយ អនុប្បទាន បានព្រមព្រៀងបង្កើតកិច្ចសន្យាសិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលមានចលនវត្ថុជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ដោយការផ្ទេរការកាន់កាប់ដោយការប្តុលក្ខណៈនៃការកាន់កាប់ ( អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាននៅតែបន្តកាន់កាប់វត្ថុ ) ។ ក្រោយមកអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបានយកចលនវត្ថុនោះទៅលក់ឲ្យអតតិយជន ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចធ្វើឧបាទេសកម្មលើប្រាក់ដែលលក់ចលនវត្ថុនោះបាន ។ ប៉ុន្តែ ប្រសិនបើប្រាក់លក់នោះត្រូវបានប្រគល់ទៅឲ្យអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានរួចរាល់ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចធ្វើឧបាទេសកម្មបាននោះទេ[៣៦] ។

## កថាភាគទី២. ឧបាទេសកម្មលើចលនវត្ថុផ្គុំ

នៅក្នុងករណីដែលចលនវត្ថុផ្គុំគ្នា អ្នកធានាដោយវត្ថុអាចចាត់ចែងវត្ថុ ដែលមានគម្រោងនឹងលក់បានដោយសេរី[៣៧] ។

ឧទាហរណ៍ ៖ នៅក្នុងករណី ក បានជំពាក់បំណុល ខ ក បានធ្វើអនុប្បទានទំនិញក្នុងហាងដែលជាចលនវត្ថុផ្គុំគ្នាជាប្រាតិភោគដោយ ក នៅបន្តកាន់កាប់ដោយចំពោះបន្ទាប់មក ក បានលក់ទំនិញដែលមានគម្រោងនឹងលក់តាំងពីដំបូងនោះ ទៅឱ្យ គ ដែលបានដឹងអំពីការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានដោយ ក ។ នៅក្នុងករណីនេះទោះបីជា គ បានដឹងអំពី អត្ថិភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សរបស់ ខ ក៏ដោយ ក៏ គ អាចធ្វើលទ្ធកម្មកម្ម សិទ្ធិនៃទំនិញបានដែរ ។ នេះក៏ព្រោះតែទំនិញទាំងនោះ នឹងលែងជាផ្នែកនៃ ចលនវត្ថុផ្គុំគ្នា នៅពេលដែលនៅក្រៅទំហំនៃចលនវត្ថុផ្គុំគ្នា ។

ចំពោះបើកថាខណ្ឌទី២ នៃមាត្រា ៨៩៣ នៃក្រមរដ្ឋប្បវេណី ចែងកំណត់ដូចខាងលើក្តីក្នុងករណី ចលនវត្ថុផ្គុំគ្នា (ចលនវត្ថុច្រើន ដែលត្រូវបានកំណត់ទំហំតាមមាត្រាដ្ឋាន ដូចជាប្រភេទ ឬ កន្លែងស្ថិត នៅនៃចលនវត្ថុអាចយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកជាចលនវត្ថុផ្គុំគ្នាតែមួយបាន[៣៨]) ហើយចលនវត្ថុនោះត្រូវមានគម្រោងលក់តាំងពីដំបូង ទៅឲ្យតតិយជនម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចធ្វើឧបាទេសកម្មបាននោះទេ។

ឧទាហរណ៍ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន បានយកទំនិញនៅក្នុងឃ្លាំងដែល ជាចលនវត្ថុប្រមូលផ្គុំគ្នាដែលត្រូវបានគ្រោងលក់ ទៅបង្កើតប្រាតិភោគដោយអនុប្បទានជាមួយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន។ នៅក្នុងករណីនេះ វត្ថុដែលចេញចូលក្នុងឃ្លាំង (កន្លែងស្ថិតនៅនៃ ចលនវត្ថុផ្គុំគ្នា) ត្រូវ

៣៦.មាត្រា ៨៩៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៣៧. មាត្រា ៨៨៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៣៨. មាត្រា ៨៩៤ .២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បានចាត់ទុកជា ចលនវត្ថុផ្គុំគ្នា។ ហេតុដូចនេះ អានុភាពនៃប្រាតិភោគមានតែចំពោះវត្ថុផ្គុំគ្នា ប៉ុន្តែមិនមានចំពោះវត្ថុដែលយកចេញបាននោះទេ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន មិនអាចធ្វើឧបាទេសកម្មលើទឹកប្រាក់ដែលបានពីការលក់ទំនិញនោះទេ។

## កថាភាគទី៣. ការចាត់ចែងវត្ថុដោយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

ជាការពិតណាស់ ចលនវត្ថុមួយចំនួនមានការលំបាកក្នុងការកំណត់នូវអត្តសញ្ញាណនៃម្ចាស់ទ្រព្យណាស់។ ដូចនេះជាទូទៅ ការកំណត់នូវអត្តសញ្ញាណនៃម្ចាស់ទ្រព្យតែងតែកំណត់កម្មសិទ្ធិលើចលនវត្ថុដោយការកាន់កាប់ដោយចំពោះ។ ហេតុនេះហើយមាត្រា ១៩៣ ក្រមរដ្ឋប្បវេណីកំណត់ចែងអំពីលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុទោះបីជាអនុប្បទាយីមិនមានកម្មសិទ្ធលើវត្ថុនោះក៏ដោយ។

នៅក្នុងកិច្ចសន្យា បង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន " បើអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ នៃប្រាតិភោគដោយអនុប្បទាននៅក្រោយពេលបង្កើតសិទ្ធិនោះ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះទៅតតិយជន ប្រសិនបើតតិយជនបានបំពេញគ្រប់លក្ខខណ្ឌ ដែលបានកំណត់នៅក្នុងមាត្រា ១៩៣ ( លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ៖ លទ្ធកម្មដោយ សុចរិត និងគ្មានកំហុស ) នៃក្រមនេះ តតិយជនអាចយកសិទ្ធិរបស់ខ្លួន ទៅតតាំងចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន"[៣៩] ។

ចំពោះចលនវត្ថុផ្គុំគ្នាវិញ បើចលនវត្ថុនោះត្រូវមានគម្រោងលក់តាំងពីដំបូង ហើយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាននៅបន្តកាន់កាប់ដោយចំពោះនូវចលនវត្ថុផ្គុំគ្នាដែលជាកម្មវត្ថុ នៃប្រាតិភោគដោយអនុប្បទាននោះនៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ប្រសិនបើអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបានលក់វត្ថុដែលជាកម្មវត្ថុនោះទៅឲ្យតតិយជន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានពុំអាចមានសិទ្ធិប្រាតិភោគនោះទៅតតាំងក្នុងមាត្រា ១៩៣ ( លទ្ធកម្មដោយសុចរិត នូវកម្មសិទ្ធិលើចលនវត្ថុក៏ដោយ ) [៤០]។

ចំពោះប្រការខាងលើទាំងពីរ សម្រាប់ចលនវត្ថុទូទៅ និងចលនវត្ថុផ្គុំគ្នា ក៏ត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដទៃទទួលការបញ្ជាពីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន បន្តកាន់កាប់ដោយ ចំពោះករណីដែលអ្នកដទៃទទួលការបញ្ជាពីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន បន្តកាន់កាប់ដោយ ចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាននៅក្រោយពេលបង្កើតសិទ្ធិនោះ ហើយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះសិទ្ធិនោះ ហើយអ្នកទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន[៤១] ។

---

៣៩. មាត្រា ៨៩៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៤០. មាត្រា ៨៩៤ .២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៤១. មាត្រា ៨៩៤ .៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទាក់ទងនឹងអានុភាពតតាំងចំពោះការចាត់ចែងវត្ថុដែលជាកម្មវត្ថុ ដោយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាននេះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចនឹងទទួលរងនូវផលវិបាកផ្សេងៗ ប្រសិនបើមិនបានទទួលបាននូវការកាន់កាប់ដោយចំពោះទៅលើវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន។ តាមការអធិប្បាយខាងលើការផ្ទេរការកាន់កាប់ពីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានទៅកាន់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានទានមាន ៤ប្រភេទ គឺការប្រគល់ជាក់ស្តែងការព្រមព្រៀង ឬការប្តូរលក្ខណៈនៃការកាន់កាប់ ការប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា។ ក្នុងចំពោះការផ្ទេរការកាន់កាប់ទាំង ៤ប្រភេទ មានតែការប្រគល់ជាក់ស្តែង និងការប្រគល់ដោយសង្ខេបដែលអាចឲ្យម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ទទួលបាននូវការកាន់កាប់ដោយចំពោះបានដោយផ្ទាល់។ ចំពោះការផ្ទេរការកាន់កាប់ដោយបញ្ជា អាចបង្កើតនូវចន្លោះប្រហោងដែលឲ្យអ្នកកាន់កាប់ដោយចំពោះ អាចធ្វើលទ្ធកម្មសិទ្ធិលើចលនវត្ថុទៅឲ្យតតិយជនបានផងដែរ។ ចំណែកការផ្ទេរដោយការព្រមព្រៀង ឬ ការប្តូរលក្ខណៈនៃការកាន់កាប់អាចផ្តល់ហានិភ័យទៅដល់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបំផុត ព្រោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានគ្រាន់តែជាអ្នកកាន់កាប់ដោយប្រយោល ខណៈអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ជាអ្នកកាន់កាប់ដោយផ្ទាល់។

## **កថាភាគទី៤. ការចាត់ចែងវត្ថុដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន**

ទាក់ទិននឹងការចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានវិញក្រមរដ្ឋប្បវេណីកំណត់ចែងក្នុងមាត្រា ៨៩៧ កថាខណ្ឌទី១ ថា "បើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលកាន់កាប់ដោយចំពោះនូវវត្ថុជាកម្មវត្ថុ នៃប្រាតិភោគដោយអនុប្បទាននោះ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬបានបង្កើតសិទ្ធិប្រាតិភោគប្រត្រក្សលើវត្ថុនោះដើម្បីតតិយជនប្រសិនបើតតិយជននោះបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិ លើចលនវត្ថុដោយសុចរិតគ្មានកំហុស) នៃក្រមរដ្ឋប្បវេណីនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួន ទៅតតាំងចំពោះអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបាន"។

"បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដទៃបានទទួលការបញ្ជាពីម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ដើម្បីកាន់កាប់ដោយចំពោះនូវវត្ថុ ដែលជាកម្មវត្ថុ។

ហើយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាននោះបានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះ ទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិប្រត្រក្សលើវត្ថុនោះតតិយជន"[៤២]។

ប៉ុន្តែ ចំពោះប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុវិញកំណត់ចែងអំពីកាតព្វកិច្ចរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន (អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មប្រាតិភោគដោយ អនុប្បទាន) ដែលមាន

៤២. មាត្រា ៨៩៧ .២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

កាតព្វកិច្ចរក្សាទុកទ្រព្យប្រាតិភោគដោយអនុប្បទាននៅកន្លែងដែលមានសុវត្ថិភាព និងមិនយកទ្រព្យនោះទៅប្រើប្រាស់ឡើយ[៤៣] ។ បន្ថែមពីនេះទៀត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្ប ទាន ( អ្នកកាន់អាជ្ញបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទាន ) ពុំ មានសិទ្ធិលក់ ផ្ទេរ ឬប្រគល់សិទ្ធិកាន់កាប់ទ្រព្យប្រាតិភោគដោយអនុប្បទាន ឲ្យទៅតតិយជនក្នុងអំឡុងពេលដែលទ្រព្យប្រាតិភោគដោយអនុប្បទាននោះ កំពុងជាប់កិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយ អនុប្បទានឡើយ ប្រសិនពុំមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន[៤៤] ។ ថ្វីបើប្រកាសនេះ មានបញ្ជាក់អំពីចំណុចនេះក៏ពិតមែន ប៉ុន្តែក្នុងប្រកាសនេះក៏ពុំកំណត់បញ្ជាក់អំពីទោសទណ្ឌដែលនឹងត្រូវបានទទួលនោះទេ។

### កថាភាគទី៥. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

ជាទូទៅ កាតព្វកិច្ចធានាត្រូវរាប់បញ្ចូលទាំងការប្រាក់ ប្រាក់ធានា សំណងក្នុងករណីបំពានកិច្ចសន្យា និង សំណងការខូចខាត ដែលទាក់ទងនឹង កាតព្វកិច្ចចម្បង និង អ្វីដែលកើតឡើងបន្ទាប់បន្សំពីកាតព្វកិច្ចចម្បងនោះ ដោយគ្មានការសន្យាពិសេសណាមួយ ។ លើសពីនេះ កិច្ចសន្យាធានាអាចកំណត់ពីចំនួនទឹកប្រាក់ធានាសំណង ក្នុងករណីបំពានកិច្ចសន្យាប្រាក់សំណងការខូចខាតចំពោះកាតមិនអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាធានាក្រៅពីការមិនអនុវត្តកាតព្វកិច្ចចម្បង ។ អ្នកធានាត្រូវរាប់បញ្ចូលកាតព្វកិច្ចធានានូវប្រាក់នោះជាការប្រាក់នៃធានាសំណងក្នុងករណីបំពានកិច្ចសន្យា និងសំណងការខូចខាតដែលទាក់ទងនឹងកាតព្វកិច្ចចម្បង ព្រមទាំងអ្វីដែលកើត ឡើងបន្ទាប់ពីកាតព្វកិច្ចចម្បងនេះ ។ ប្រសិនបើភាគីនៃកិច្ចសន្យាធ្វើការសន្យាពិសេសទៀតនោះ ពួកគេត្រូវគោរពតាមការសន្យាពិសេសនោះ ។

កិច្ចសន្យាធានាអាចកំណត់នូវចំនួនទឹកប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ឬ ប្រាក់សំណងការខូចខាតចំពោះការមិនអនុវត្តកាតព្វកិច្ចធានា ដាច់ដោយឡែកបានពីកាតព្វកិច្ចចម្បង ។

ឧទាហរណ៍ៈ ក មានកាតព្វកិច្ចសងជាប្រាក់ចំនួន ១០.០០០ ដុល្លារ ចំពោះ ខ ។ ការប្រាក់ និង ប្រាក់សំណង ( ក្នុងករណីយឺតយ៉ាវ ) ត្រូវបានព្រមព្រៀងគ្នារៀងៗខ្លួន គឺចំនួន ៧ % ។គ. មិនត្រឹមតែធានចំពោះប្រាក់ដើមចំនួន ១០.០០០ ដុល្លារទេ គឺ ថែមទាំងការប្រាក់និងប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យាដែលអាចមានថែមទៀតផង ក្នុងករណីប្រសិនបើ គ និង ក បង្កើតកិច្ចសន្យាធានាដោយគ្មានការសន្យាពិសេសណាមួយនោះ ។ តាមរយៈកិច្ចសន្យាពិសេស គ. អាចធានាត្រឹមតែប្រាក់ដើម ឬ ការប្រាក់ដែលអាចមាន ។ក៏ដូចជាការធានាមួយផ្នែកដែរ គ និង ក អាចធ្វើការសន្យាពិសេស អំពីការប្រាក់ក្នុងករណីយឺតយ៉ាវចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន ឧទាហរណ៍ៈ ក និង គ អាចសន្យាថា គ ត្រូវបង់ការប្រាក់ចំនួន ១០ % ចំពោះការយឺតយ៉ាវនៃកាតព្វកិច្ចធានា ។ ក្នុងករណីនេះ គ មានកាតព្វកិច្ចបង់ ប្រាក់ចំនួន ១០.០០០ ដុល្លារ ដែលជាប្រាក់ដើម ការប្រាក់ចំនួន ៥ % និង ការប្រាក់ក្នុងករណីយឺតយ៉ាវចំនួន ៧% ដែលកើតចេញពីប្រាក់ដើមហើយប្រសិនបើគាត់ អនុវត្តកាតព្វកិច្ចធានាមានភាពយឺតយ៉ាវគាត់ត្រូវបង់ការប្រាក់ចំនួន ១០% ចំពោះការយឺតយ៉ាវនៃកាតព្វកិច្ចធានា ។

៤៣.ប្រការ១៣ ប្រកាសអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន , ឆ្នាំ ២០១៧

៤៤.ប្រការ១៨ ប្រកាសអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន , ឆ្នាំ ២០១៧

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវកំណត់ធានានូវប្រាក់ដើម ការប្រាក់ ប្រាកធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ និងសំណងនៃការខូចខាត ដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ[៤៥] ។

## កថាភាគទី៦.បញ្ញត្តិពិសេសក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុ

### ក. សិទ្ធិឃាត់ទុក

សិទ្ធិឃាត់ទុកជាសិទ្ធិមួយប្រភេទនៃសិទ្ធិប្រត្យក្ស ប៉ុន្តែម្ចាស់សិទ្ធិឃាត់ទុកពុំមានសិទ្ធិទទួលការសងដោយ មានអាទិភាពនោះទេ។ សិទ្ធិឃាត់ទុក ត្រូវបានបង្កើតឡើងនៅពេលដែលអ្នកកាន់កាប់វត្ថុរបស់អ្នកដទៃមានសិទ្ធិ លើបំណុលដែលបានកើតឡើងដោយមានទំនាក់ទំនងទៅនឹងវត្ថុនោះ ដោយអ្នកកាន់កាប់នោះអាចឃាត់វត្ថុនោះបានរហូតទទួលបានការសងចំពោះសិទ្ធិលើបំណុល ដោយអ្នកកាន់កាប់ត្រូវបានចាប់ផ្តើមកាន់កាប់សុចរិត ក្នុងករណីដែលសិទ្ធិឃាត់ទុកបានកើតឡើង ម្ចាស់សិទ្ធិឃាត់ទុកអាចទទួលផលពីវត្ថុដែលឃាត់ទុកនោះ និងអាចយកផលពីវត្ថុ ដែលឃាត់ទុកនោះមកកាត់សិទ្ធលើបំណុល (កាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុន ហើយប្រសិនបើមានសំណល់ ត្រូវយកមកកាត់ប្រាក់ដើម) ដោយមានអាទិភាពជាងម្ចាស់បំណុលដទៃផ្សេងទៀត។ មួយវិញទៀត ម្ចាស់សិទ្ធិឃាត់ទុកត្រូវមានករណីយកិច្ចមួយចំនួនដូចជា ត្រូវកាន់កាប់វត្ថុដែលឃាត់ទុកនោះដោយប្រុងប្រយ័ត្នក្នុងនាមជា– អ្នកគ្រប់គ្រងដោយសុចរិត និងមិនអាចយកវត្ថុដែលឃាត់ទុកនោះ ទៅប្រើប្រាស់ ឬជួល ឬទៅដាក់ប្រាតិភោគ នោះទេ បើគ្មានការយល់ព្រមពីកម្មសិទ្ធិករនៃវត្ថុ (កូនបំណុល) លើកលែងតែ ការប្រើប្រាស់នោះក្នុងគោលបំណងរក្សាវត្ថុឃាត់ទុក និងប្រសិនបើមិនដូច្នោះនោះទេ កម្មសិទ្ធិករនៃវត្ថុត់ទុកអាចទាមទារឱ្យរលត់សិទ្ធិឃាត់ទុក ។ ទន្ទឹមនឹងនេះផងដែរ ម្ចាស់សិទ្ធិឃាត់ទុក ក៏មានសិទ្ធិមួយចំនួនផងដែរ ដូចជាប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានចំណាយជាប្រចាំសម្រាប់ការគ្រប់គ្រង និងថែរក្សាវត្ថុឃាត់ទុកម្ចាស់សិទ្ធិឃាត់ទុក អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុឃាត់ទុកសងចំណាយនោះវិញបាន និងបើការចំណាយបានបង្កើនតម្លៃវត្ថុឃាត់ទុក ម្ចាស់សិទ្ធិឃាត់ទុកអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុឃាត់ទុកសងចំណាយទាំងអស់ទៅឱ្យម្ចាស់សិទ្ធិឃាត់ទុក ឬតម្លៃប្រាក់កំណើនដែលមានអត្ថិភាព តាមការជ្រើសរើសរបស់កម្មសិទ្ធិករបាន ប្រសិនបើកំណើនតម្លៃនោះនៅតែបន្តអត្ថិភាព ប៉ុន្តែតុលាការក៏អាចកំណត់ពេលសមរម្យដើម្បីសងតាមការទាមទាររបស់កម្មសិទ្ធិករបាន។

ដោយឡែកសិទ្ធិឃាត់ទុកនឹងរលត់នៅក្នុងករណីដែលមានកំណត់នៅក្នុងច្បាប់ដូចជា :

- អាជ្ញាយុកាលៈ ដំណើរការនៃអាជ្ញាយុកាលនៃសិទ្ធិលើបំណុល
- ការផ្តល់ប្រាតិភោគ : ផ្តល់បាតិភោគដ៏សមរម្យ
- ការបាត់បង់នូវការកាន់កាប់ : ម្ចាស់សិទ្ធិឃាត់ទុកបាត់បង់កាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការ ឃាត់ទុក ប៉ុន្តែករណីនេះ មិនយកមកអនុវត្តសម្រាប់ស្ថានភាពដែលម្ចាស់សិទ្ធិឃាត់ទុកយកវត្ថុនេះទៅជួល ឬបញ្ចាំដោយ

៤៥. មាត្រា ៨៩៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

• ទទួលការអនុញ្ញាតពីកម្មសិទ្ធិករនៃវត្ថុនោះឡើយ និងទោះបីម្ចាស់សិទ្ធិឃាត់ទុកបានបាត់បង់ការកាន់កាប់វត្ថុឃាត់ទុកក៏ដោយ បន្ទាប់មកម្ចាស់សិទ្ធឃាត់ទុកនោះបានកាន់កាប់ឡើងវិញ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់ មកវិញ-មាត្រា ២៣៧) ត្រូវចាត់ទុកថាបន្តអត្ថិភាព។

មាត្រា ៨៩៦ នៃក្រមរដ្ឋប្បវេណី កំណត់ចែងអំពីអានុភាពនៃការឃាត់ទុកចំពោះសិទ្ធិប្រាតិភោគដោយអនុប្បទាននេះ ត្រូវបានអនុវត្តដូចគ្នាទៅនឹងអានុភាពនៃការឃាត់ទុកចំពោះសិទ្ធិលើការបញ្ចាំ ។ ក្នុងន័យនេះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានឃាត់ទុកវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានបានរហូតដល់ពេលទទួលការសងចំពោះទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដូចបានកំណត់ខាងលើនេះ ។ ប៉ុន្តែសិទ្ធិនេះមិនអាចតតាំង ចំពោះម្ចាស់បំណុលដែលមានអាទិភាពជាង ខ្លួនបានឡើយ[៤៦] ។

## ខ. ករណីកិច្ចរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានក្នុងការរក្សាទុកវត្ថុ

ចំពោះករណីកិច្ចរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានក្នុងការក្សាទុកវត្ថុ ដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន មាត្រា ៨៩៦ នៃក្រមរដ្ឋប្បវេណី កំណត់ចែងដូចគ្នាទៅនឹងមាត្រា ៨២៣ផងដែរ ដោយមានអត្ថន័យជារួមថា « ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។ ប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនបានគោរពកាតព្វកិច្ចនោះទេ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានអាចទាមទាររំលត់សិទ្ធិប្រាតិភោគដោយអនុប្បទាននោះបាន»[៤៧]។

## គ. សិទ្ធិទាមទារឲ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិទាមទារឲ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានកំណត់ នៅក្នុងមាត្រា ៨៩៦ នៃក្រមរដ្ឋប្បវេណី ដែលចែងដូចគ្នាទៅនឹងមាត្រា ៨២៣ ផងដែរ ដោយកំណត់ថា ករណីម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែក្សាវត្ថុចំពោះវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិប្រាតិភោគអនុប្បទាននោះ អាចទាមទារឲ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន។ ប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគ ដោយអនុប្បទានបានចេញចំណាយបង្កើនតម្លៃនៃវត្ថុដែលជាកម្មវត្ថុ នៃប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាននោះ អាចទាមទារឲ្យកម្មសិទ្ធិនៃវត្ថុនោះសងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ សងនូវតម្លៃប្រាក់ដែលកើននោះវិញ តាមការជ្រើសរើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើននោះនៅតែមាន ។ តុលាការអាចកំណត់ពេលសមរម្យ ដើម្បីសងតាមការទាមទារ របស់កម្មសិទ្ធិករបាន[៤៨] ។

៤៦. មាត្រា ៨២១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៤៧. មាត្រា ៨២៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៤៨. មាត្រា ៨២៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ផ្នែកទី២. ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចអនុវត្តសិទ្ធិរបស់ខ្លួនតាមរយៈការប្តូរវត្ថុដែលជាកម្មវត្ថុប្រាតិភោគដោយអនុប្បទាននោះទៅជាប្រាក់ដោយខ្លួនឯង ឬធ្វើលទ្ធកម្មនូវវត្ថុនោះជាស្ថាពរដោយជូនដំណឹងទៅអ្នកបង្កើត (កូនបំណុល) ។ ក្នុងករណីនេះ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលទទួលបញ្ញា ។ ពីអ្នកបង្កើតកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន (ម្ចាស់បំណុល) អាចទាមទារឱ្យជននោះប្រគល់វត្ថុដែលជាកម្មវត្ថុមកឱ្យខ្លួនបាន និងប្រសិនបើតម្លៃនៃវត្ថុនេះមានចំនួនទឹកប្រាក់លើសពីកាតព្វកិច្ចដែលត្រូវសងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបង់ចំនួនទឹកប្រាក់ដែលលើសនោះទៅឱ្យអ្នកបង្កើត ដោយចាត់ទុកជាប្រាក់ជម្រះ។

មួយវិញទៀត អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន (កូនបំណុល មានសិទ្ធិទទួលយកមកវិញនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ដោយការសងកាតព្វកិច្ចរបស់ខ្លួន ដោយផ្តល់ចំនួនសរុបនកាតព្វកិច្ចបាននៅមុនពេលមានការផ្តល់ប្រាក់ជម្រះ ដែលជាមូលដ្ឋានគតិយុត្តការពារអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានឱ្យបានច្រើនតាមតែអាចធ្វើទៅបាន ក្នុងទំហំដែលមិនធ្វើឱ្យខូចខាតដល់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន លើកលែងតែតម្លៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន មិនលើសពីកាតព្វកិច្ចដែលត្រូវសង ក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអំពីចំនួនដែលមិនលើសឱ្យទៅអ្នកបង្កើត (កូនបំណុល) ។ លើសពីនេះទៅទៀត ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានសម្រាប់ម្ចាស់សិទ្ធិ អាចអនុវត្តដូចកម្មសិទ្ធិករនវត្ថុបានប្រសិនបើខ្លួនកាន់កាប់វត្ថុនិងចាត់ចែងតទៅតតិយជនបាន ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធមិនបានកាន់កាប់នោះទេ ខ្លួននឹងមិនអាចនវត្តសិទ្ធិនេះបានឡើយហើយអ្នកបង្កើតសិទ្ធិ ឬកូនបំណុលនឹងអាចចាត់ចែងវត្ថុដែលជាកម្មវត្ថុ នេះបានហើយដើម្បីឱ្យមានភាពច្បាស់លាស់ចំពោះសកម្មភាពទាំងនេះ ទាមទារឱ្យធ្វើឡើងតាមលក្ខខណ្ឌតម្រូវដូចមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីពិសេសសម្រាប់សិទ្ធិលើការបញ្ចាំទាមទារឱ្យផ្ទេរវត្ថុដែលជាកម្មវត្ថុនៃការបញ្ចដែលជាលក្ខខណ្ឌបង្កើតអានុភាព និងការចុះបញ្ជីដែលជាលក្ខខណ្ឌតតាំងប្រសិនបើមានបុគ្គលផ្សេងអះអាងអំពីកម្មសិទ្ធចំពោះ វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះ ។

ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានអាច ធ្វើការបែងចែកជា ២ករណី គឺ ការចាត់ចែងប្តូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ ដោយមូលហេតុអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានពុំអនុវត្តកាតព្វកិច្ច និងការទទួលយកមកវិញនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ដោយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។

ប្រការនេះមិនចោទជាបញ្ហានោះទេ នៅពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ញាពីម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានទទួលបានការកាន់កាប់ ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ។ ប៉ុន្តែប្រសិនបើវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ស្ថិតនៅក្នុងការកាន់កាប់ដោយចំពោះដោយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានដកការបញ្ញាពីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

អាចទាមទារឲ្យជននោះប្រគល់វត្ថុដែលជាកម្មវត្ថុនោះជាមុនសិន[៤៩] ។

**កថាភាគទី១. ការចាត់ចែងប្តូរជាប្រាក់**

ការចាត់ចេងប្តូរជាប្រាក់ ឬធ្វើលទ្ធកម្មជាស្ថាពរដោយបញ្ជាក់ថា ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន តម្រូវឱ្យជូនដំណឹងទៅអ្នកបង្កើតប្រាតិភោគអំពីការប្តូរជាប្រាក់ ឬលទ្ធកម្មកម្មសិទ្ធិនោះ ។

ក្នុងករណីដល់កាលបរិច្ឆេទកំណត់សង ក មិនសងទេនោះ ខ អាចធ្វើការចាត់ចែងវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ដោយខ្លួនគាត់បាន ដោយគ្រាន់តែជូនដំណឹងទៅអ្នកបង្កើតសិទ្ធិប្រាតិភោគ ឬ ក្នុងករណីដែលកាតព្វកិច្ចពុំត្រូវបានអនុវត្ត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចចាត់ចែងប្តូរវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាននោះជាប្រាក់ដោយខ្លួនឯងបាន ដោយគ្រាន់តែជូនដំណឹងទៅកាន់អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន[៥០] ។

**ក. អនុប្បទានជាស្ថាពរ**

ក្រៅពីជម្រើសនៃការចាត់ចែងប្តូរជាប្រាក់ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ជម្រើសធ្វើអនុប្បទានជាស្ថាពរ ដោយធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុ នៃប្រាតិភោគដោយអនុប្បទានបាន។ ចំពោះការធ្វើលទ្ធកម្មនេះ ម្ចាស់សិទ្ធិប្រាតិភោគដោយនុប្បទានក៏ត្រូវជូនដំណឹងទៅកាន់អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ[៥១] ។

**ខ. ករណីកិច្ចត្រូវបង់ទឹកប្រាក់ដែលលើស**

ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ជ្រើសរើសអនុវត្តសិទ្ធិប្រាតិភោគ ដោយការចាត់ចែងជាប្រាក់ ឬ អនុប្បទានជាស្ថាពរ ប្រសិនបើតម្លៃនៃវត្ថុដែលជាកម្មវត្ថុមានចំនួនលើសពីចំនួនទឹកប្រាក់ នៃកាតព្វកិច្ចដែលត្រូវសង ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបង់ចំនួនទឹកប្រាក់ដែលលើសនោះ ទៅឲ្យអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានវិញ ដោយចាត់ទុកថាជាប្រាក់ជម្រះ[៥២] ។

**គ. សិទ្ធិទទួលយកវិញរបស់អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន**

ជាគោលការណ៍ បើដល់កាលបរិច្ឆេទនៃកាលកំណត់អនុវត្តកាតព្វកិច្ចហើយ ប៉ុន្តែអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានពុំអនុវត្តកាតព្វកិច្ច ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចប្រើជម្រើសណាមួយក៏បានក្នុងចំណោមការចាត់ចែងប្តូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរដើម្បីអនុវត្ត។ ប៉ុន្តែទោះបីជាពេលកំណត់ត្រូវសងកាតព្វកិច្ចបានកន្លងផុតក៏ដោយ ក៏មាត្រា ៨៩៩ នៃក្រមរដ្ឋប្បវេណី ២០០៧ បញ្ញត្តិទុកសិទ្ធិឲ្យអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន អាចទទួលយកមកវិញនូវវត្ថុដែលជាកម្មវត្ថុ ដោយផ្តល់នូវកាតព្វកិច្ចគ្រប់ចំនួន និង

---

៤៩. មាត្រា ៨៩៨ .៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៥០. មាត្រា ៨៩៨ .១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៥១. មាត្រា ៨៩៨ .២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៥២. មាត្រា ៨៩៨ .៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បង្ហាញអំពីការផ្តល់នោះទៅម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន នៅមុនពេលមានការផ្តល់ប្រាក់ជម្រះដូចបានរៀបរាប់ខាងលើ។ ប៉ុន្តែ ករណីនេះមិនត្រូវយកមកអនុវត្តឡើយ កាលណាតម្លៃវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ មិនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសងក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានជូនដំណឹងអំពីចំនួនដែលមិនលើសនោះទៅឲ្យអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានរួចហើយ[៥៣] ។

## កថាភាគទី២. ការអនុវត្តអត្រាការប្រាក់

បញ្ហាអត្រាការប្រាក់នៅក្នុងកិច្ចសន្យាមិនថាជាកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ឬ កិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគប្រត្រក្យ ជាបញ្ហាមួយដែលពាក់ព័ន្ធយ៉ាងជ្រៅទៅនឹងវិស័យច្បាប់ ក៏ដូចជាវិស័យសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជា។ ជាទូទៅកិច្ចសន្យារវាងគូភាគី ជាច្បាប់ដែលបង្កើតឡើងដើម្បីចងគូភាគី និងមានអានុភាពអនុវត្តទៅលើគូភាគីផងដែរលក្ខខណ្ឌនេះក៏ត្រូវបានកំណត់ចំពោះ អត្រាការប្រាក់ដែលអាចជាកម្មវត្ថុមួយនៃកិច្ចសន្យាផងដែរ ។ ប៉ុន្តែដោយផ្អែកទៅលើគោលការណ៍សមធម៌នៅក្នុងសង្គម និងការជៀសវាងទៅលើការកេងចំណេញហួសហេតុនា ឆ្នាំ ២០១១ ក្រសួងយុត្តិធម៌ កំណត់ចេញប្រកាសមួយស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតដោយកំណត់អត្រាការប្រាក់នោះមិន ឲ្យលើសពី ១៨% ក្នុងមួយឆ្នាំ[៥៤] ចំពោះកិច្ចសន្យាខ្ចីបរិភោគដែលមានការប្រាក់ ។ បន្ថែមពីនេះទៀតធនាគារជាតិ ក៏បញ្ញត្តិចេញនូវប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន ដោយបានកំណត់អត្រាការប្រាក់ឥណទានមិនឲ្យលើសពី ១៨% ក្នុងមួយឆ្នាំ[៥៥] ដែលមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលស្ថិតក្រោមអាណាព្យាបាលរបស់ធនាគារជាតិ។

ថ្វីបើកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ និង កិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានសុទ្ធតែបង្កើតបាននូវកាតព្វកិច្ចដែលបង្កើតប្រាក់ទៅលើកូនបំណុល ប៉ុន្តែទាក់ទងនឹងបញ្ញត្តិអំពីអត្រាការប្រាក់នេះ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១ ពុំមានបញ្ជាក់ច្បាស់ទៅលើថា តើអត្រាការប្រាក់ដែលត្រូវបានកម្រិតចំពោះកិច្ចសន្យាខ្ចីបរិភោគដោយ ភ្ជាប់ការប្រាក់[៥៦] អាចអនុវត្តទៅលើកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាននោះទេ។ ភាពមិនច្បាស់លាស់នេះ បានបង្កើតនូវសំណួរគតិយុត្តថា តើកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាននេះ ជាទម្រង់មួយនៃកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ដែលមានការធានាកាតព្វកិច្ច ឬកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន មិនដូចគ្នានឹងកិច្ចសន្យាខ្ចីបរិភោគដែលមានការប្រាក់ ដោយសារតែកិច្ចសន្យាប្រភេទផ្សេងគ្នា ។ ទាក់ទិននឹងករណីនេះ ប្រសិនបើងាកទៅមើលច្បាប់ជប៉ុនដែលជាប្រភពយ៉ាងមានឥទ្ធិពលលើក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ក៏មានច្បាប់មួយដែលកម្រិតទៅលើអត្រាការប្រាក់នៃកិច្ចសន្យាសម្រាប់ឥណទាន ( ប្រាក់កម្ចី[៥៧] ) ផងដែរ។ ក្នុងអត្ថន័យនៃច្បាប់នោះ ពុំមានការបញ្ជាក់ថាជាកិច្ចសន្យាប្រភេទណាទេ ប៉ុន្តែច្បាប់នោះបញ្ញត្តិចែងទូទៅចំពោះកិច្ចសន្យាដែលទាក់ទងនឹង

៥៣. មាត្រា ៨៩៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៥៤. ប្រការ១ ប្រកាសអត្រាការប្រាក់កម្រិត ឆ្នាំ ២០១១

៥៥. ប្រការ៤ ប្រកាសការប្រាក់ពិដាន ឆ្នាំ ២០១៧

៥៦. មាត្រា ៥៨៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៥៧. ច្បាប់ស្តីពីការកម្រិតអត្រាការប្រាក់ ( ប្រទេសជប៉ុន ) ១៥.ឧសភា.១៩៥៤

ប្រាក់កម្ចី។ ដូចនេះ ភាគីក៏ដូចជាស្ថាប័នពាក់ព័ន្ធអាចមានភាពងាយស្រួលក្នុងការបកស្រាយច្បាប់ ពេលមានវិវាទទាក់ទិននឹងអត្រាការប្រាក់។ ដូចនេះបញ្ហាពាក់ព័ន្ធនឹងអត្រាការប្រាក់នេះ ជាភាពចន្លោះប្រហោងនៃច្បាប់កម្ពុជាផងដែរ។

## កថាភាគទី៣. ស្ថាប័នមានសមត្ថកិច្ចទាក់ទិននឹងប្រាតិភោគដោយអនុប្បទាន

### ក. ក្រសួងយុត្តិធម៌

មុននឹងមានក្រមរដ្ឋប្បវេណី តាមអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ ឆ្នាំ ២000 ក្រសួងយុត្តិធម៌ ជាស្ថាប័នដែលមានភារកិច្ចតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិទាំងឡាយស្តីអំពីនីតិព្រហ្មទណ្ឌ និតិវិធីព្រហ្មទណ្ឌ នីតិរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី[៥៨] ។ បន្ទាប់ពីបង្កើតក្រមរដ្ឋប្បវេណីអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ ឆ្នាំ ២០១៤ បញ្ញត្តិអំពីភារកិច្ចរបស់ក្រសួងយុត្តិធម៌ ជាស្ថាប័នដែលកសាងសេចក្តីព្រាងច្បាស់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ នៅក្នុងវិស័យយុត្តិធម៌ ព្រមទាំងទទួលពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់របស់ក្រសួង និងស្ថាប័ននានា។ បន្ថែមពីនេះក្រសួងយុត្តិធម៌ ក៏ទទួលបន្ទុកលើការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិទាំងឡាយក៏ដូចជាពិនិត្យ និងផ្តល់យោបល់លើបញ្ហានានាដែលទាក់ទងនឹងកិច្ចការរដ្ឋប្បវេណី និងកិច្ចការព្រហ្មទណ្ឌផងដែរ។

ទាក់ទិននឹងការទទួលបន្ទុកលើការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិទាំងឡាយ ក៏ដូចជាពិនិត្យ និងផ្តល់យោបល់លើបញ្ហានានាដែលទាក់ទងនឹងកិច្ចការរដ្ឋប្បវេណីនេះ ក្រសួងយុត្តិធម៌ ជាស្ថាប័នដែលមានសមត្ថកិច្ចដោយផ្ទាល់ក្នុងការពិនិត្យ និងផ្តល់យោបល់លើបញ្ហានានាដែលទាក់ទង នឹងប្រាតិភោគដោយអនុប្បទាន ព្រមទាំងតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ដើម្បីដោះស្រាយនូវបញ្ហានោះផងដែរ។

### ខ. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ ទិញលក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយ ប្បទាន ដោយមាននាយកដ្ឋានគ្រប់គ្រងអាជីវកម្ម បញ្ចាំ និងប្រាតិភោគដោយអនុប្បទានជាសេនាធិការ ដែលបំពេញមុខងារលើការងារគ្រប់គ្រងអាជីវកម្ម បញ្ចាំ និងប្រាតិភោគដោយអនុប្បទានផងដែរ[៥៩] ។ បន្ថែមពីនេះទៀតក្រសួង សេដ្ឋកិច្ច ហិរញ្ញវត្ថុ មន្ទីរសេដ្ឋកិច្ច និងហរិញ្ញវត្ថុ ក៏ជាស្ថាប័នតែមួយគត់ដែល មានសមត្ថកិច្ចក្នុងការពិនិត្យ និងសម្រេចផ្តល់ ឬ បដិសេដ ឬ បន្តសុពលភាពដល់ក្រុមហ៊ុនដែលប្រកប អាជីវកម្មប្រាតិភោគដោយអនុប្បទានផងដែរ[៦០] ។ បន្ថែមពីនោះ ក្រសួងនេះក៏មានសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្មជាការព្រមាន ឬ ជាពិន័យអន្តរការណ៍ចំពោះសកម្មភាពខុសច្បាប់នានាទាក់ទៅនឹងអាជីវកម្ម ប្រាតិភោគដោយអនុប្បទានផងដែរ[៦១] ។

៥៨.មាត្រា៩ និងមាត្រា១០នៃ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ , ឆ្នាំ២០០០

៥៩.មាត្រា៤៩ និងមាត្រា៥០ នៃអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ , ឆ្នាំ ២០១៣

៦០.ប្រការ៦ និងប្រការ៧ ស្តីពីប្រកាសអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន, ឆ្នាំ ២០១៧

៦១. ប្រការ៣៣ ដល់ប្រការ៣៨ ស្តីពីប្រកាសអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន, ឆ្នាំ ២០១៧

ករណីមានវិវាទរវាងក្រុមហ៊ុនទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន ជាមួយក្រុមហ៊ុនទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន និង/ឬ អ្នកដាក់ប្រាតិភោគដោយអនុប្ប ទានពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មបញ្ចាំ ឬប្រាតិភោគដោយអនុប្បទាន អគ្គនាយកដ្ឋានឧស្សាហកម្ម ហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ច និងហរិញ្ញវត្ថុ អាចដើរតួនាទីជាអ្នកផ្សះផ្សាបានតាមរយៈកិច្ចព្រមព្រៀងផ្សះផ្សា ដែលត្រូវចុះហត្ថលេខាដោយគូភាគីនៃវិវាទ ដោយមានប្រថាប់ត្រារបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[៦២] ។ ប្រសិនបើហ៊ុនទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន ឬ អ្នកដាក់ប្រាតិភោគដោយអនុប្បទាន មិនពេញចិត្តចំពោះសេចក្តីសម្រេច ឬ វិធានការផ្សេងៗរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភាគីមិនពេញចិត្តមានសិទ្ធដាក់ពាក្យបណ្តឹងតវ៉ាទៅកាន់ក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុននឹងអនុវត្តនីតិវិធីបណ្តឹងទៅតុលាការ។ ការដោះស្រាយវិវាទក្រៅតុលាការដោយក្រសួង ឬ មន្ទីរបែបនេះ ជាយន្តការណ៍មួយដែលអាចជួយ សម្រួលដល់ការដោះស្រាយវិវាទ ដោយអាចឲ្យគូភាគីទទួលបាននូវការប្រឹក្សាផ្នែកច្បាប់ មុននឹងឈានដល់ការដោះស្រាយតាមប្រព័ន្ធតុលាការមាននីតិវិធីស្មុគស្មាញ ព្រមទាំងចំណាយថវិកា និងពេលវេលា ថែមទៀតផង។

### គ. តុលាការ

ថ្វីបើភាគីអាចធ្វើការដោះស្រាយក្រៅប្រព័ន្ធតុលាការ ដោយប្រើប្រាស់យន្តការរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏ពិតមែន ប៉ុន្តែដំណោះស្រាយនេះ ពុំមានអានុភាពបង្ខំអនុវត្តនោះទេ ប្រសិនបើ មានភាគីណាមួយមិនយល់ស្រប និងព្រមព្រៀងទៅលើដំណោះស្រាយ។ អាស្រ័យហេតុនេះហើយ ទើបស្ថាប័នតុលាការនៅតែជាជម្រើសដ៏សំខាន់ ដែលមានសិទ្ធិអំណាចក្នុងការជម្រះក្តីទាក់ទង នឹងប្រាតិភោគដោយអនុប្បទានក៏ដូចជារឿងក្តីផ្សេងៗផងដែរ ព្រោះមានតែសេចក្តីសម្រេចស្ថាពររបស់តុលាការទេដែលមានអានុភាពចាប់បង្ខំឲ្យភាគីគោរពតាម។

៦២.ប្រការ៣១ ស្តីពីប្រកាសអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ,ឆ្នាំ ២០១៧

# ជំពូកទី៣
# ការអនុវត្តការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន

# ជំពូកទី៣
# ការអនុវត្តការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន
## ផ្នែកទី១ ការភាន់ច្រឡំរវាងការបញ្ចាំ និងប្រាតិភោគដោយអនុប្បទានរបស់ប្រជាពលរដ្ឋ

ប្រាតិភោគដោយអនុប្បទាន និង ការបញ្ចាំចលនវត្ថុ ជាការធានាកាតព្វកិច្ចដែលមានលក្ខណៈស្រដៀងគ្នាច្រើន បើធៀបជាមួយការធានាកាតព្វកិច្ចដទៃទៀត។ ប្រការនេះហើយដែលធ្វើឲ្យ ប្រជាពលរដ្ឋទូទៅមានការភាន់ច្រឡំរវាងប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ។

តាមរយៈការប្រមូលទិន្នន័យតាមការស្រង់មតិតាមប្រព័ន្ធឌីជីថលដោយប្រើប្រាស់ Google Form ចន្លោះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០២១ រហូតដល់ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០២១ ដែលត្រូវជ្រើសរើសភាគសំណាកដោយចៃដន្យចំពោះប្រជាពលរដ្ឋនៅទូទាំងប្រទេសកម្ពុជាចំនួន១២២រូប។ អ្នកឆ្លើយតបចំនួន ១២២រូប បានបង្ហាញលទ្ធផលដូចនៅក្នុងក្រាហ្វិកខាងក្រោម។

បង្ហាញថា ក្នុងចំណោមអ្នកឆ្លើយតបចំនួន ១២២នាក់ អ្នកដែលបានឆ្លើយថា យល់ពីអត្ថន័យនៃការបញ្ចាំមានរហូតដល់ ៨៥%។ ចំណែកអ្នកដែលមិនយល់នូវអត្ថន័យនៃការបញ្ចាំ មានចំនួនតែ ៥% ប៉ុណ្ណោះ ។

ជាការឆ្លើយតបនូវសំណួរថា ពេលអ្នកមិនបានទៅលោះវត្ថុនៅថ្ងៃកំណត់ អ្នកគិតថាហាងនឹងការរឹបអូសវត្ថុនោះមែនឬទេ។ អ្នកឆ្លើយតបដែលបានឆ្លើយថា ហាងបញ្ចាំនឹងធ្វើការរឹបអូសវត្ថុដែលបានបញ្ចាំមានចំនួនទៅដល់ ៦០%។ ចំណែកឯអ្នកដែលបានឆ្លើយថា ហាងបញ្ចាំនឹងមិនរឹបអូសវត្ថុដែលបានបញ្ចាំមានចំនួនត្រឹមតែ ៧% ប៉ុណ្ណោះ។ រីឯអ្នកឆ្លើយតបដែលនៅសល់ចំនួន ៣៣% ទៀតបានបញ្ជាក់ថាពុំបានដឹង និងពុំធ្លាប់ដឹងព្រោះពុំធ្លាប់បានបញ្ចាំ។

ចំណែកនៅក្នុងចំណោមអ្នកឆ្លើយតបចំនួន ១០៤រូប ដែលបានឆ្លើយថា យល់ដឹងអំពីអត្ថន័យនៃការបញ្ចាំ អ្នកឆ្លើយតបថា ហាងបញ្ចាំនឹងរឹបអូសវត្ថុបញ្ចាំមានចំនួន ៦៥រូប ឬ ៦៣%។ អ្នកដែលបានបញ្ចាំ មានចំនួន ៣១%។ ដូចនេះ តាមក្រាហ្វិកទី១ និងក្រាហ្វិកទី៣ យើងអាចបង្ហាញឲ្យឃើញថាអ្នកដែលយល់ដឹងអំពីការបញ្ចាំមានត្រឹមតែ ៧រូប ខណៈអ្នកដែលច្រឡំរវាងការបញ្ចាំ និងប្រាតិភោគដោយអនុប្បទានមានចំនួន ៦៥រូប ដែលស្មើនឹង ៩០%[៦៣] ។

បានបង្ហាញថាក្នុងចំណោមអ្នកឆ្លើយតបចំនួន ១២២រូប មានតែអ្នកឆ្លើយតប ៥.៧% ប៉ុណ្ណោះដែលមានភាពយល់ដឹងត្រឹមត្រូវទៅលើអត្ថន័យនៃការបញ្ចាំ។ ចំណែកអ្នកឆ្លើយតប ៩៤.៣% ពុំបានយល់ដឹងអំពីអត្ថន័យនៃការបញ្ចាំនោះទេ ។

ដោយសារតែអ្នកដែលច្រឡំរវាងការបញ្ចាំ និងប្រាតិភោគដោយអនុប្បទានរហូតដល់ ៩០% និងអ្នកបានយល់ដឹងអំពីអត្ថន័យនៃការបញ្ចាំ មានរហូតដល់ ៩៤.៣% ហេតុដូចនេះនៅក្នុងជំពូកនេះ យើងនឹងធ្វើការ

៦៣. www.Population, Total - CAMBODIA. The World Bank Group, 2021

បកស្រាយធៀបដោយសង្ខេបនូវភាពដូចគ្នា និងខុសគ្នានៃប្រាតិភោគដោយអនុប្បទាន ។

### កថាភាគទី១. ការបង្កើតកិច្ចសន្យាបង្កើតសិទ្ធិ

ចំពោះកិច្ចសន្យាបង្កើតសិទ្ធិនេះ មិនថាកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំចលនវត្ថុ ឬ កិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវគោរពទៅតាមលក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់ ដែលលក្ខខណ្ឌនេះពុំមានភាពខុសគ្នាទេ គឺមានភាពដូចគ្នាទាំងស្រុង។ ប៉ុន្តែដើម្បីឲ្យកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំចលនវត្ថុមានសុពលភាពទៅបានលុះត្រាតែអ្នកបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល ឬ តតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំ) ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ ដែលមានន័យថា ម្ចាស់សិទ្ធិនៃការបញ្ចាំត្រូវតែទទួលបានការកាន់កាប់ដោយចំពោះទៅលើវត្ថុដែលខុសពីម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលអាចកាន់កាប់ដោយផ្ទាល់ និងប្រយោល។ ដូចនេះម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវទទួលបានការផ្ទេរការកាន់កាប់ដោយការប្រគល់ជាក់ស្តែង ឬការប្រគល់ដោយសង្ខេបតែប៉ុណ្ណោះ។

ទាក់ទិននឹងការហាមបង្កើតកិច្ចសន្យាបញ្ចាំផ្តាច់ ម្ចាស់សិទ្ធិលើការបញ្ចាំ និងអ្នកបង្កើតសិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀងគ្នាឲ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលបានកម្មសិទ្ធិលើការបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំតាមវិធីផ្សេងដែលច្បាប់បានកំណត់ ដោយសម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ មិនអាចធ្វើលទ្ធកម្មសិទ្ធិ ឬ ចាត់ចែងលើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំដោយការអនុវត្តជាឯកជន ក្នុងករណីដែលកាតព្វកិច្ចមិនត្រូវបានសងនោះឡើយ។

### កថាភាគទី២. អានុភាពនៃសិទ្ធិ

ទាក់ទិននឹងអានុភាពនៃសិទ្ធិលើការបញ្ចាំ និងអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន មានភាពដូចគ្នាទាំងស្រុងទៅលើអានុភាពនៃឧបាទេសកម្ម អានុភាពនៃទំហំសិទ្ធិលើបំណុលដែលត្រូវបានធានា អានុភាពនៃការឃាត់ទុកករណីកិច្ចរបស់ម្ចាស់សិទ្ធិក្នុងការរក្សាទុកវត្ថុដែលជាកម្មវត្ថុ និងសិទ្ធិទាមទារឲ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិ។

ចំណុចដូចគ្នាមួយទៀតរវាងអានុភាពនៃសិទ្ធិលើការបញ្ចាំ និងអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន គឺអានុភាពទៅលើផលដោយម្ចាស់សិទ្ធិលើការបញ្ចាំ និងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ អាចទទួលផលដែលកើតចេញពីវត្ថុដែលជាកម្មវត្ថុ និងអាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន (កាត់ការប្រាក់ជាមុនសិន បើមានសំណល់ត្រូវយកទៅកាត់ប្រាក់ដើម)។

ប៉ុន្តែអានុភាពនេះ ពុំអនុវត្តចំពោះប្រាតិភោគដោយអនុប្បទាននោះទេ ប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានពុំបានកាន់កាប់ដោយចំពោះទៅលើវត្ថុដែលជាកម្មវត្ថុ។

### កថាភាគទី៣. ការអនុវត្តសិទ្ធិ ក្នុងករណីដែលកាតព្វកិច្ចពុំត្រូវបានអនុវត្ត

ក្នុងករណីដែលកាតព្វកិច្ចពុំត្រូវបានអនុវត្ត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចមានជម្រើសក្នុងការធ្វើអនុប្បទានជាស្ថាពរ ( ធ្វើលទ្ធកម្មលើកម្មសិទ្ធិ ) ឬ អាចចាត់ចែងប្តូរវត្ថុដែលជាកម្មវត្ថុនៃ ប្រាតិភោគដោយអនុប្បទាននោះជាប្រាក់ដោយខ្លួនឯងបាន ដោយគ្រាន់តែជូនដំណឹងទៅកាន់អ្នកបង្កើតសិទ្ធិប្រាតិភោគ

ដោយអនុប្បទាន ។ ប៉ុន្តែចំពោះការអនុវត្តសិទ្ធិលើការបញ្ចាំវិញ ករណីដែលកាតព្វកិច្ចពុំត្រូវបានអនុវត្តម្ចាស់សិទ្ធិលើការបញ្ចាំត្រូវទាមទារទៅកាន់តុលាការ និងជូនដំណឹងអំពីការទាមទារនោះទៅកូនបំណុល ដើម្បីយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្តង តាមការវាយតម្លៃរបស់អ្នកវាយតម្លៃ[៦៤] ។

ចំពោះទឹកប្រាក់ដែលលើស ទាំងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន និងម្ចាស់សិទ្ធិលើការបញ្ចាំមានតាតព្វកិច្ចដូចគ្នា ក្នុងការផ្តល់ទឹកប្រាក់ដែលលើនោះទៅកាន់កម្មសិទ្ធិរនៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ឬការបញ្ចាំនោះវិញ។

## ផ្នែកទី២. ការអនុវត្តប្រាតិភោគដោយអនុប្បទាន

បន្ទាប់ពីបានសិក្សាទៅលើផ្នែកទ្រឹស្តីនៃប្រាតិភោគដោយអនុប្បទានរួចមក ជំពូកនេះនឹងបន្តធ្វើការសិក្សាស្រាវជ្រាវទៅលើបញ្ហាប្រឈម ក៏ដូចជាការវិភាគស្វែងរកដំណោះស្រាយ ចំពោះការអនុវត្តជាក់ស្តែងនៃប្រាតិភោគដោយអនុប្បទាននៅកម្ពុជា។

### កថាភាគទី១. កម្រិតយល់ដឹងរបស់ប្រជាជនកម្ពុជាទៅលើប្រាតិភោគដោយអនុប្បទាន

តាមការស្រង់មតិបង្ហាញថា ក្នុងចំណោមអ្នកឆ្លើយតបចំនួន ១២២រូប មានតែគំរូតាងចំនួន ១៦រូបប៉ុណ្ណោះដែលឆ្លើយថា យល់អំពីអត្ថន័យនៃប្រាតិភោគដោយអនុប្បទាន។ ចំណែកអ្នកឆ្លើយតបចំនួន ៥៥រូបបានឆ្លើយថា ធ្លាប់ឮ តែពុំយល់អត្ថន័យ។ រីឯអ្នកឆ្លើយតបចំនួន ៥១រូប បានឆ្លើយថា ពុំយល់អត្ថន័យនៃប្រាតិភោគដោយអនុប្បទាននោះឡើយ។

អាចបង្ហាញបានថា មានតែប្រជាជនចំនួន ១៣% តែប៉ុណ្ណោះដែលយល់ដឹងអំពីប្រាតិភោគដោយអនុប្បទាន។ តាមក្រាបនេះ និងក្រាហ្វិកទី៤ ការយល់ដឹងអំពីអត្ថន័យនៃការបញ្ចាំរបស់អ្នកឆ្លើយតប (បន្ទាប់ពីវិភាគរួច) អាចបញ្ជាក់ឲ្យដឹងថា កម្រិតនៃការយល់ដឹងទាក់ទងនឹងច្បាប់មូលដ្ឋានដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាមានកម្រិតទាបនៅឡើយ ម្យ៉ាងទៀតអ្នកឆ្លើយតបមានអាយុមធ្យម ២៥ឆ្នាំ ដែលជាអាយុដែលជាទូទៅបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្ររួចរាល់។ ទាក់ទិននឹងដំណោះស្រាយនៃបញ្ហានេះ ក្រសួងទាក់ទងដែលរួមមានទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងក្រសួងអប់រំយុវជន និងកីឡារួមទាំងក្រសួងពាក់ព័ន្ធ គប្បីសិក្សាធ្វើសម្រង់មតិ និង រៀបចំគោលនយោបាយក្នុងការផ្សព្វផ្សាយច្បាប់ តាមរយៈការរៀបចំរបស់ប្រជាជន។ សៀវភៅនេះដែរគប្បីរៀបរៀងដោយប្រើប្រាស់ភាសាសាមញ្ញ ងាយយល់ឲ្យសមស្របទៅនឹងកម្រិតយល់ដឹងរបស់ប្រជាជន ដោយបញ្ចូលទៅក្នុងកម្មវិធីសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ ឬ ថ្នាក់ឆ្នាំមូលដ្ឋានសម្រាប់និស្សិតមហាវិទ្យាល័យ ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការយល់ដឹងច្បាប់ និង អាចអនុវត្តបានក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន។ វិធីសាស្ត្រនេះ ក៏អាចធ្វើឲ្យប្រជាពលរដ្ឋយល់ដឹងច្បាប់មូលដ្ឋានសំខាន់ៗ សម្រាប់ជីវភាពប្រចាំថ្ងៃ ក៏ដូចជាអាចដោះស្រាយបញ្ហាទាក់ទិននឹងការអនុវត្តប្រាតិភោគដោយអនុប្បទាន ដែលជាប្រធានបទនៃសារណាមួយនេះផងដែរ។

---

៦៤. មាត្រា ៨៣២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## កថាភាគទី២. បញ្ហាការភាន់ច្រឡំរវាងការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន

តាមការស្រង់មតិបានបង្ហាញថា ចំនួនអ្នកឆ្លើយតបចំនួន ៨៥% ( ការយល់ដឹងអំពីអត្ថន័យនៃការបញ្ចាំរបស់អ្នកឆ្លើយតបចំនួន ១០៨នាក់) បានឆ្លើយថា បានយល់អំពីអត្ថន័យនៃការបញ្ចាំ ប៉ុន្តែតាមក្រាហ្វិកទី៤ (ការយល់ដឹងអំពីអត្ថន័យនៃការបញ្ចាំរបស់អ្នកឆ្លើយតបរបស់អ្នកឆ្លើយតប (បន្ទាប់ពីវិភាគរួច)) អ្នកឆ្លើយតបចំនួនដែលយល់អត្ថន័យទៅលើអត្ថន័យនៃការបញ្ចាំបានត្រឹមត្រូវ ៥.៧% ប៉ុណ្ណោះ។ ដូចនេះ ប្រជាជនកម្ពុជាជាច្រើនបាននឹងកំពុងយល់ច្រឡំថា ប្រាតិភោគដោយអនុប្បទាន គឺជាការបញ្ចាំដែលប្រការនេះ គឺជាហេតុផលដែលហាងបញ្ចាំជាច្រើនបានយកគោលការណ៍នៃប្រាតិភោគដោយអនុប្បទានមកប្រើប្រាស់ចំពោះការបញ្ចាំ ជាពិសេសក្នុងករណីដែល កាតព្វកិច្ចពុំត្រូវបានអនុវត្ត ម្ចាស់ហាងបញ្ចាំបានឆ្លៀតឱកាសប្រើប្រាស់ជម្រើសក្នុងការធ្វើអនុប្បទានជាស្ថាពរ (ធ្វើលទ្ធកម្មសិទ្ធិ) ឬ ចាត់ចែងប្តូរវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះ ជាប្រាក់ដោយខ្លួនឯងបាន។ការអនុវត្តសិទ្ធិនេះបានខុសពីគោលការណ៍នៃសិទ្ធិលើការបញ្ចាំដែលទាមទារឲ្យឆ្លងកាត់ប្រព័ន្ធតុលាការ។

## កថាភាគទី៣.ការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយមានអាជ្ញាបណ្ណ

ក្រសួងសេដ្ឋកិច្ចកាលពីឆ្នាំ២០១០ បានចេញប្រកាសស្តីពីការគ្រប់ដណ្តប់លើអាជ្ញាប័ណ្ណនៃអាជីវកម្ម។ កាលពីចុងឆ្នាំ២០១៦ ក្រសួងកែសម្រួលប្រកាសនោះឡើងវិញ ដើម្បីធ្វើឲ្យវាស្របនឹងភាពពិតរបស់វិស័យនេះ ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបញ្ញត្តិការ និងមាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុបញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាសេនាធិការ ។ បើស្របតាមការប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរាល់អាជីវកម្មដែលទទួលប្រាក់បញ្ចាំត្រូវតែសុំការអនុញ្ញាត ឬមានអាជ្ញាប័ណ្ណត្រឹមត្រូវពីក្រសួង ដើម្បីដំណើរការអាជីវកម្មដោយស្របច្បាប់បាន ។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត បំពេញភារៈកិច្ចសម្របសម្រួល និងគាំទ្រត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំខ្នាតតូចនៅតាមរាជធានី-ខេត្ត ។ ប្រជាពលរដ្ឋកម្ពុជាអាចដាក់ពាក្យស្នើសុំប្រកបអាជីវកម្មហាងបញ្ចាំខ្នាតតូចនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្តដោយបំពេញលក្ខខណ្ឌដូចជា÷

- -ជានីតិបុគ្គលសញ្ជាតិខ្មែរ និងស្ថាបនបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់របស់ប្រទេសកម្ពុជា។
- -ត្រូវមានដើមទុនប្រកបអាជីវកម្មតាមខ្នាតអាជីវកម្មដែលបានស្នើរសុំ
- -ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម ១០% នៃដើមទុន
- -អ្នកកាន់លិខិតអនុញ្ញាតិប្រកបអាជីវកម្មត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងអាជីវកម្មស្រដៀងគ្នា ។ ប្រសិនបើអ្នកឈរឈ្មោះមិនមែនជាម្ចាស់ភាគហ៊ុនត្រូវមានលិខិតបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច[៦៥]។

៦៥.ប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន, ឆ្នាំ២០១៦។

- -ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។ លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតិប្រកបអាជីវកម្មមានកំណត់ក្នុងពាក្យស្នើសុំរបស់មន្ទីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

យោងតាមអនុក្រឹត្តលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ កក្កដារ ២០២១ ស្តីពីការៀបចំប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អាជិវកម្មហាងបញ្ចាំស្ថិតនៅក្រោមការគ្រប់គ្រងនិងត្រួតពិនិត្យនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លើសពីនេះប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ឆ្នាំ២០១៦ នឹងកំពុងត្រូវបានកែសម្រួលម្តងទៀតក្នុងពេលនេះ។ ការប្រកបអាជីវកម្មស្របច្បាប់គឺដើម្បីអាចរក្សាបាននូវសណ្តាប់ធ្នាប់សង្គម ចៀសវាងម្ចាស់អាជីវកម្មទទួលទ្រព្យបញ្ចាំពីករណីលួចប្លន់ជាដើម។ ម្យ៉ាងទៀត អ្នកខ្ចីគួរពិនិត្យមើលទីតាំងទីកន្លែង និងលិខិតកិច្ចសន្យាឱ្យច្បាស់លាស់ ចៀសវាងអាជីវកម្មមិនស្របច្បាប់ ដែលអាចធ្វើឱ្យខាតបង់ទ្រព្យធនរបស់អ្នកផងដែរ។

## កថាភាគទី៤.ការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយពុំមានអាជ្ញាបណ្ណ

ទាក់ទិនជាមួយផ្នែកសមត្ថកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាស្ថាប័នដែលគ្រប់គ្រង ត្រួតពិនិត្យ និង ផ្តល់អាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្មទៅដល់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន។ ដូចនេះ ប្រសិនបើមានការប្រកបអាជិវកម្ម ដោយពុំមានអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្មនោះទេ បញ្ហាមួយចំនួនកើតឡើងដូចជាការវាយតម្លៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន មានតម្លៃទាបជាងទីផ្សារ ការទទួលប្រាតិភោគដោយអនុប្បទាននូវទ្រព្យដែលបានមកពីចោរកម្ម (មានព័ត៌មាននៅក្នុងឧបសម្ព័ន្ធទី៣) ការយកអត្រាការប្រាក់ខ្ពស់ហួសហេតុ ឬ កាត់យក ការប្រាក់ជាមុន ការលួចផ្លាស់ប្តូរសមាសភាគខ្លះ នៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន (ភាគច្រើនកើតទៅលើយានយន្ត និងគ្រឿងអេឡិចត្រូនិច ដោយការលួចផ្លាស់ប្តូរផ្នែកខ្លះ ជំនួសដោយគ្រឿងបន្លាស់ដែលមានគុណភាពមិនល្អ) ការប្រើប្រាស់ទ្រព្យម្ចាស់សិទ្ធិដោយគ្មានការអនុញ្ញាត មិនមានទម្រង់កិច្ចសន្យា (ទម្រង់ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[៦៦] ) ច្បាស់លាស់ដែលអាច ធ្វើឲ្យខាតប្រយោជន៍អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន (មានរូបភាពនៅក្នុងឧបសម្ព័ន្ធទី៤) និងបញ្ហាមិនបានបង់ពន្ធចូលរដ្ឋ។

ដូចនេះ ការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយពុំមានអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទាន ផ្តល់ផលប៉ះពាល់ដល់សង្គមខ្លាំងណាស់។ បញ្ហាការប្រកបអាជីវកម្មដោយពុំមានអាជ្ញាបណ្ណនេះ អាចធ្វើទៅបានដោយសារតែមានបញ្ហាអំពើពុករលួយ និង/ឬ ច្បាប់មិនមានបច្ចុប្បន្នភាព។ ជាដំណោះស្រាយប្រទេសមួយចំនួនបានប្រើប្រាស់យន្តការលើក ទឹកចិត្តឲ្យប្រជាជនផ្តល់ដំណឹងអំពីការប្រព្រឹត្តបទល្មើស ដោយការផ្តល់រង្វាន់លើកទឹកចិត្តមួយចំណែក ដែលបានមកពីការពិន័យទៅលើជនល្មើស។ ជាក់ស្តែង ចំពោះសហរដ្ឋអាមេរិកផ្តល់រង្វាន់លើកទឹកចិត្ត មិនលើសពី ៣០% នៃប្រាក់ពិន័យ (អាស្រ័យទៅ

៦៦.មាត្រា ៨៣២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

តាមកត្តាផ្សេងៗតាមឆន្ទានុសិទ្ធិរបស់តុលាការ) សម្រាប់ជនដែលបានរាយការណ៍អំពីបទល្មើស[៦៧] ។ បន្ថែមពីនេះទៀតជនដែលបានរាយការណ៍អំពីបទ ល្មើសអាចមានសិទ្ធិក្នុងការបង្ហាញ ឬ មិនបង្ហាញអត្តសញ្ញាណរបស់ខ្លួនផងដែរ[៦៨] ។

### កថាភាគទី៥. អត្រាការប្រាក់កំណត់ដោយច្បាប់

ប្រសិនបើភាគីនៃកិច្ចសន្យាយល់ព្រមលើអត្រាការប្រាក់នៅក្នុងកិច្ចសន្យាអត់ការប្រាក់ដែលត្រូវអនុវត្តគឺជាអត្រាការប្រាក់ក្នុងកិច្ចសន្យា។ ចំពោះការខ្ចីបរិភោគធម្មតា អត្រាការប្រាក់ គឺត្រូវបានព្រមព្រៀងដោយភាគី។

ក្នុងករណីដែលភាគីនៃកិច្ចសន្យា បានយល់ព្រមថាអត្រាការប្រាក់នឹងត្រូវបង្កើតឡើង ប៉ុន្តែមិនបានសម្រេចអំពីអត្រាការប្រាក់ទេ អត្រាការប្រាក់ត្រូវគិតចំនួន ៥ ភាគរយក្នុងមួយឆ្នាំដែលជាអត្រាការប្រាក់ដែលកំណត់ដោយច្បាប់[៦៩] ។

អត្រាការប្រាក់ក្នុងកិច្ចសន្យា អាចសម្រេចបានដោយសេរី រវាងភាគីនៃកិច្ចសន្យា។ ទោះបីជាយ៉ាងនេះក៏ដោយ បើសិនជាដាក់ការប្រាក់ខ្ពស់ពេក កូនបំណុលក៏មិនអាចមានលទ្ធភាពសងដែរ ដូច្នេះក្នុងប្រទេសជាច្រើនគេមានច្បាប់ស្តីពីការកម្រិតអត្រាការប្រាក់។ បើទោះបីជាច្បាប់ស្តីពីការកម្រិតអត្រាការប្រាក់មិនមានក៏ដោយ កិច្ចសន្យាដែលកំណត់ អត្រាការប្រាក់ត្រូវទុកជាមោឃៈ នៅពេលដែលកិច្ចសន្យាផ្ទុយ នឹងសណ្តាប់ធ្នាប់ សាធារណៈ និងទំនៀមទម្លាប់ល្អ[៧០] ។

តាមមាត្រា ១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១ បានកំណត់ថាអត្រាការប្រាក់ដែលត្រូវបានកម្រិតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រឹមអត្រាចាប់ពី ១០% ដល់ ៣០% ឆ្នាំ ក្នុង ១ឆ្នាំ[៧១] ។

ប្រការ១នៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត ឆ្នាំ២០១១ បានចែងថាអត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលបានកំណត់កថាខណ្ឌទី ១ នៃមាត្រា ១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី ១៨% ក្នុង១ឆ្នាំ[៧២] ។

យោងតាមសេចក្តីប្រកាសព័ត៌មាន ស្តីពីការដាក់ពិដានអត្រាការប្រាក់ឥណទាន របស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧.០១៧,១០៩ ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ បានសម្រេចដាក់ពិដានអត្រាការប្រាក់ទៅ

៦៧. ប្រការ១៣ .៤ ស្តីពីការប្រកាសអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន, ឆ្នាំ២០១៧

៦៨. theo Nyrerod and Giancarlo Spagnolo, "A fresh look at whistlebiower Rewarda," SSRN Electronic journal,2021

៦៩. មាត្រា ៣១៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៧០. មាត្រា ៣៥៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៧១. មាត្រា ១៧ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១

៧២. ប្រការ១ ប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត ឆ្នាំ២០១១

លើឥណទានមានកម្រិត ១៨% ក្នុង១ឆ្នាំ ហើយនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ នេះតទៅជាកំហិត ។ការដាក់ពិដានឥណទាននេះ គឺជាការដាក់កម្រិតអតិបរមានៃអត្រាការប្រាក់ឥណទាន ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងអស់ អាចកំណត់យកពីអតិថិជនដែលខ្ចីប្រាក់ពីគ្រឹះស្ថាន[៧៣] ។

លើសពីនេះ អត្រាការប្រាក់ក្នុងកិច្ចសន្យាត្រូវកំណត់ផ្អែកលើអត្រាការប្រាក់ប្រចាំឆ្នាំ ប៉ុន្តែក្នុងករណីដែលការប្រាក់ត្រូវបានកំណត់តាមការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យា ភាគីនៃកិច្ចសន្យាអាចព្រមព្រៀងគ្នាថាតើការប្រាក់ត្រូវបង្កើតឡើងជារៀងរាល់ឆ្នាំ រៀងរាល់ខែ ឬ រៀងរាល់ថ្ងៃ ។

### កថាភាគទី៦. បញ្ហាអត្រាការប្រាក់ខ្ពស់ហួសកម្រិត

តាមទិន្នន័យនៃការស្រង់មតិ ដែលមានអ្នកឆ្លើយតបចំនួន ៣៣រូប បានផ្តល់ចម្លើយទាក់ទិននឹងអត្រាការប្រាក់ការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន បានបញ្ជាក់នូវព័ត៌មានដូចខាងក្រោម៖ ទិន្នន័យដែលទទួលបានអាចបង្ហាញឲ្យឃើញថា អត្រាការប្រាក់មធ្យមដែលទទួលគឺ៤.៦% ក្នុងមួយខែ ឬ ប្រមាណ ៥៥% ក្នុងមួយឆ្នាំ ដែលជាអត្រាការប្រាក់ខ្ពស់ខ្លាំងធៀបនឹងអត្រាការប្រាក់ ដែលត្រូវបានកម្រិតចំពោះកិច្ចសន្យាខ្ចីបរិភោគ និងអត្រាការប្រាក់ពិដានចំពោះឥណទានរបស់ធនាគារជាតិ ១៨% ក្នុងមួយឆ្នាំដែលខុសគ្នាប្រមាណ៣ដង។ បញ្ហានេះអាចបណ្តាលមកពីការប្រកបអាជីវកម្ម ប្រាតិភោគដោយអនុប្បទានមិនមានអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្ម ពុំមានភាពច្បាស់លាស់លើបទប្បញ្ញត្តិទាក់ទងការកម្រិតអត្រាការប្រាក់ និង ពុំមានច្បាប់ដាក់ទណ្ឌកម្មទៅលើការយកអត្រាការប្រាក់ហួសកម្រិត។

បញ្ហាការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយមិនមានអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្ម អាចបណ្តាលឲ្យមានការពុំអាចត្រួតពិនិត្យបានដោយមអាជ្ញាធរមានសមត្ថកិច្ច។ ចំពោះការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានស្របច្បាប់ តម្រូវឲ្យម្ចាស់សិទ្ធិធ្វើការផ្តល់របាយការណ៍ទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការផ្តល់របាយការណ៍នេះអាចធ្វើឲ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានទិន្នន័យព័ត៌មានគ្រប់គ្រងក្នុងការដោះស្រាយបញ្ហាអត្រាការប្រាក់ខ្ពស់ហួសកម្រិតនេះផងដែរ។

ទាក់ទិននឹងបញ្ហាពុំមានភាពច្បាស់លាស់លើបទប្បញ្ញត្តិ ទាក់ទងការកម្រិតអត្រាការប្រាក់ដូចដែលបានរៀបរាប់ក្នុងទ្រឹស្តីខាងលើ បទប្បញ្ញត្តិរបស់កម្ពុជាទាក់ទងនឹងអត្រាការប្រាក់ពុំមានភាពច្បាស់លាស់ថាអត្រាការប្រាក់ដែលត្រូវបានកម្រិតអាចអនុវត្តបានតែចំពោះកិច្ចសន្យាខ្ចីបរិភោគ ឬ កិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាននោះទេ។ប្រសិនបើអត្រាការប្រាក់ដែលត្រូវបានកម្រិតនេះ ត្រូវអនុវត្តទៅលើកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ហេតុអ្វីបានជាក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអនុញ្ញាតឲ្យមានការផ្សព្វផ្សាយអត្រាការប្រាក់រហូតពី ១.៩% ក្នុងមួយខែ[៧៤] ឬ ២២.៨% ក្នុងមួយឆ្នាំរហូតដល់ ៥% ក្នុងមួយខែ[៧៥] ឬ ៦០% ក្នុងមួយឆ្នាំចំពោះហាងបញ្ចាំ និងប្រាតិភោគដោយអនុប្បទានមួយចំនួន ( ដូចរូបភាពនៅក្នុងឧបសម្ព័ន្ធទី៤)

៧៣. យោងតាមសេចក្តីប្រកាសព័ត៌មានស្តីពីដាក់ពិដានអត្រាការប្រាក់ឥណទានរបស់ធនាគារជាតិនៃកម្ពុជា , ឆ្នាំ២០១៧

៧៤. https://www.cashuup.com

៧៥. https://www.cashuup.com/news-events/pawn-shop-rise-proves-quick-fix/

ដែលជាហាងដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ព្រោះកថាខណ្ឌទី៣ មាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ កំណត់ចែងថា កិច្ចសន្យាដែល កំណត់លើសពីកម្រិតនៃអត្រាការប្រាក់នោះ ត្រូវទុកជាមោឃៈ។ ដូចនេះ ក្នុងនាមជាស្ថាប័នរដ្ឋ ក៏ដូចជាស្ថាប័នដែលមានសមត្ថកិច្ចទៅលើការប្រាក់នេះ។

ចំណែកបញ្ហាកម្ពុជាពុំមានច្បាប់ដាក់ទណ្ឌកម្មទៅការយកអត្រាការប្រាក់ហួសកម្រិត ជាកត្តាចម្បងដែលបង្កឲ្យមានការយកអត្រាការប្រាក់ខ្ពស់ពីសំណាក់ម្ចាស់បំណុល ឬ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន។ ជាក់ស្តែងកម្ពុជាបច្ចុប្បន្នពុំទាន់មានច្បាប់នេះនៅឡើយ ខណៈដែលប្រទេសមួយចំនួនបានប្រើប្រាស់យន្តការដាក់ទណ្ឌកម្មទៅលើម្ចាស់បំណុលដែលយកការប្រាក់ហួសកម្រិត។ ជាក់ស្តែង មាត្រា ៥ ច្បាប់ទាក់ទងនឹងការទទួលយកការវិនិយោគការគ្រប់គ្រងប្រាក់បញ្ញើនិងអត្រាការប្រាក់ឆ្នាំ១៩៨៥ របស់ប្រទេសជប៉ុនបញ្ញត្តិកំណត់ទណ្ឌកម្មទាក់ទងនឹងការយកអត្រាការប្រាក់លើស កម្រិត អាចមានទណ្ឌកម្មដាក់ពន្ធនាគាររហូតដល់ ៥ឆ្នាំ[៧៦] ។ ចំណែកព្រះរាជាណាចក្រកម្ពុជាថៃ មាត្រា ៤ ច្បាប់ស្តីពីការហាមមិនឲ្យយកអត្រាការប្រាក់លើសកំណត់ ឆ្នាំ ២០១៧ មានកំណត់ទណ្ឌកម្មទៅលើជនដែលយកអត្រាការប្រាក់លើសពីអត្រាការប្រាក់ដែលច្បាប់បានកំណត់ អាចត្រូវដាក់ពន្ធនាគារមិនលើសពី ២ឆ្នាំ ឬ ពិន័យជាប្រាក់មិនលើសពី ពីរសែនបាត ឬ ទាំងដាក់ពន្ធនាគារ និងពិន័យជាប្រាក់ ។

## កថាភាគទី៧.បញ្ហាការគត់ត្រាព័ត៌មានប្រាតិភោគដោយអនុប្បទាននិងការប្រមូលពន្ធ

### ក. ភាពមិនអាចត្រួតពិនិត្យបាននូវព័ត៌មានប្រាតិភោគដោយអនុប្បទាន

ជាការពិតណាស់ ការអនុវត្តអាជីវកម្មប្រាតិភោគដោយអនុប្បទានមិនស្របច្បាប់ អាចធ្វើឲ្យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពុំអាចត្រួតពិនិត្យទៅលើព័ត៌មាន ឬ របាយការណ៍ទាក់ទិននឹងប្រាតិភោគដោយអនុប្បទានបាននោះឡើយ។ប្រការនេះអាចបង្កឲ្យមានបញ្ហាដូចដែលបានអធិប្បាយនៅក្នុងចំណុចការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយពុំមានអាជ្ញាបណ្ណខាងលើ ជាពិសេសពាក់ព័ន្ធនឹងបញ្ហាអត្រាការប្រាក់ និងទ្រព្យដែលបានមកអំពីចោរកម្ម។

ថ្វីបើអាជីវកម្មប្រាតិភោគដោយអនុប្បទានមួយចំនួនបានទទួលអាជ្ញបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏ពិតមែន ប៉ុន្តែបញ្ហាខាងលើក៏នៅតែអាចកើតមានឡើងបានផងដែរ ដោយសារភាពដែលអាចកើតឡើងនៃការរាយការណ៍អំពី ព័ត៌មានមិនពិតរបស់អាជីវកម្មប្រាតិភោគដោយអនុប្បទាន ក៏ដូចជាភាពលំបាកក្នុងការធ្វើសវនកម្មទៅលើរបាយការណ៍ផងដែរ។

### ខ. បញ្ហាទាក់ទិននឹងការប្រមូលពន្ធ

ក៏ដូចជាបញ្ហាខាងលើផងដែរ នាពេលដែលភាពមិនអាចត្រួតពិនិត្យបាននូវព័ត៌មាននៃប្រាតិភោគដោយអនុប្បទាន ការប្រមូលពន្ធទៅលើអាជីវកម្មប្រាតិភោគដោយអនុប្បទានក៏ពុំមានប្រសិទ្ធភាព ផងដែរដែលជាហេតុធ្វើឲ្យបាត់បង់នូវចំណូលជាតិមួយផ្នែកថែមទៀតផងដែរ។ The Organization for Economic

៧៦. មាត្រា ៥ ច្បាប់ការទទួលយកការវិនិយោគ ការគ្រប់គ្រងប្រាក់បញ្ញើ និងអត្រាការប្រាក់ ប្រទេសជប៉ុន ឆ្នាំ១៩៨៥

Cooperation Development (អង្គការដើម្បីសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច) ( OECD 2017 )[៧៧] អធិប្បាយថា "ការគេចវេស និងការបន្លំពន្ធ (Tax Evasion and Tax Fraud) គឺជា អំពើខុសច្បាប់ និងជាអំពើបង្ហាញចេតនាប្រព្រឹត្តអំពីភាពមិនត្រឹមត្រូវចំពោះការបំពេញកាតព្វកិច្ចពន្ធ ។ អំពើនេះពាក់ព័ន្ធនឹងការប្រព្រឹត្តដោយចេតនានូវការមិនបង្ហាញ ឬ ការក្លែងបន្លំនៃប្រាក់ចំណូល ឬ ប្រាក់ចំណេញចំពោះអាជ្ញាធរពន្ធដារ។ ការគេចពន្ធ និងការបន្លំពន្ធអាចត្រូវធ្វើឡើងក្រោម ៣រូបភាព គឺការរាយការណ៍ចំណូលមិនបានត្រឹមត្រូវ ដោយការរាយការណ៍ចំណូលតិចជាងការពិត ការរាយការណ៍ចំណាយហួសការពិតតាមរយៈ វិក្កយបត្រក្លែងក្លាយការប្រកបធុរកិច្ចជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

## កថាភាគទី៨. ការប្រើប្រាស់បច្ចេកវិទ្យាជំនួយក្នុងការប្រមូលព័ត៌មាន

ដោយតាមបច្ចេកវិទ្យា ICT (Information and Communication Technology) គឺជាបច្ចេកវិទ្យាទំនាក់ទំនងទាំងអស់រួមមានបច្ចេកវិទ្យាអ៊ីនធើណេត និងបណ្តាញឥតខ្សែកម្មវិធីដែលប្រើប្រាស់នៅក្នុងទូរស័ព្ទដៃ ឬ កុំព្យូទ័រ កម្មវិធី និងសេវាកម្មគ្រប់គ្រងប្រព័ន្ធទិន្នន័យដទៃទៀត ដែលអាចឲ្យប្រើប្រាស់អាចចូលប្រើទាញយក រក្សាទុក បញ្ជូន និងរៀបចំទិន្នន័យព័ត៌មានតាមប្រព័ន្ធឌីជីថល។ ការប្រើប្រាស់បច្ចេក វិទ្យា ICT ជំនួសក្នុងការប្រមូលព័ត៌មាននេះ អាចធ្វើឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានភាពងាយស្រួលក្នុងការតាមដាននូវរាល់បញ្ហាដែលកើតមានខាងលើ។ បន្ថែមពីនេះទៅទៀត ការប្រើប្រាស់បច្ចេកវិទ្យា ICT ការប្រើប្រាស់បច្ចេកវិទ្យាខាងលើអាចជាដំណោះស្រាយ ដែលទាក់ទងនឹងប្រាតិភោគដោយអនុប្បទានដូចជាការវាយតម្លៃដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានមានតម្លៃទាបជាងទីផ្សារ ការទទួលប្រាតិភោគដោយអនុប្បទាននូវទ្រព្យដែលបានមកអំពីចោរកម្ម និង ការយកអត្រាការប្រាក់ខ្ពស់ហួសហេតុ។

ការប្រើប្រាស់បច្ចេកវិទ្យា ICT ជំនួយក្នុងការអនុវត្តខាងលើ អាចជាជំនួយឲ្យអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានដឹងថា អាជីវកម្មប្រាតិភោគដោយអនុប្បទានដែលខ្លួនបានប្រើប្រាស់នោះជាអាជីវកម្មស្របច្បាប់ឬទេ។ បន្ថែមពីលើនេះទៅទៀត ការប្រើប្រាស់បច្ចេកវិទ្យា ICT ជំនួយនេះអាចផ្តល់ឲ្យរាជរដ្ឋាភិបាលក៏ដូចជាស្ថាប័នពាក់ព័ន្ធអាចយកទិន្នន័យនេះមកវិភាគ និងកំណត់នយោ បាយក្នុងការដោះស្រាយនូវបញ្ហាដែលពាក់ព័ន្ធដែលបានរៀបរាប់នាផ្នែកខាងលើផងដែរ។

## កថាភាគទី៩. ដំណោះស្រាយទាក់ទិននឹងការប្រមូលព័ត៌មាន

ការប្រើប្រាស់បច្ចេកវិទ្យា ICT ជំនួយក្នុងការប្រមូលព័ត៌មានខាងលើ ក៏អាចធ្វើឲ្យស្ថាប័នពន្ធដារទទួលបាននូវទិន្នន័យប្រាក់ចំណូលរបស់អាជីវកម្មប្រាតិភោគដោយអនុប្បទានដែលជាកត្តាសំខាន់ ក្នុងប្រសិទ្ធភាពនៃការប្រមូលពន្ធ ក៏ដូចជាការកាត់បន្ថយអំពើពុករលួយក្នុងការប្រមូលពន្ធថែមទៀតផងដែរ។ ការប្រមូលពន្ធឲ្យមានប្រសិទ្ធិភាពនេះ ក៏អាចផ្តល់ឲ្យមានការប្រកួតប្រជែងដោយស្មើភាព ព្រមទាំងអាចបង្កើនប្រាក់ចំណូលដល់រដ្ឋាភិបាលថែមទៀតផង។

៧៧. https://www.oecd.org/tax/crime/technology-tools-to--tackle-tax-evasion-and-tax-fraud.pdf

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវសរសេរបកស្រាយខាងលើនេះរួចមកឃើញថាព្រះរាជាណាចក្រកម្ពុជាមានច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងទៅនឹងសិទ្ធិប្រាតិភោគដោយអនុប្បទានក៏ដោយ ប៉ុន្តែការអនុវត្តជាក់ស្តែងនៃប្រាតិភោគដោយអនុប្បទាននៅកម្ពុជាក៏នៅតែមានបញ្ហាចោទជាច្រើន ។ ទាក់ទិនទៅនឹងបញ្ហាកម្រិតការយល់ដឹងរបស់ប្រជាជនកម្ពុជាទៅលើប្រាតិភោគដោយអនុប្បទាន ប្រជាជនកម្ពុជាដែលមានការយល់ដឹងអំពីប្រាតិភោគដោយអនុប្បទាននៅមានកម្រិតទាបត្រឹមតែ ១៣% ដែលនេះអាចបញ្ជាក់បានថា ប្រជាជនកម្ពុជាភាគច្រើន ពុំមានចំណេះដឹងទាក់ទងនឹងប្រាតិភោគដោយអនុប្បទាននោះឡើយ។ ម្យ៉ាងវិញទៀត ប្រជាជនកម្ពុជាប្រមាណ ៩០% មានការភាន់ច្រឡំរវាងប្រាតិភោគដោយអនុប្បទាន ដែលជាហេតុធ្វើឱ្យមានភាពចន្លោះប្រហោងនៃការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិ ។ រីឯការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយពុំមានអាជ្ញាបណ្ណបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការអនុវត្តប្រាតិភោគដោយអនុប្បទាន ទោះបីជាមានបទបញ្ញត្តិកំណត់រួចហើយក្តី ។ ចំណែកឯអត្រាការប្រាក់ដែលបានអនុវត្តជាក់ស្តែងចំពោះប្រាតិភោគដោយអនុប្បទាននាពេលបច្ចុប្បន្នមានអត្រាជាមធ្យម ៤.៦% ក្នុងមួយខែខណៈដែលហាងប្រាតិភោគដោយអនុប្បទានមួយចំនួន បានផ្សព្វផ្សាយអត្រាការប្រាក់ចន្លោះពី ១.៩% ក្នុងមួយខែ ឬ ២២.៨% ក្នុងមួយឆ្នាំរហូតដល់ ៥% ក្នុងមួយខែ ឬ ៦០% ក្នុងមួយឆ្នាំដែលជាអត្រាការប្រាក់ខ្ពស់ហួសកម្រិត ។ ចំពោះការកត់ត្រាព័ត៌មានទាក់ទិននឹងប្រាតិភោគដោយអនុប្បទាន រួមនឹងការប្រមូលពន្ធនៅតែចោទជាបញ្ហាផងដែរដោយសារតែភាពមិនទាន់សម័យនៃការកត់ត្រាព័ត៌មាន ដែលជាហេតុធ្វើឱ្យមានភាពលំបាកក្នុងការធ្វើសវនកម្មទៅលើផ្នែកពន្ធដូចគ្នា។

បញ្ហាកម្រិតយល់ដឹងរបស់ប្រជាជនកម្ពុជា ក៏ដូចជាបញ្ហាការភាន់ច្រលំរវាងការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន បានក្លាយជាមូលហេតុដែលធ្វើឱ្យមានការអនុវត្តសិទ្ធិហួសហេតុពីសំណាក់ម្ចាស់សិទ្ធិ។ ក្នុងការអនុវត្តជាក់ស្តែងបានយកគោលការណ៍នៃប្រាតិភោគដោយអនុប្បទានមកប្រើប្រាស់ជំនួសគោលការណ៍នៃសិទ្ធិលើការបញ្ចាំដែលគោលការណ៍នៃសិទ្ធិលើការបញ្ចាំ ទាមទារឱ្យឆ្លងកាត់នីតិវិធីតុលាការក្នុងការចាត់ចែងលើវត្ថុដែលជាកម្មវត្ថុ និងនីតិវិធីវង្វាយតម្លៃវត្ថុ ។ ការអនុវត្តខុសគោលការណ៍ខាងលើនេះ ក៏អាចផ្តល់ឱកាសឱ្យម្ចាស់សិទ្ធិអាចធ្វើការវាយតម្លៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានទាបជាងទីផ្សារ ដែលជាហេតុធ្វើឱ្យខាតប្រយោជន៍របស់អ្នកបង្កើតសិទ្ធិផងដែរ។ទាក់ទិននឹងបញ្ហាការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយពុំមានអាជ្ញាបណ្ណ បានក្លាយជាឧបសគ្គដ៏ចម្បងក្នុងការអនុវត្តអនុវត្តប្រាតិភោគដោយអនុប្បទានឱ្យមានតម្លាភាពផងដែរ ដោយសារតែអំពើពុករលួយ និងច្បាប់ពុំមានបច្ចុប្បន្នភាព។ ។បញ្ហាអំពើពុករលួយអាចបង្កមកអំពីការពុករលួយរបស់ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ(ថ្នាក់មូលដ្ឋាន)។ ទាំងអំពើពុករលួយរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ថ្នាក់មូលដ្ឋាន) សុទ្ធកើតឡើងដោយសារទំនាក់ទំនងក្រៅផ្លូវការរវាងអាជ្ញាធរមូលដ្ឋានជាមួយនឹងជនទុច្ចរិត ដែលអាចជាការប្រើប្រាស់ខ្សែស្រឡាយ ឬ ការស៊ីសំណូកសូកប៉ាន់។ រីឯបញ្ហាភាពមិនមានបច្ចុប្បន្នភាពនៃច្បាប់កើតឡើងដោយសារកម្ពុជាពុំទាន់មានធនធានមនុស្សគ្រប់គ្រាន់ ក៏ដូចជាភាពមិនទាន់

សម័យរបស់ច្បាប់ធៀបនឹងបច្ចេកវិទ្យាដែលរីកចម្រើនឥតឈប់ឈរ។ បញ្ហាអំពើពុករលួយ និង បច្ចុប្បន្នភាពនៃច្បាប់បានក្លាយជាឧបសគ្គយ៉ាងខ្លាំងដល់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយនូវបញ្ហាដែលទាក់ទងនឹងប្រាតិភោគដោយអនុប្បទាន។

ចំពោះបញ្ហាអត្រាការប្រាក់ដែលខ្ពស់ហួសកម្រិត គឺបានផ្តល់ផលប៉ះពាល់ទៅដល់សង្គមយ៉ាងខ្លាំង បេះដាហេតុធ្វើ ឱ្យមានការកំណត់អត្រាការប្រាក់អតិបរមាឡើង ។ " អត្រាអតិបរមាដែលត្រូវបានកម្រិតដោយច្បាប់ មានគោលដៅការពារអតិថិជន ការពារអ្នកខ្ចីដែលមិនបានចាប់អារម្មណ៍ « ទៅលើកិច្ចសន្យា » មិនមានចំណេះដឹងគ្រប់គ្រាន់ក្នុងការវិភាគ ឬ អតិថិជនដែលកំពុងមានបញ្ហាហិរញ្ញវត្ថុ ដោយការពារជនទាំងនោះអំពីផលវិបាកអវិជ្ជមាននៃប្រាក់កម្ចី ដែលនឹងបង្កជាគ្រោះថ្នាក់នៅថ្ងៃអនាគត] ។ « បញ្ហាអត្រាការប្រាក់ខ្ពស់ហួសកម្រិតនេះ បណ្តាលមកអំពីភាពមិនច្បាស់លាស់លើបទប្បញ្ញត្តិទាក់ទងការកម្រិតអត្រាការប្រាក់ ក៏ដូចជាពុំមានច្បាប់ដែល ដាក់ទណ្ឌកម្មទៅលើការយកអត្រាការប្រាក់ហួសកម្រិត»។ បញ្ហាការកត់ត្រាព័ត៌មានទាក់ទិននឹងប្រាតិភោគដោយអនុប្បទាន រួមនឹងការប្រមូលពន្ធបានកើតឡើងដោយសារការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយពុំមានអាជ្ញាបណ្ណ និងការរាយការណ៍អំពីព័ត៌មានរបាយការណ៍មិនពិតប្រាកដរបស់ម្ចាស់អាជីវកម្មប្រាតិភោគដោយអនុប្បទានដែលមានអាជ្ញាបណ្ណ។ ប្រការទាំងពីរនេះ អាចបង្កភាពលំបាកក្នុងការធ្វើសវនកម្មទៅលើរបាយការណ៍ ដោយសារអាជីវកម្មប្រាតិភោគដោយអនុប្បទានពុំមានស្វ័យប្រវត្តិកម្មក្នុងការកត់ត្រាព័ត៌មាន។ ទាក់ទិននឹងរបាយការណ៍នេះផងដែង ក៏បានផ្តល់ផលប៉ះពាល់យ៉ាងជាក់ស្តែងទៅលើការប្រមូលទិន្នន័យ វិភាគទិន្នន័យ ក៏ដូចជាស្វែងរកនូវដំណោះស្រាយបញ្ហាផងដែរ ។ បន្ថែមពីនេះទៀត បញ្ហាការកត់ត្រាព័ត៌មានទាក់ទិននឹងប្រាតិភោគដោយអនុប្បទាន ក៏បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើប្រសិទ្ធភាព និងតម្លាភាពនៃការប្រមូលពន្ធថែមទៀតផង ដោយសារតែភាពលំបាកនៃការធ្វើសវនកម្មទៅលើប្រាក់ចំណូល និងចំណាយរបស់ម្ចាស់សិទ្ធិ ។

# អនុសាសន៍

រវាងការភាន់ច្រលំការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន រួមទាំងកម្រិតយល់ដឹងរបស់ប្រជាជនចំពោះប្រាតិភោគដោយអនុប្បទាននៅមានកម្រិតទាប រដ្ឋាភិបាល ជាពិសេសក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គប្បីសិក្សាធ្វើការសម្រង់មតិ និងរៀបចំគោលនយោបាយក្នុងការផ្សព្វផ្សាយច្បាប់។ គោលនយោបាយនេះ អាចធ្វើទៅបានតាមរយៈការរៀបចំចងក្រងសៀវភៅអប់រំគោលការណ៍ច្បាប់មួយចំនួនដែល ត្រូវបានប្រើប្រាស់សម្រាប់ការប្រកបជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន រួមទាំងបទប្បញ្ញត្តិដែលទាក់ទិននឹង ប្រាតិភោគដោយអនុប្បទានផងដែរ។ សៀវភៅនេះដែរ គប្បីរៀបរៀងដោយប្រើប្រាស់ភាសាសាមញ្ញងាយយល់ ឱ្យសមស្របទៅនឹងកម្រិតយល់ដឹងរបស់ប្រជាជន ដោយបញ្ចូលទៅក្នុងកម្មវិធីសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ ឬថ្នាក់ឆ្នាំមូលដ្ឋានសម្រាប់និស្សិតមហាវិទ្យាល័យ ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការយល់ដឹងច្បាប់ និងអាចអនុវត្ត បានក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន។ទាក់ទិនទៅនឹងបញ្ហាការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយពុំមានអាជ្ញាបណ្ណ រដ្ឋាភិបាល និងស្ថាប័ននីតិបញ្ញត្តិ គួរគប្បីសិក្សាដោះស្រាយបញ្ហានេះដោយបង្កើតយន្តការក្នុងការត្រួតពិនិត្យទៅ លើបទល្មើសដែលពាក់ព័ន្ធនឹងការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយពុំមានអាជ្ញាបណ្ណ ឬ មិនស្របនឹងច្បាប់។ យន្តការនេះដែរ អាចប្រើប្រាស់គោលការណ៍បង្កើតជាបទប្បញ្ញត្តិ ឬច្បាប់ដែលអាចលើកទឹក ចិត្តឱ្យប្រជាជនផ្តល់ដំណឹង ឬ រាយការណ៍អំពីការប្រព្រឹត្តបទល្មើស ដោយបង្កើតឱ្យមានការផ្តល់ជាប្រាក់រង្វាន់លើកទឹកចិត្តចំពោះប្រជាជនដែលរាយការណ៍អំពីការប្រព្រឹត្តបទល្មើស ក៏ដូចជាធានានូវសុវត្ថិភាព និងអត្តសញ្ញាណ របស់អ្នករាយការណ៍ផងដែរ ។

អត្រាការប្រាក់ខ្ពស់ហួសកម្រិតអាចត្រូវបានដោះស្រាយដោយស្ថាប័នពាក់ព័ន្ធ ដែលរួមមានក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។ ស្ថាប័នពាក់ព័ន្ធទាំងអស់នេះគប្បីសិក្សាបកស្រាយបន្ថែម ទៅលើបញ្ហាអត្រាការប្រាក់ដែលត្រូវបានកម្រិត។ បន្ថែមពីនេះទៀត ស្ថាប័នមានសមត្ថកិច្ចអាចធ្វើការសិក្សាទៅលើសេចក្តីព្រាងច្បាប់ទាក់ទិននឹងការដាក់ទណ្ឌកម្មទៅលើការយកអត្រាការប្រាក់ហួសកម្រិត មកពិចារណាក្នុងការគ្រប់គ្រង និងទប់ស្កាត់បញ្ហានេះ។ បញ្ហាការកត់ត្រាព័ត៌មានប្រាតិភោគដោយអនុប្បទាន និងការប្រមូលពន្ធ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គប្បីធ្វើការសិក្សាស្រាវជ្រាវក្នុងការជ្រើសរើសបច្ចេកវិទ្យា ICT ដែលមានពាក្យពេញ (Information and Communication Technology) ក៏ដូចជាប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មដែលអាចកត់ត្រាទិន្នន័យរបស់ហាងបញ្ចាំ ឬប្រាតិភោគដោយអនុប្បទានមកប្រើប្រាស់។ បច្ចេកវិទ្យាទាំងពីរខាងលើ អាចធានានូវតម្លាភាពចំពោះការកត់ត្រាព័ត៌មាន ដែលអាចត្រួតពិនិត្យដោយបុគ្គលពាក់ព័ន្ធការជំនួយក្នុងការដោះស្រាយវិវាទ ក៏ដូចជាជំនួយក្នុងការប្រមូលពន្ធផងដែរ ។ បន្ថែមពីលើការដោះស្រាយបញ្ហាការកត់ត្រាព័ត៌មានប្រាតិភោគដោយអនុប្បទាន និងការប្រមូលពន្ធបច្ចេកវិទ្យាទាំងពីរនេះដែរក៏អាចប្រមូលយកនូវទិន្នន័យសម្រាប់ធ្វើការអភិវឌ្ឍន៍បទប្បញ្ញត្តិច្បាប់ ក៏ដូចជាវិភាគទៅលើប្រសិទ្ធភាពរវាងទ្រឹស្តីច្បាប់ និងការអនុវត្តជាក់ស្តែងបានផងដែរ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងបទដ្ឋានគតិយុត្តនៅកម្ពុជា

- ក្រមរដ្ឋប្បវេណី ២០០៧
- អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហេរញ្ញវត្ថុ លេខ ៤៨៨ អបក្រ.បក, ១៦ តុលា ២០១៣
- ប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន លេខ ០៣០ សហវ.ប្រក, ១៣ មករា ២០១៧ ។
- ប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត, លេខ ១២៨ កយ,ប្រក/១១,២១ ធ្នូ ២០១១
- ប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន លេខ ធ៧.០១៧.១០៩.ប្រក, ១៣ មីនា ២០១៧
- ៧១. យោងតាមសេចក្តីប្រកាសព័ត៌មានស្តីពីដាក់ពិដានអត្រាការប្រាក់ឥណទានរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧.០១៧.១០៩ ប្រ.ក ចុះថ្ងៃ១៣ ខែមីនា ឆ្នាំ ២០១៧ បានសម្រេចដាក់ពិដានអត្រាការប្រាក់ទៅលើឥណទានមានកម្រិត១៨%ក្នុង១ឆ្នាំ

## សៀវភៅ និងឯកសារផ្សេងៗ ជាភាសាខ្មែរ

- គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ២០០៧ សន្ទានុក្រមផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ។
- www.cashuup.com
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី
- សេចក្តីកំណត់ក្រមរដ្ឋប្បវេណី
- មេរៀន ភាគ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី សមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ
- វចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត
- មាត្រា ១៧ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១
- ប្រការ១ ប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត ឆ្នាំ២០១១
- 

## ឯកសារភាសាបរទេស

- Nyrerad, Theo, and Giancarlo Spagnolo. "A Fresh Look at Whistleblower Rewards ទៅលើប្រាក់រង្វាន់របស់អ្នករាយការណ៍ទៅកាន់សមត្ថកិច្ច....N Secrty Jurnal, S

- https://doi.org/10.2139/ssrn.38717481
- Population, Total - CAMBODIA Data. The World Bank Group, 2021. https://data.worldbank org/indicator/SP.POP TOTL Plocations-KH (Sangamarig og um 8089)
- Saeed, Ahmed Muneeb Publication. Cambodia, 2019-2023 nosive Pathways to a Compete Ey ប្រទេសកម្ពុជាសម្រាប់ឆ្នាំ២០១៩-២០២៣ មានឆ្ពោះទៅរកសេដ្ឋកិច្ចប្រកួតហៅផង Asia Development Bank (ADB), October 2019. https://www.adb.org/sites/default files institutional document/534691/cps-cam-2019-2023.pdf
- Technology Tools to Tackle Tax Evasion and Tax Fraud (surnugriaunganag inong Bammugng]. Organisation for Economic Co-operation and Development, 2017 https://www.oecd.org/tax/crime/technology-tools-to-tackle tax evasion-and-tax-raud.por
- Information and Cornmunication Technologies (ICT) [បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍]. The Agricultural Information Management Standards Portal (AIMS). Food and Agriculture Organization of United Nations. Accessed August 1, 2021. http://aims.fao.org/information and-communication-technologies-ict"
- Kothari, C.R. 2004. Research Methodology New Dehli: NEW AGE INTERNATIONAL1
- Ly, Sodeth. Cambodia Is Now a Lower-Middle Income ECONOMY: What Does This Mean? " World Bank Blogs. World Bank, August 11, 2016. https://blogs.worldbank.org/eastasiapacific/cambodia-is-now a-lower-middle-income-economy-what-does-this-mean (Stujsgmwige09 Jumbob)
- Madeira, Carlos. "The Impact of Interest RATE Ceilings on Households Credit Access: Evidence from a 2013 CHILEAN LEGISLATION ឥទ្ធិពលនៃពិដានអត្រាការប្រាក់លើការទទួលបានឥណទានសម្រាប់គ្រួសារ៖ ភស្តុតាងពីការបង្កើតច្បាប់នៅក្នុងប្រទេសឈីលីឆ្នាំ ២០១៣.″ Journal of Banking & Finance 106 (2019): 166-79. https://doi.org/10.1016/j.jbankfin 2019.06.0111
- Melzer, B., 2011. The real costs of credit access: evidence from the payday lending market [nly បង់នៃការទទួលបានឥណទាន៖ ភស្តុតាងពីទីផ្សារផ្តល់ប្រាក់កម្ចីសម្រាប់ថ្ងៃបើកប្រាក់ខែ, Q. J. En 126
- Moses, Lyria Bennett. "Adapting the Law to Technological Change: A Comparison of Common Law and Legislation - ការសម្របខ្លួននៃច្បាប់ទៅនឹងការផ្លាស់ប្តូររបស់បច្ចេកវិទ្យា ការប្រៀបធៀប Common Law Sumimuinannu The University of New South Wales Law Journal 26, no. 2 (2003): 394-417. https://search.informit.org/doi/10.3316/lelapa 116436844605657 ៗ

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០៣៣០......សហវ.ប្រក

## ប្រកាស
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្មធានារ៉ាប់រងបញ្ចាំ និងធានារ៉ាប់រងគ្រោះថ្នាក់គោគដោយអនុប្បទាន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៨/០២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណីឆ្នាំ២០០៨
- បានឃើញអនុក្រឹត្យលេខ៤៨៨អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ១៣៣០ សហវ.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងដូចខាងក្រោម÷

- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន
- ធានាសមធម៌ និងតុល្យភាពនៃផលប្រយោជន៍រវាងអ្នកដាក់បញ្ចាំ និងអ្នកទទួលទ្រព្យបញ្ចាំ
- បង្កើតឱ្យមានប្រព័ន្ធផ្គត់ផ្គង់សាច់ប្រាក់ឆាប់រហ័សដោយស្របច្បាប់ក្រៅពីប្រព័ន្ធធនាគារ
- រួមចំណែកទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានដើម្បីធានានូវសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់ យន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រង និងការត្រួតពិនិត្យប្រតិបត្តិការអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពពាក់ព័ន្ធនឹងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយ-អនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

ពាក្យបច្ចេកសព្ទដែលបានប្រើនៅក្នុងប្រកាសនេះត្រូវបានកំណត់ដូចខាងក្រោម÷

- **ក្រសួង** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **អគ្គនាយកដ្ឋាន** សំដៅដល់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **នាយកដ្ឋាន** សំដៅដល់នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុបញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គ-នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **មន្ទីរ** សំដៅដល់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត
- **អាជ្ញាបណ្ណ** សំដៅដល់លិខិតគតិយុត្តិដែលចេញដោយក្រសួង ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុន/សហគ្រាសណាមួយប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ
- **លិខិតអនុញ្ញាតប្រកបអាជីវកម្ម** សំដៅដល់លិខិតដែលចេញដោយមន្ទីរ ដើម្បីអនុញ្ញាតឱ្យ ក្រុមហ៊ុន/សហគ្រាសណាមួយប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចនៅក្នុងព្រះរាជាណា-ចក្រកម្ពុជាដោយស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ
- **អាជីវកម្មទទួលបញ្ចាំ** សំដៅដល់សកម្មភាពពាណិជ្ជកម្មដែលអតិថិជនយកទ្រព្យទៅដាក់បញ្ចាំ ដើម្បីទទួលបានប្រាក់កម្ចីដោយសន្យាទូទាត់សងប្រាក់ដើម និងការប្រាក់ទៅតាមកិច្ចសន្យាដែលបានកំណត់
- **អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន** សំដៅដល់សកម្មភាពពាណិជ្ជកម្មដែលអតិថិជនធ្វើអនុប្បទានសិទ្ធិលើចលនវត្ថុ របស់ខ្លួនជូនដល់អ្នកទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីទទួលបានប្រាក់កម្ចីដោយសន្យាទូទាត់សងប្រាក់ដើម និងការប្រាក់ទៅតាមកិច្ចសន្យាដែលបានកំណត់
- **អ្នកទទួលបញ្ចាំ** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលទ្រព្យបញ្ចាំពីក្រសួង/មន្ទីរ

- **អ្នកទទួលប្រាតិភោគដោយអនុប្បទាន** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលទ្រព្យប្រាតិភោគដោយអនុប្បទានពីក្រសួង/មន្ទីរ
- **អ្នកដាក់បញ្ចាំ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យទៅដាក់បញ្ចាំជាមួយអ្នកទទួលបញ្ចាំ ដើម្បីទទួលបានប្រាក់កម្ចី
- **អ្នកដាក់ប្រាតិភោគដោយអនុប្បទាន** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យទៅដាក់ប្រាតិភោគដោយ-អនុប្បទានជាមួយអ្នកទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីទទួលបានប្រាក់កម្ចី
- **ទ្រព្យ** សំដៅដល់ចលនវត្ថុ ឬអចលនវត្ថុដែលជាកម្មវត្ថុយកទៅដាក់បញ្ចាំ
- **លោះ** សំដៅដល់ការទទួលយកមកវិញនូវទ្រព្យដែលបានដាក់បញ្ចាំ ឬដែលបានដាក់ប្រាតិភោគដោយអនុប្បទានក្រោយពីបានសងប្រាក់ដើម (ប្រាក់កម្ចី) និងការប្រាក់គ្រប់ចំនួនទៅតាមកិច្ចសន្យាដែលបានកំណត់ជូនទៅអ្នកទទួលបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទានវិញ
- **កិច្ចសន្យា** សំដៅដល់កិច្ចសន្យាទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទានដែលធ្វើឡើងរវាងអ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន និងអ្នកទទួលបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន។

## ជំពូកទី២
## ស្ថាប័នគ្រប់គ្រង

**ប្រការ៥.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបញ្ញត្តិករក្នុងការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយ-អនុប្បទាន។ ក្រសួងមាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាសេនាធិការ។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត បំពេញតួនាទី និងភារកិច្ចសម្របសម្រួល និងគាំទ្រការងារគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ និង/ឬទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចនៅតាមរាជធានី-ខេត្ត ក្នុងនាមជាសេនាធិ-ការរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៣
## អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និង/ឬ ទទួលប្រាតិភោគដោយអនុប្បទាន

**ប្រការ៦.-**

រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតមធ្យម និងខ្នាតធំត្រូវមានអាជ្ញាបណ្ណពីក្រសួង។ ដើម្បីទទួលបានអាជ្ញាបណ្ណក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា (ចំពោះអាជីវកម្មខ្នាតធំកម្រិត២ត្រូវចុះបញ្ជីជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត)
- ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ
- ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១០%នៃដើមទុន
- អ្នកកាន់អាជ្ញាបណ្ណត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ក្នុងករណីអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុននិកត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម។

- ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវបានកំណត់ក្នុងពាក្យស្នើសុំអាជ្ញាបណ្ណរបស់ក្រសួង។

**ប្រការ៧.-**

រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចត្រូវមានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ។ ដើម្បីទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា
- ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ
- ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១០% នៃដើមទុន
- អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ក្នុងករណីអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុននិកត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម
- ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវបានកំណត់ក្នុងពាក្យស្នើសុំស្នើសុំរបស់មន្ទីរ។

**ប្រការ៨.-**

ក្រសួង/មន្ទីរមានរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការក្នុងការពិនិត្យ និងសម្រេចផ្តល់ ឬបដិសេធ ឬបន្តសុពលភាពជូនក្រុមហ៊ុន/សហគ្រាសគិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារពេញលេញ និងគ្រប់ចំនួន។

**ប្រការ៩.-**

ដើមទុនសម្រាប់ប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានត្រូវបានកំណត់ដូចខាងក្រោម÷

**ក- អាជីវកម្មទទួលបញ្ចាំរួមមាន÷**

| | | |
|---|---|---|
| - ខ្នាតតូច | :ត្រូវមានដើមទុនចាប់ពី | ២០ លានរៀល ដល់ ៤០ លានរៀល |
| - ខ្នាតមធ្យម | :ត្រូវមានដើមលើសពី | ៤០ លានរៀល ដល់ ២០០ លានរៀល |
| - ខ្នាតធំ (កម្រិត១) | :ត្រូវមានដើមទុនលើសពី ២០០ លានរៀល ដល់ ៨០០ លានរៀល | |
| - ខ្នាតធំ (កម្រិត២) | :ត្រូវមានដើមទុនលើសពី ៨០០ លានរៀល ឡើងទៅ | |

**ខ- អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានរួមមាន÷**

| | | |
|---|---|---|
| - ខ្នាតតូច | :ត្រូវមានដើមទុនចាប់ពី | ២០ លានរៀល ដល់ ៤០ លានរៀល |
| - ខ្នាតមធ្យម | :ត្រូវមានដើមទុនលើសពី | ៤០ លានរៀល ដល់ ២០០ លានរៀល |
| - ខ្នាតធំ (កម្រិត១) | :ត្រូវមានដើមទុនលើសពី ២០០ លានរៀល ដល់ ៨០០ លានរៀល | |
| - ខ្នាតធំ (កម្រិត២) | :ត្រូវមានដើមទុនលើសពី ៨០០ លានរៀល ឡើងទៅ | |

រាល់ការបន្ថែម ឬបន្ថយដើមទុនអាជីវកម្មខាងលើត្រូវមានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន។

**ប្រការ១០.-**

ប្រភេទ ខ្នាត ថ្លៃ និងសុពលភាពអាជ្ញាបណ្ណប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានដែលចេញដោយក្រសួងត្រូវបានកំណត់ដូចខាងក្រោម÷

| ល.រ | ប្រភេទ | | ថ្លៃអាជ្ញាបណ្ណថ្មី/បន្ត | សុពលភាព |
|---|---|---|---|---|
| -អាជីវកម្មទទួលបញ្ចាំ | | | | |
| ១ | អាជ្ញាបណ្ណ | ខ្នាតមធ្យម | ២.០០០.០០០រៀល/០១ឆ្នាំ | ០៣ឆ្នាំ |
| | | ខ្នាតធំ (កម្រិត១) | ៣.០០០.០០០រៀល/០១ឆ្នាំ | |
| | | ខ្នាតធំ (កម្រិត២) | ៤.០០០.០០០រៀល/០១ឆ្នាំ | |
| ២ | អាជ្ញាបណ្ណសាខា | ខ្នាតមធ្យម | ១.០០០.០០០រៀល/០១ឆ្នាំ | ០៣ឆ្នាំ |
| | | ខ្នាតធំ (កម្រិត១) | ១.៥០០.០០០រៀល/០១ឆ្នាំ | |
| | | ខ្នាតធំ (កម្រិត២) | ២.០០០.០០០រៀល/០១ឆ្នាំ | |
| -អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន | | | | |
| ១ | អាជ្ញាបណ្ណ | ខ្នាតមធ្យម | ១.០០០.០០០រៀល/០១ឆ្នាំ | ០៣ឆ្នាំ |
| | | ខ្នាតធំ (កម្រិត១) | ១.៥០០.០០០រៀល/០១ឆ្នាំ | |
| | | ខ្នាតធំ (កម្រិត២) | ២.០០០.០០០រៀល/០១ឆ្នាំ | |
| ២ | អាជ្ញាបណ្ណសាខា | ខ្នាតមធ្យម | ៥០០.០០០រៀល/០១ឆ្នាំ | ០៣ឆ្នាំ |
| | | ខ្នាតធំ (កម្រិត១) | ៧៥០.០០០រៀល/០១ឆ្នាំ | |
| | | ខ្នាតធំ (កម្រិត២) | ១.០០០.០០០រៀល/០១ឆ្នាំ | |

ថ្លៃអាជ្ញាបណ្ណ ឬថ្លៃបន្តសុពលភាពអាជ្ញាបណ្ណដូចមានចែងក្នុងប្រការនេះត្រូវបង់រៀងរាល់០១ (មួយ) ឆ្នាំម្តងទៅក្នុងគណនីចរន្តរបស់រតនាគារជាតិដែលបើកនៅធនាគារជាតិ នៃកម្ពុជាតាមដីកាអមរបស់នាយកដ្ឋាន។

អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំបង់ថ្លៃបន្តសុពលភាពអាជ្ញាបណ្ណប្រចាំឆ្នាំឱ្យបាន៣០ ថ្ងៃមុន នៃឆ្នាំបន្ទាប់។

**ប្រការ១១.-**

ប្រភេទ ថ្លៃ និងសុពលភាពលិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូច ដែលចេញដោយមន្ទីរត្រូវបានកំណត់ដូចខាងក្រោម÷

| ល.រ | ប្រភេទ | | ថ្លៃលិខិតអនុញ្ញាតថ្មី/ បន្ត | សុពលភាព |
|---|---|---|---|---|
| -អាជីវកម្មទទួលបញ្ចាំ | | | | |
| ១ | លិខិតអនុញ្ញាត | ខ្នាតតូច | ១.០០០.០០០រៀល | ០១ឆ្នាំ |
| ២ | លិខិតអនុញ្ញាតសាខា | ខ្នាតតូច | ៥០០.០០០រៀល | ០១ឆ្នាំ |
| -អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន | | | | |
| ១ | លិខិតអនុញ្ញាត | ខ្នាតតូច | ៥០០.០០០រៀល | ០១ឆ្នាំ |
| ២ | លិខិតអនុញ្ញាតសាខា | ខ្នាតតូច | ២៥០.០០០រៀល | ០១ឆ្នាំ |

ថ្លៃលិខិតអនុញ្ញាតប្រកបអាជីវកម្មដូចមានចែងក្នុងប្រការនេះ ត្រូវបង់ចូលគណនីចរន្តរបស់សាខារតនាគារជាតិ ដែលបើកនៅសាខាធនាគារជាតិ នៃកម្ពុជានៅបណ្តារាជធានី-ខេត្ត តាមដីកាអមរបស់មន្ទីរសាមីរាជធានី-ខេត្ត នោះ។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតឱ្យបាន ៣០ ថ្ងៃមុនលិខិតអនុញ្ញាតនោះផុតសុពលភាព និងត្រូវបង់ថ្លៃបន្តសុពលភាពដូចមានចែងក្នុងប្រការនេះ។

**ប្រការ១២.-**

ក្រុមហ៊ុន/ សហគ្រាស អាចបង្កើតសាខាបានលុះត្រាតែមានអាជ្ញាបណ្ណពីក្រសួង/ លិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ។

ដើម្បីបើកសាខាបានក្រុមហ៊ុន/ សហគ្រាសត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ៦ និងប្រការ ៧នៃប្រកាសនេះ។

## ជំពូកទី៤

## កិច្ចដំណើរការអាជីវកម្មទទួលបញ្ញើ និងទទួលប្រាតិភោគដោយអនុប្បទាន

### ផ្នែកទី១

### ភារកិច្ចរបស់អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម

**ប្រការ១៣.-**

**អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មមានភារកិច្ចដូចខាងក្រោម÷**

- ត្រូវទទួលខុសត្រូវចំពោះអតិថិជនដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន
- ត្រូវមានស្លាកយីហោអាជីវកម្មនៅពីមុខកន្លែងធ្វើអាជីវកម្ម ហើយអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវដាក់បង្ហាញនៅកន្លែងដែលងាយមើលឃើញ
- ត្រូវធ្វើអាជីវកម្មឱ្យបានត្រឹមត្រូវស្របតាមឈ្មោះ អាសយដ្ឋានដែលបានបញ្ជាក់នៅក្នុងអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ត្រូវមានកិច្ចសន្យា និងសៀវភៅកត់ត្រាប្រតិបត្តិការអាជីវកម្មទទួលបញ្ញើ ឬទទួលប្រាតិភោគដោយអនុប្បទាន និងត្រូវថែរក្សាទុកដាក់ឱ្យបានល្អ។ ទម្រង់កិច្ចសន្យា និងសៀវភៅកត់ត្រាប្រតិបត្តការអាជីវកម្មនឹងមានផ្តល់ជូនដោយក្រសួង
- រាល់កិច្ចសន្យាដាក់បញ្ញើ ឬដាក់ប្រាតិភោគដោយអនុប្បទានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជាមួយអតិថិជនព្រមទាំងមានការបញ្ជាក់ឱ្យបានច្បាស់លាស់នូវព័ត៌មានអប្បរមា លក្ខខណ្ឌ រយៈពេលកិច្ចសន្យាដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ១៦ និងភារកិច្ចដែលគូភាគីបានព្រមព្រៀងគ្នាដោយមានការចុះហត្ថលេខា ឬស្នាមមេដៃទទួលស្គាល់ត្រឹមត្រូវដោយគូភាគីនៃកិច្ចសន្យា
- ត្រូវរក្សាទុកទ្រព្យបញ្ញើ និង/ ឬប្រាតិភោគដោយអនុប្បទាននៅកន្លែងដែលមានសុវត្ថិភាព និងមិនត្រូវយកទ្រព្យនោះទៅប្រើប្រាស់ឡើយ
- ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាត ឬបាត់បង់លើទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគដោយអនុប្បទានកើតឡើងក្នុងអំឡុងពេលជាប់កិច្ចសន្យា
- ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ឱ្យនគរបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មក្នុងករណីមានការសង្ស័យចំពោះអតិថិជន ឬទ្រព្យណាមួយដែលពាក់ព័ន្ធនឹងបទល្មើស
- ត្រូវផ្តល់ព័ត៌មាន ឬរបាយការណ៍អំពីអត្តសញ្ញាណនៃអតិថិជន និងទ្រព្យ (សៀវភៅចុះបញ្ជីទ្រព្យ) ជូនប៉ុស្តិ៍នគរបាលរដ្ឋបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មក្នុងរយៈពេល០៧ (ប្រាំពីរ )ថ្ងៃយ៉ាងយូរបន្ទាប់ពីកាលបរិច្ឆេទទទួលទ្រព្យបញ្ញើ និង/ ឬទ្រព្យប្រាតិភោគដោយអនុប្បទាន
- ត្រូវធានាថារាល់ការផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុន/ សហគ្រាសត្រូវតែជាការពិត និងមានការបញ្ជាក់ពីអត្តលេខក្រុមហ៊ុន/ សហគ្រាស

- ត្រូវបិទផ្សាយថ្ងៃ និងពេលវេលាម៉ោងធ្វើការរបស់ខ្លួននៅមុខច្រកទ្វារចេញ-ចូលនៃកន្លែងអាជីវកម្មឱ្យបានត្រឹមត្រូវ និងមិនត្រូវមានប្រតិបត្តិការទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងប្រមូលការប្រាក់ឡើយក្រៅពីថ្ងៃ ឬម៉ោងដែលបានប្រកាសបិទមិនធ្វើការ
- ត្រូវផ្តល់របាយការណ៍ឱ្យបានទៀងទាត់ដូចមានចែងក្នុងប្រការ២៩នៃប្រកាសនេះ ដោយត្រូវបញ្ជាក់ថាពិតជាត្រឹមត្រូវដោយនាយកក្រុមហ៊ុន/សហគ្រាស
- ត្រូវបំពេញកាតព្វកិច្ចពន្ធដារឱ្យបានត្រឹមត្រូវដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ
- ត្រូវរាយការណ៍ជាបន្ទាន់ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានៃធនាគារជាតិនៃកម្ពុជា ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ឬមកក្រសួង/មន្ទីរក្នុងករណីសង្កេតឃើញសកម្មភាពណាមួយដែលបម្រើដល់ការលាងសម្អាតប្រាក់ ឬបម្រើផលប្រយោជន៍ដល់ភេរវករ ឬបទល្មើសភេរវកម្មណាមួយ
- ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលនៅជាធរមាន។

**ប្រការ១៤..**

ក្រុមហ៊ុន/សហគ្រាសត្រូវបានហាមឃាត់សកម្មភាពអាជីវកម្មមួយចំនួនដូចខាងក្រោម÷

- មិនត្រូវផ្សព្វផ្សាយពាណិជ្ជកម្មដែលមានលក្ខណៈមិនពិត ឬឆបោក ឬនាំឱ្យមានការយល់ខុស ឬធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈ
- មិនត្រូវទទួលយកទ្រព្យអ្វីមួយពីអនីតិជន ឬពីជនណាមួយដែលកំពុងឋិតក្នុងភាពស្រវឹងជោគជាំ ជនវិប្បល្លាសស្មារតី ឬពីជនណាមួយដែលសង្ស័យថាជាចោរ ឬអ្នកទទួលផលចោរកម្ម
- មិនត្រូវបង្កវិវាទឬជិវាទក្នុងការធ្វើអាជីវកម្មជាមួយអ្នកទទួលបញ្ចាំ ឬប្រាតិភោគដោយអនុប្បទានដទៃទៀត
- មិនត្រូវចូលរួម ឬធ្វើអាជីវកម្ម ដើម្បីបម្រើដល់សកម្មភាពលាងសម្អាតប្រាក់ឬបម្រើផលប្រយោជន៍ដល់ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ
- មិនត្រូវទទួលយកទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានណាដែលពុំមានឯកសារ ឬលិខិតបញ្ជាក់អត្តសញ្ញាណទ្រព្យច្បាស់លាស់
- មិនត្រូវធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
- មិនត្រូវទទួលយកទ្រព្យណាមួយដែលច្បាប់ហាមឃាត់។

## ផ្នែកទី ២
## ការផ្តល់ប្រាក់កម្ចី

**ប្រការ១៥..**

ចំពោះក្រុមហ៊ុន/សហគ្រាស ដែលទទួលបានអាជ្ញាបណ្ណពីក្រសួង ការផ្តល់ប្រាក់កម្ចីដល់អ្នកដាក់បញ្ចាំ ឬដល់អ្នកដាក់ប្រាតិភោគដោយអនុប្បទាន ០១ ប្រតិបត្តិការមិនត្រូវលើសពី ២០ % (ម្ភៃភាគរយ) នៃដើមទុនអាជីវកម្មដែលបានប្រកាសឡើយ។ ការផ្តល់ប្រាក់កម្ចីសម្រាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុមិនត្រូវលើសពី ២០.០០០.០០០ (ម្ភៃលាន) រៀលឡើយក្នុងមួយប្រតិបត្តិការនៃទ្រព្យបញ្ចាំ។

ចំពោះក្រុមហ៊ុន/សហគ្រាស ដែលទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ ការផ្តល់ប្រាក់កម្ចីដល់អ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន ០១ ប្រតិបត្តិការមិនត្រូវលើសពី ២០ % (ម្ភៃភាគរយ) នៃដើមទុនអាជីវកម្មដែលបានប្រកាសឡើយ។ ការផ្តល់ប្រាក់កម្ចីសម្រាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុមិនត្រូវលើសពី ៤.០០០.០០០ (បួនលាន) រៀលក្នុងមួយប្រតិបត្តិការនៃទ្រព្យបញ្ចាំនោះ។

## ផ្នែកទី ៣
## អត្រាការប្រាក់ និងរយៈពេលនៃការដាក់បញ្ញើ និង/ឬប្រាតិភោគដោយអនុប្បទាន

**ប្រការ១៦.-**

អត្រាការប្រាក់ត្រូវកំណត់តាមការព្រមព្រៀងរវាងអ្នកទទួលបញ្ញើ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន និងអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន និងត្រូវអនុលោមតាមបទប្បញ្ញត្តិ និងច្បាប់ដែលនៅជាធរមាន។

កិច្ចសន្យានេះមានសុពលភាពអនុវត្តយ៉ាងយូរត្រឹម០៤ (បួន) ខែ ចាប់ពីកាលបរិច្ឆេទនៃការដាក់ទ្រព្យបញ្ញើ ឬដាក់ទ្រព្យប្រាតិភោគដោយអនុប្បទាន និងអាចបន្តសុពលភាពសារជាថ្មីបាន។

## ផ្នែកទី ៤
## ការចាត់ចែងទ្រព្យ

**ប្រការ១៧.-**

ក្នុងករណីអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានបានសងប្រាក់កម្ចី និងការប្រាក់គ្រប់ចំនួនដូចមានចែងក្នុងកិច្ចសន្យាក្រុមហ៊ុន/សហគ្រាសត្រូវប្រគល់ទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគដោយអនុប្បទានទៅឱ្យអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានវិញភ្លាម។

**ប្រការ១៨.-**

ក្រុមហ៊ុន/សហគ្រាស ពុំមានសិទ្ធិលក់ ផ្ទេរ ប្រើប្រាស់ ឬប្រគល់សិទ្ធិកាន់កាប់ទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគ-ដោយអនុប្បទាន ឱ្យទៅបុគ្គលផ្សេងទៀតក្នុងអំឡុងពេលដែលទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគដោយអនុប្បទាននោះកំពុងជាប់កិច្ចសន្យា ដោយពុំមានការឯកភាពពីអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានឡើយ។

**ប្រការ១៩.-**

ក្នុងករណីអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានពុំមានលទ្ធភាពសងប្រាក់កម្ចីនិងការប្រាក់តាមការកំណត់នៅពេលកិច្ចសន្យាដល់កាលវសានការចាត់ចែងលើទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគដោយអនុប្បទានមានដូចខាងក្រោម÷

- **សម្រាប់អាជីវកម្មទទួលបញ្ញើ**÷ទ្រព្យបញ្ញើត្រូវចាត់ចែងអនុលោមតាមនីតិវិធីដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- **សម្រាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន**÷ទ្រព្យប្រាតិភោគដោយអនុប្បទាននឹងត្រូវចាត់ចែងតាមលទ្ធភាពជាក់ស្តែង ឬនីតិវិធីដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៥
## ការផ្លាស់ប្តូរទីតាំង នាមករណ៍ ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម

**ប្រការ២០.-**

រាល់ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវមានការឯកភាពជាមុនពីក្រសួង/មន្ទីរ។

ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរមុននឹងធ្វើការផ្លាស់ប្តូរ។

ក្រសួង ឬមន្ទីរ ត្រូវជូនដំណឹងអំពីការសម្រេចឯកភាព ឬជំទាស់ ក្នុងរយៈពេល ៣០ ថ្ងៃនៃថ្ងៃធ្វើការ ឬរយៈពេលសមស្របណាមួយ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលសំណើ។

**ប្រការ២១.-**

ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគទុននិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មរបស់ក្រុមហ៊ុន/សហគ្រាសត្រូវផ្តល់ឯកសារដូចខាងក្រោម÷

**ក. ការស្នើសុំផ្លាស់ប្តូរទីតាំងអាជីវកម្មរបស់ក្រុមហ៊ុន/សហគ្រាស÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្លាស់ប្តូរដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- លិខិតឯកភាពពីអាជ្ញាធរដែនដីចំពោះទីតាំងអាជីវកម្មថ្មី
- លិខិតបញ្ជាក់ស្តីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធ
- ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុទីតាំងថ្មី ឬកិច្ចសន្យាជួលទីតាំងថ្មី
- ឯកសារបញ្ជាក់ពីការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការផ្លាស់ប្តូរទីតាំងអាជីវកម្ម និងជម្រះបញ្ជីប្រតិបត្តិការជាមួយអតិថិជនឱ្យបានរួចរាល់

**ខ. ការស្នើសុំផ្លាស់ប្តូរនាមករណ៍របស់ក្រុមហ៊ុន/សហគ្រាស÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្លាស់ប្តូរនាមករណ៍ដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការផ្លាស់ប្តូរនាមករណ៍ ឬលិខិតសម្រេចរបស់នាយកក្រុមហ៊ុន/សហគ្រាស
- ឯកសារបញ្ជាក់ពីការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការផ្លាស់ប្តូរនាមករណ៍

**គ. ការស្នើសុំផ្លាស់ប្តូរភាគទុននិក ឬសមាជិកក្រុមប្រឹក្សាភិបាលប្រកបអាជីវកម្ម÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ស្តីពីការស្នើសុំផ្លាស់ប្តូរភាគទុននិក ឬសមាជិកក្រុមប្រឹក្សាភិបាលដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការផ្លាស់ប្តូរភាគទុននិក ឬសមាជិកក្រុមប្រឹក្សាភិបាល
- លិខិតទិញ-លក់ភាគហ៊ុនរបស់ភាគហ៊ុននិក
- លិខិតថ្កោលទោសឬលិខិតបញ្ជាក់កិរិយាមារយាទចេញដោយអាជ្ញាធរមានសមត្ថកិច្ច

**ឃ. ការស្នើសុំផ្លាស់ប្តូរអ្នកកាន់អាជ្ញាបណ្ណ/អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ស្តីពីការស្នើសុំផ្លាស់ប្តូរដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មច្បាប់ដើម
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬលិខិតបញ្ជាក់បទពិសោធន៍ពាក់ព័ន្ធធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះចំពោះអ្នកកាន់អាជ្ញាបណ្ណ។
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬលិខិតបញ្ជាក់បទពិសោធន៍ពាក់ព័ន្ធធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ ចំពោះអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- លិខិតថ្កោលទោស ឬលិខិតបញ្ជាក់កិរិយាមាយាទចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

## ផ្នែកទី ៦
## ប្រាក់តម្កល់ធានាអាជីវកម្ម

**ប្រការ២២.-**

ក្រុមហ៊ុន/សហគ្រាស ខ្នាតមធ្យម និងខ្នាតធំត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១០ % (ដប់ភាគរយ) នៃដើមទុនប្រកបអាជីវកម្មទៅក្នុងគណនីទោលរតនាគារជាតិដែលបើកនៅធនាគារជាតិ នៃកម្ពុជាតាមដីការអមរបស់នាយកដ្ឋាន។

ក្រុមហ៊ុន/សហគ្រាសខ្នាតតូច ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១០% (ដប់ភាគរយ) នៃដើមទុនប្រកបអាជីវកម្មទៅក្នុងគណនីទោលរបស់សាខារតនាគារជាតិ ដែលបើកនៅសាខាធនាគារជាតិនៃកម្ពុជាតាមដីការអមរបស់មន្ទីរសាមីនោះ។

ប្រាក់តម្កល់ធានាអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២ ខាងលើអាចដកវិញបានក្រោយពីក្រុមហ៊ុន/សហគ្រាសបានបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ ហើយត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ២៥ ។

**ប្រការ២៣.-**

នៅក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃបានទទួលលិខិតស្នើសុំដកប្រាក់តម្កល់ និងឯកសារតម្រូវផ្សេងៗ ក្រសួងត្រូវចេញលិខិតអនុញ្ញាតឱ្យដក ឬលិខិតបដិសេធដកប្រាក់តម្កល់នោះ ដោយបញ្ជាក់ហេតុផលត្រឹមត្រូវ។

## ជំពូកទី ៥
## ការផ្អាក និងការបញ្ឈប់សកម្មភាពអាជីវកម្ម

**ប្រការ២៤.-**

ក្នុងករណីផ្អាកសកម្មភាពអាជីវកម្ម ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្អាកដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- លិខិតបញ្ជាក់ស្តីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់សារពើពន្ធ
- លិខិតជូនដំណឹងទៅអាជ្ញាធរពន្ធដារមានសមត្ថកិច្ចស្តីពីការផ្អាកសកម្មភាពអាជីវកម្ម
- ឯកសារពាក់ព័ន្ធការជម្រះបញ្ជីជាមួយអតិថិជនដែលដាក់បញ្ញើ ឬដាក់ប្រាតិភោគដោយអនុប្បទាន

ក្រសួង/មន្ទីរអនុញ្ញាតឱ្យ ក្រុមហ៊ុន/សហគ្រាសផ្អាកសកម្មភាពអាជីវកម្មរបស់ខ្លួនជាបណ្តោះអាសន្នយ៉ាងយូរត្រឹម៤ (បួន) ខែ ក្នុង១ (មួយ) ឆ្នាំ ឬត្រឹមសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលនៅសល់តែប៉ុណ្ណោះ។

**ប្រការ២៥.-**

ក្នុងករណីបញ្ឈប់សកម្មភាពអាជីវកម្ម ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ មុនបញ្ឈប់សកម្មភាពអាជីវកម្ម និងត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម៖

- លិខិតស្នើសុំបញ្ឈប់អាជីវកម្មដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់
- អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មច្បាប់ដើម
- លិខិតបញ្ជាក់ពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវដែលចេញដោយអាជ្ញាធរពន្ធដារមានសមត្ថកិច្ច
- ឯកសារពាក់ព័ន្ធការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការបញ្ឈប់សកម្មភាពអាជីវកម្ម និងការជម្រះបញ្ជីប្រតិបត្តិការជាមួយអតិថិជន
- បង្កាន់ដៃបង់ប្រាក់តម្កល់ធានាអាជីវកម្ម។

**ប្រការ២៦.-**

នៅក្នុងរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃបានទទួលលិខិតស្នើសុំផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្ម ឯកសារតម្រូវផ្សេងៗក្រសួង/មន្ទីរ ត្រូវចេញលិខិតបញ្ជាក់យល់ព្រម ឬបដិសេធសំណើរបស់ក្រុមហ៊ុន/សហគ្រាសដោយបញ្ជាក់ហេតុផលត្រឹមត្រូវ។

## ជំពូកទី៦
## ការត្រួតពិនិត្យ និងរបាយការណ៍

**ប្រការ២៧.-**

ក្រសួង/មន្ទីរមានសិទ្ធិចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងដើម្បីធានាដល់ការអនុវត្តប្រកាសនេះ។

**ប្រការ២៨.-**

មន្ទីរត្រូវផ្តល់ជូននាយកដ្ឋាននូវរបាយការណ៍ដូចខាងក្រោម÷

-របាយការណ៍ប្រចាំត្រីមាសស្តីពីសកម្មភាពអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានឱ្យបានមុនថ្ងៃទី១៥ នៃត្រីមាសបន្ទាប់

-របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានឱ្យបានមុនបំណាច់ត្រីមាសទី១ នៃឆ្នាំសារពើពន្ធ។

ទម្រង់នៃរបាយការណ៍ខាងលើត្រូវបានកំណត់ទៅតាមគំរូដែលនាយកដ្ឋានបានផ្តល់ជូន។

**ប្រការ២៩.-**

ក្រុមហ៊ុន/សហគ្រាសដែលទទួលបានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវផ្តល់ជូនក្រសួង/មន្ទីរនូវរបាយការណ៍ដូចខាងក្រោម÷

- របាយការណ៍ប្រតិបត្តិការអាជីវកម្មប្រចាំខែមិនឱ្យលើសពីថ្ងៃទី១៥ នៃខែបន្ទាប់
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនឱ្យលើសពីត្រីមាសទី១ នៃឆ្នាំបន្ទាប់

ទម្រង់នៃរបាយការណ៍ខាងលើត្រូវបានកំណត់តាមគំរូដែលកំណត់ដោយក្រសួង។

**ប្រការ៣០.-**

ក្រសួង/មន្ទីរមានសិទ្ធិតែងតាំងសវនករឯករាជ្យ ដើម្បីធ្វើសវនកម្មក្រុមហ៊ុន/សហគ្រាសទាំងអស់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ក្នុងករណីរកឃើញភាពមិនប្រក្រតីលើឯកសារពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មដែលផ្តល់ដោយក្រុមហ៊ុន/សហគ្រាស ដោយរាល់ការចំណាយលើសវនករឯករាជ្យជាបន្ទុករបស់ក្រុមហ៊ុន/សហគ្រាស។

## ជំពូកទី៧
## ការផ្សះផ្សា និងដោះស្រាយវិវាទ

**ប្រការ៣១.-**

វិវាទរវាងក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានជាមួយក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន និង/ឬជាមួយអ្នកដាក់បញ្ចាំ/អ្នកដាក់ប្រាតិភោគដោយអនុប្បទានពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មបញ្ចាំ ឬប្រាតិភោគដោយអនុប្បទានអាចជាកម្មវត្ថុនៃការសម្រុះសម្រួល និងផ្សះផ្សាដោយអគ្គនាយកដ្ឋាន/មន្ទីរ។

ក្រសួង/មន្ទីរសម្រុះសម្រួល និងផ្សះផ្សាវិវាទតាមការស្នើសុំរបស់ភាគីវិវាទក្នុងរយៈពេល០២ខែយ៉ាងយូរ។ ការផ្សះផ្សាវិវាទអាចឈានទៅដល់ការចុះកិច្ចព្រមព្រៀងផ្សះផ្សា ដែលត្រូវចុះហត្ថលេខាដោយគូភាគីវិវាទដោយមានប្រថាប់ត្រារបស់អគ្គនាយកដ្ឋាន/មន្ទីរ។ កិច្ចព្រមព្រៀងផ្សះផ្សាមានអានុភាពអនុវត្តភ្លាមៗចំពោះគូភាគី។

**ប្រការ៣២.-**

ក្រុមហ៊ុន/សហគ្រាស ឬអ្នកដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានដែលមិនពេញចិត្តចំពោះសេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់ក្រសួង/មន្ទីរមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាមកក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុននឹងអនុវត្តនីតិវិធីបណ្តឹងទៅតុលាការលើកលែងតែរឿងព្រហ្មទណ្ឌ។

ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវដោះស្រាយបណ្តឹងក្នុងរយៈពេល៩០ ថ្ងៃនៃថ្ងៃធ្វើការក្រោយពីទទួលបានពាក្យបណ្តឹងតវ៉ា ឬក្នុងរយៈពេលមួយសមស្រប។

ក្នុងការដោះស្រាយវិវាទក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចអញ្ជើញភាគីពាក់ព័ន្ធវិវាទដើម្បីសាកសួរ ឬផ្តល់ភស្តុតាងតាមការចាំបាច់។

សេចក្តីសម្រេច ស្តីពីការដោះស្រាយវិវាទត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់អំពីអង្គហេតុសំអាងហេតុ និងការសន្និដ្ឋាន។

ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានីតិកម្ម ភាគីវិវាទអាចដាក់ពាក្យបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៨

## ទោសប្បញ្ញត្តិ

**ប្រការ៣៣.-**

ត្រូវបានចាត់ទុកជាអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះចំពោះអំពើដូចខាងក្រោម÷

- ប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន គ្មានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ក្លែងបន្លំអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ប្រើប្រាស់អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាព
- ប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ផ្តល់ប្រាក់កម្ចីខុសពីលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះ
- យឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃមុនពេលអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនោះផុតសុពលភាព
- បង្កើតសាខាដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរ
- ប្រកបអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលបានផ្តល់ជូន
- អនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៤ ប្រការ១៥ ប្រការ២០ ប្រការ២៤ និងប្រការ២៥ នៃប្រកាសនេះ
- មិនបានផ្តល់ ឬផ្តល់របាយការណ៍យឺតយ៉ាវតាមការកំណត់ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះ
- ពុំអនុវត្តតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ក្រសួង។

**ប្រការ៣៤.-**

ក្រុមហ៊ុន/សហគ្រាសទាំងឡាយណាដែលបានប្រព្រឹត្តកំហុសដូចមានចែងក្នុងប្រការ៣៣នៃប្រកាសនេះនឹងត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

- ព្រមានជាលាយលក្ខណ៍អក្សរ
- ហាមឃាត់ការធ្វើប្រតិបត្តិការឬរឹតត្បិតសកម្មភាពមួយចំនួន
- ព្យួរអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មបណ្តោះអាសន្នពី០៦ ខែទៅ១ ឆ្នាំ
- ដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះ

- ចាត់វិធានការផ្សេងៗទៀតទៅតាមច្បាប់ជាធរមាន។

**ប្រការ៣៥.-**

ក្រសួង/មន្ទីរមានសិទ្ធិព្យួរអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅពេលដែលក្រុមហ៊ុន/សហគ្រាសបានប្រព្រឹត្តល្មើសក្នុងករណីណាមួយដូចខាងក្រោម÷

- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំខែដោយចេតនា ឬអចេតនាក្រោយពីទទួលបានការព្រមានជាលាយលក្ខណ៍អក្សរ
- បង្កើតសាខាដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន
- ប្រកបអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលបានផ្តល់ជូនដោយចេតនាក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរ
- បន្តអនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៤ ប្រការ១៥ ប្រការ២០ ប្រការ២៤ និងប្រការ២៥ នៃប្រកាសនេះក្រោយពីទទួលបានលិខិតព្រមានជាលាយលក្ខណ៍អក្សរ។

**ប្រការ៣៦.-**

ក្រសួង/មន្ទីរ មានសិទ្ធិដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅពេលដែលក្រុមហ៊ុន/សហគ្រាសបានប្រព្រឹត្តល្មើសក្នុងករណីណាមួយដូចខាងក្រោម÷

- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំខែដោយចេតនា ឬអចេតនាចាប់ពី០៦ ខែឡើងទៅ
- ក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរលើកទី២ ហើយនៅតែមិនរៀងចាលទៀត
- ខកខានមិនបានបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធលើសពី០៦ ខែឡើងទៅ
- ប្រើប្រាស់អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពលើសពី០៣ ខែឡើងទៅ
- ក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរ ហើយនៅតែបន្តប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មទៀត
- ផ្តល់ប្រាក់កម្ចីខុសពីលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះលើសពី០៥ ករណីឡើងទៅ
- យឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មលើសពី០៣ ខែ ក្រោយពេលអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនោះផុតសុពលភាព
- បង្កើតសាខាលើសពី០២ (ពីរ) សាខាឡើងទៅដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន
- ធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម ដែលបានផ្តល់ជូនដោយចេតនាក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរលើកទី២ហើយ
- នៅបន្តអនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៧ ប្រការ១៩ និងប្រការ២៥ នៃប្រកាសនេះក្រោយពីអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវបានព្យួររួចហើយ
- បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬប្រព្រឹត្តបទល្មើសហិរញ្ញវត្ថុ ឬអំពើមិនស្របច្បាប់ណាមួយដែលមានភស្តុតាងច្បាស់លាស់ពីអាជ្ញាធរមានសមត្ថកិច្ច។

ក្រសួង/មន្ទីរ នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរចំនួន៣០ (សាមសិប) ថ្ងៃមុននឹងដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មពីក្រុមហ៊ុន/សហគ្រាសដែលបានប្រព្រឹត្តខុស។

**ប្រការ៣៧.-**

ការប្រកបអាជីវកម្មទទួលបញ្ចាំ/ទទួលប្រាតិភោគដោយអនុប្បទានដោយគ្មានអាជ្ញាបណ្ណ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន១០.០០០.០០០ (ដប់លាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ដើម្បីអាចប្រកបអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមកក្រសួង។

ការប្រកបអាជីវកម្មទទួលបញ្ចាំ/ទទួលប្រាតិភោគដោយអនុប្បទាន ដោយគ្មានលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ៥.០០០.០០០(ប្រាំលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ដើម្បីអាចប្រកបអាជីវកម្មបានក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មមកមន្ទីរ។

**ប្រការ៣៨.-**

ការក្លែងបន្លំអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១០.០០០.០០០ (ដប់លាន) រៀល និងបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

ការក្លែងបន្លំលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល និងបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

**ប្រការ៣៩.-**

ការប្រើប្រាស់អាជ្ញាបណ្ណផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល និងត្រូវរួសរាន់ដាក់ពាក្យស្នើសុំបន្តសុពលភាពក្នុងករណីមិនរាងចាលក្រសួងនឹងចាត់វិធានការបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

ការប្រើប្រាស់លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.៥០០.០០០ (ពីរលានប្រាំរយពាន់) រៀល និងត្រូវរួសរាន់ដាក់ពាក្យស្នើសុំបន្តសុពលភាពក្នុងករណីមិនរាងចាលមន្ទីរនឹងចាត់វិធានការបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

**ប្រការ៤០.-**

ការប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.០០០.០០០ (ពីរលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

ការប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.០០០.០០០(មួយលាន) រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤១.-**

ការផ្តល់ប្រាក់កម្ចីលើសពីដើមទុនដែលបានប្រកាសជាមួយក្រសួងត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៣.០០០.០០០ (បីលាន) រៀល។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរអាជ្ញាបណ្ណបណ្តោះអាសន្ន។

ការផ្តល់ប្រាក់កម្ចីលើសពីដើមទុនដែលបានប្រកាសជាមួយមន្ទីរត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.៥០០.០០០ (មួយលានប្រាំរយពាន់) រៀល។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរអាជ្ញាបណ្ណបណ្តោះអាសន្ន។

**ប្រការ៤២.-**

ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបង់ថ្លៃបន្តសុពលភាពអាជ្ញាបណ្ណប្រចាំឆ្នាំដូចមានចែងក្នុងប្រការ១០ ត្រូវទទួលពិន័យអន្តរការណ៍ចំនួន២០.០០០(ម្ភៃពាន់) រៀល ក្នុង ០១ ថ្ងៃសម្រាប់រយៈពេល៣០ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលចំនួនទឹកប្រាក់ជាតពិន័យត្រូវគុណទ្វេដង។

ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតប្រកបអាជីវកម្មក្នុងរយៈពេល៣០ថ្ងៃមុន លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន១០.០០០ (ដប់ពាន់)រៀល ក្នុង០១ថ្ងៃសម្រាប់រយៈពេល៣០ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍ត្រូវគុណទ្វេដង។

**ប្រការ៤៣.-**

ការបង្កើតសាខាដោយគ្មានអាជ្ញាបណ្ណពីក្រសួងត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៣.០០០.០០០ (បីលាន) រៀល ក្នុង០១សាខា និងត្រូវផ្អាកសកម្មភាពអាជីវកម្មសាខា។ ដើម្បីអាចបន្តសកម្មភាពអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសាខានោះ។ ក្នុងករណីមិនរាងចាលក្រសួងនឹងព្យួរឬដកហូតអាជ្ញាបណ្ណក្រុមហ៊ុន/ សហគ្រាសមេ។

ការបង្កើតសាខាដោយគ្មានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.៥០០.០០០ (មួយលានប្រាំរយពាន់) រៀលក្នុង០១ សាខា និងត្រូវផ្អាកសកម្មភាពអាជីវកម្មសាខា។ ដើម្បីអាចបន្តសកម្មភាពអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសម្រាប់សាខានោះ។ ក្នុងករណីមិនរាងចាលមន្ទីរនឹងព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមហ៊ុន/ សហគ្រាសមេ។

**ប្រការ៤៤.-**

ការធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន២.០០០.០០០ (ពីរលាន) រៀលក្នុង០១ករណី និងផ្អាកអាជីវកម្មនោះជាបន្ទាន់។ ក្នុងករណីមិនរាងចាលក្រសួងនឹងព្យួរ ឬដកហូតអាជ្ញាបណ្ណនោះ។

ការធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី និងផ្អាកអាជីវកម្មនោះជាបន្ទាន់។ ក្នុងករណីមិនរាងចាលមន្ទីរនឹងព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្មនោះ។

**ប្រការ៤៥.-**

ក្រោយពីទទួលលិខិតព្រមានជាលាយលក្ខណ៍អក្សរ អ្នកកាន់អាជ្ញាបណ្ណនៅតែប្រព្រឹត្តផ្ទុយនឹងចំណុចណាមួយនៃប្រការ១៣ និងប្រការ១៤ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន៤០០.០០០ (បួនរយពាន់) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការដកហូត ឬបញ្ឈប់សកម្មអាជីកម្ម។

ក្រោយពីទទួលលិខិតព្រមានជាលាយលក្ខណ៍អក្សរ ហើយអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅតែប្រព្រឹត្តផ្ទុយនឹងចំណុចណាមួយនៃប្រការ១៣ និងប្រការ១៤ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ពីមន្ទីរចំនួន២០០.០០០ (ពីររយពាន់)រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការដកហូត ឬបញ្ឈប់សកម្មអាជីកម្ម។

**ប្រការ៤៦.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ១៥ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.០០០.០០០(ពីរលាន) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ១៥ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤៧.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ២០ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី និងត្រូវផ្អាកសកម្មភាពអាជីវកម្មជាបន្ទាន់ហើយត្រូវបំពេញឯកសារស្នើសុំ។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ២០ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន៥០០.០០០ (ប្រាំរយពាន់) រៀលក្នុង០១ ករណី និងត្រូវផ្អាកសកម្មភាពអាជីវកម្មជាបន្ទាន់។ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤៨.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលផ្តល់របាយការណ៍យឺតយ៉ាវដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន២០.០០០ (ម្ភៃពាន់) រៀលក្នុង០១ (មួយ) ថ្ងៃសម្រាប់រយៈពេល៣០ ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរ ឬដកហូតអាជ្ញាបណ្ណ។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលផ្តល់របាយការណ៍យឺតយ៉ាវ ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន១០.០០០ (ដប់ពាន់) រៀល ក្នុង០១ (មួយ) ថ្ងៃសម្រាប់រយៈពេល៣០ ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្ម។

## ជំពូកទី០៩

## អន្តរប្បញ្ញត្តិ

**ប្រការ៤៩.-**

អាជ្ញាបណ្ណទទួលបញ្ចាំ និង/ឬទទួលប្រាតិភោគដោយអនុប្បទានដែលក្រសួងផ្តល់ជូនមុនពេលដាក់ឱ្យអនុវត្តប្រកាសនេះនៅបន្តមានសុពលភាពរហូតដល់ផុតកាលកំណត់សុពលភាពរបស់អាជ្ញាបណ្ណនោះ។

## ជំពូកទី១០

## អវសានប្បញ្ញត្តិ

**ប្រការ៥០.-**

ប្រកាសលេខ០២៨សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្តល់អាជ្ញាបណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥១.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រុមហ៊ុន/សហគ្រាស និងបុគ្គលដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

ថ្ងៃទី១៣ខែ មករា ឆ្នាំ២០១៧

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល:-**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- ធនាគារជាតិនៃកម្ពុជា
- សាលារាជធានី-ខេត្ត
- ដូចប្រការ៥១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ







ទម្រង់កិច្ចសន្យារបស់អាជីវកម្មបញ្ចាំ ឬប្រាតិភោគអនុប្បទានដែលអនុវត្តសព្វថ្ងៃនៅកម្ពុជា ។



លី សៀក ឡុង
(ហេង សៀក ឡុង)

ទំងន់........ 9.54

ល្អួល........

អ្នកទិញបានមើល ថ្លឹង និងយល់ព្រមតាមទម្ងន់ខាងលើត្រឹមត្រូវ

អ្នកលក់
ហេង វុចនា

Police Commissariat Of Kandal Province



បណ្ណាត់ថៃបញ្ចាំ №000970



បណ្ណាត់ថៃបញ្ចាំ №000970



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឈ្មោះ........
របស់បញ្ចាំ........
ចំនួនទឹកប្រាក់........ 550
ទទួលថ្ងៃទី........ 21 ខែ........ 6 ឆ្នាំ ២០ 17
ផុតកំណត់ថ្ងៃទី........ 21 ខែ........ 7 ឆ្នាំ ២០